ធនាគារជាតិ នៃ កម្ពុជា
NATIONAL BANK OF CAMBODIA

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

# របាយការណ៍ប្រចាំឆមាសទី ១
# និង
# ទិសដៅការងារឆមាសទី ២
# ឆ្នាំ២០១២

ព្រះរាជាណាចក្រកម្ពុជា

KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ

NATION  RELIGION  KING


ធនាគារជាតិ នៃ កម្ពុជា

NATIONAL BANK OF CAMBODIA


# របាយការណ៍ប្រចាំឆមាសទី ១

# និង

# ទិសដៅការងារឆមាសទី ២

# ឆ្នាំ២០១២

# អារម្ភកថា

នៅក្នុងឆមាសទី១ ឆ្នាំ២០១២នេះ ស្ថានភាពសេដ្ឋកិច្ចពិភពលោកមានស្ថិរភាពជាបង្គួរ ដោយសារការងើបឡើងវិញបន្តិចម្តងៗនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក រួមជាមួយការខិតខំយ៉ាងសកម្មក្នុងការរកដំណោះស្រាយចំពោះវិបត្តិបំណុលនៅតំបន់អឺរ៉ុប ខណៈសម្ពាធអតិផរណាសកលបានថយចុះបន្តិច ។ ទន្ទឹមនោះ ប្រព័ន្ធហិរញ្ញវត្ថុសកលក៏បានធូរស្បើយមួយកម្រិត បន្ទាប់ពីភាពចលាចលទីផ្សារហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងរនៅឆ្នាំ២០១១ ។

ទោះបីសកម្មភាពសេដ្ឋកិច្ចនាដើមឆ្នាំ២០១២ ជារួមនៅមានល្បឿនយឺត ប៉ុន្តែមានការរំពឹងទុកនូវលទ្ធផលប្រសើរជាងនេះនាឆមាសទី២ ។ តាមការព្យាកររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ កំណើនសេដ្ឋកិច្ចពិភពលោកនៅឆ្នាំ២០១២ មានកម្រិតត្រឹម ៣,៥% ធៀបនឹង ៤% នៅឆ្នាំ២០១១ ។ ស្ថានភាពសេដ្ឋកិច្ចនៅសហគមន៍អឺរ៉ុបអាចមាននិន្នាការធ្លាក់ចុះក្នុងកម្រិតទាបមួយ ខណៈដែលប្រទេសជឿនលឿនដទៃទៀតនៅក្រៅតំបន់អឺរ៉ុប រួមទាំងប្រទេសជប៉ុនផងដែរ ប្រឈមនឹងកំណើនទាបនៅឡើយ ។ ការព្យាករកំណើនសេដ្ឋកិច្ចឆ្នាំ២០១២ ចំពោះសហរដ្ឋអាមេរិកមាន ២% (១,៧% ឆ្នាំ២០១១) និងអាឡឺម៉ង់ ១% (៣,១% ឆ្នាំ២០១១) ។ ដោយឡែក ប្រទេសឧស្សាហកម្មនៅអាស៊ី អាចនឹងមានកំណើន ២,២% នៅឆ្នាំ២០១២ ដែលខ្ពស់ជាងកម្រិត -០,២% នៅឆ្នាំ២០១១ ក្នុងនោះ ប្រទេសអូស្ត្រាលី ៣% (២% ឆ្នាំ២០១១) និងជប៉ុន ២,៤% (-០,៧% ឆ្នាំ២០១១) ។ ចំណែកឯប្រទេសកំពុងអភិវឌ្ឍន៍ និងកំពុងងើបឡើង មានកំណើន ៥,៦% (៦,២% ឆ្នាំ២០១១) ក្នុងនោះ សេដ្ឋកិច្ចប្រទេសចិនត្រូវបានរំពឹងថានឹងមានកំណើន ៨% (៩,២% ឆ្នាំ២០១១) និងឥណ្ឌា ៦,១% (៧,១% ឆ្នាំ២០១១) ។ ទន្ទឹមនោះ ប្រទេសកូរ៉េ និងតៃវ៉ាន់ ដែលជាដៃគូពាណិជ្ជកម្មនិងវិនិយោគសំខាន់សម្រាប់កម្ពុជា ត្រូវបានរំពឹងថាមានកំណើន ៣,៥% និង ៣,៦% រៀងគ្នា ។

ការព្យាកររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ក៏បានបង្ហាញផងដែរនូវកំណើនសេដ្ឋកិច្ចប្រទេសអាស៊ានប្រមាណ ៥,២% នៅឆ្នាំ២០១២ ពី ៤,៦% ឆ្នាំ២០១១ ក្នុងនោះ ប្រទេសឡាវមានកំណើនខ្ពស់ជាងគេដល់ ៨,៤% កម្ពុជា ៦,៣% ហើយសិង្ហបុរីមានកំណើនត្រឹម ២,៧% ។ មកទល់បច្ចុប្បន្ន មូលដ្ឋានសេដ្ឋកិច្ចនិងនយោបាយដ៏រឹងមាំនៅតំបន់អាស៊ី គឺជារនាំងទប់ស្កាត់ការឆ្លងរាលដាលនៃវិបត្តិទីផ្សារហិរញ្ញវត្ថុ និងកាត់បន្ថយផលប៉ះពាល់ពីការបន្ថយលេវើរិច[១] នៅតំបន់អឺរ៉ុប ។ ចំណែកឯអតិផរណាក្នុងតំបន់ត្រូវបានរំពឹងថានឹងថយចុះមកត្រឹម ៥% ក្នុងឆ្នាំ២០១២ ។ ទោះបីជាដូច្នេះក្តី បរិស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភពលោកដែលពុំទាន់រឹងមាំនៅឡើយ នៅតែជាហានិភ័យខ្ពស់សម្រាប់តំបន់អាស៊ី និងអាចបង្កផលប៉ះពាល់អវិជ្ជមានដល់សម្ពាធអតិផរណាផងដែរ ។ អនុសាសន៍គោលនយោបាយចំពោះអាស៊ាន រួមមាន ការបន្តជំរុញតម្រូវការក្នុងស្រុក លើកកម្ពស់វិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តដើម្បីទ្រទ្រង់វិនិយោគឯកជន និងពង្រីកមូលដ្ឋានសេដ្ឋកិច្ច រួមទាំងរក្សាចីរភាពស្ថានភាពសារពើពន្ធ និងនយោបាយរូបិយវត្ថុរឹតត្បិតតាមការចាំបាច់ ។

ចំពោះប្រទេសកម្ពុជាវិញ រាជរដ្ឋាភិបាលបានព្យាករថា នៅឆ្នាំ២០១២ សេដ្ឋកិច្ចអាចមានកំណើនប្រមាណ ៦,៩% (៧,១% ឆ្នាំ២០១១) ដែលទ្រទ្រង់ដោយគោលនយោបាយសារពើពន្ធ និងគោលនយោបាយរូបិយវត្ថុទន់ភ្លន់ និងការខិតខំរបស់រាជរដ្ឋាភិបាលក្នុងការជួយស្តារស្ថានភាពវិស័យកសិកម្មពីគ្រោះទឹកជំនន់

[១] deleveraging

ទាន់ពេលវេលា ។ វិស័យឧស្សាហកម្មត្រូវបានរំពឹងថានឹងកើនឡើង ១១,៨% និងបន្តរួមចំណែកជាចម្បងនៅក្នុងកំណើនសេដ្ឋកិច្ច ខណៈវិស័យសេវាកម្មមានកំណើន ៦,៨% និងវិស័យកសិកម្ម ២,៤% ។ ការនាំចេញសម្លៀកបំពាក់និងវាយនភ័ណ្ឌត្រូវបានរំពឹងថានឹងបន្ថយល្បឿនបន្តិចក្នុងអត្រាកំណើនប្រមាណ ១0% ដោយសារសកម្មភាពសេដ្ឋកិច្ចនៃប្រទេសដៃគូនាំចូលនៅទន់ខ្សោយ ។ ចំពោះវិស័យធនាគារវិញ ក្នុងនាមជាអាជ្ញាធររូបិយវត្ថុនិងត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជាបានខិតខំបន្តបំពេញតួនាទីរបស់ខ្លួនក្នុងការរក្សាស្ថិរភាពថ្លៃតាមរយៈការអនុវត្តនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន និងបានរួមចំណែកពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច សំដៅជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ។

នៅក្នុងឆមាសទី១ ឆ្នាំ២០១២ អត្រាអតិផរណាបានបង្ហាញនូវនិន្នាការថយចុះគួរកត់សម្គាល់ គឺពី ៥,៨% នៅខែមករា មក ១,៨% នៅខែមិថុនា ។ ក្នុងអំឡុងពេលដូចគ្នានេះ ប្រាក់រៀលរក្សាបានស្ថិរភាពយ៉ាងប្រសើរ ដោយប្រែប្រួលក្នុងគម្លាតមួយតូចជាងឆ្នាំកន្លងទៅ ហើយមានអត្រាមធ្យម ៤.0៤៤ រៀល ក្នុង ១ដុល្លារអាមេរិក នឹងឡើងថ្លៃ 0,២% ធៀបនឹងគ្រាដូចគ្នានៃឆ្នាំ២០១១ ។ នេះគឺជាស្ថិរភាពដ៏ល្អធៀបនឹងរូបិយប័ណ្ណដទៃទៀតក្នុងតំបន់ និងអំណោយផលដល់ការបង្កើនជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀលថែមទៀត ។

ទុនបម្រុងអន្តរជាតិបានបន្តកើនឡើងជាបន្តបន្ទាប់ដល់ចំនួន ៣.២៣១ លានដុល្លារអាមេរិក ដែលអាចធានាការនាំចូលបានប្រមាណ ៤,៥ ខែ ។ ការគ្រប់គ្រងទុនបម្រុងត្រូវបានអនុវត្តដោយប្រុងប្រយ័ត្ន និងផ្អែកលើគោលការណ៍សុវត្ថិភាព និងសន្ទនីយភាពជាចម្បង ស្របតាមភាពរឹងមាំជាលំដាប់នៃមូលដ្ឋានសេដ្ឋកិច្ច ។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបន្តជំរុញអន្តរការិយកម្មធនាគារ ពង្រឹងសុខុមាលភាព ស្ថិរភាព និងបង្កើនប្រសិទ្ធភាពប្រព័ន្ធធនាគារ ។ លទ្ធផលល្អគួរឲ្យកត់សម្គាល់ត្រូវបានស្តែងចេញតាមរយៈភាពប្រសើរឡើងនៃសូចនាករសំខាន់ៗជាច្រើន ។ រូបិយវត្ថុទូទៅមានកំណើនឆ្នាំលើឆ្នាំ ២១,១% ហើយភាពស៊ីជម្រៅវិស័យហិរញ្ញវត្ថុមានកម្រិតប្រមាណ ៤៣% នៅខែមិថុនា ឆ្នាំ២០១២ ធៀបនឹង ៤0% នាគ្រាដូចគ្នានៃឆ្នាំមុន ។ ឥណទានចំពោះវិស័យឯកជន និងប្រាក់បញ្ញើក្នុងវិស័យធនាគារមានកំណើនប្រចាំឆ្នាំ ៣១,៣% និង ២៣,៣% រៀងគ្នា ដែលនាំឲ្យអនុបាតឥណទានធៀបនឹងប្រាក់បញ្ញើកើនដល់ ៨៥,៧% នាដំណាច់ឆមាសទី១ នេះ ។ ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញផលិតកម្មកសិកម្ម ដែលជាវិស័យមានសក្តានុពលខ្ពស់ក្នុងសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានបន្តលើកទឹកចិត្តគ្រឹះស្ថានធនាគារក្នុងការផ្តល់ឥណទានចំពោះវិស័យកសិកម្ម ។ ជាលទ្ធផល ឥណទានចំពោះវិស័យនេះបានកើនឡើងប្រមាណ ៧៤% ឆ្នាំលើឆ្នាំ នាខែមិថុនា ឆ្នាំ២០១២ និងមានចំណែក ១0% នៃឥណទានសរុប ធៀបនឹងកំណើន ៥៦% នាខែមិថុនា ឆ្នាំ២០១១ ។ ជាមួយគ្នានេះដែរ ក្នុងគោលបំណងជួយដោះស្រាយតម្រូវការឥណទានខ្នាតធំ ធនាគារជាតិនៃកម្ពុជាបានគាំទ្រគ្រឹះស្ថានធនាគារឲ្យផ្តល់សង្ឃហឥណទាន[២] ដែលអាចបែងចែកហានិភ័យចំពោះប្រតិបត្តិការធំៗ ។

ទន្ទឹមនឹងការពង្រឹងអន្តរការិយកម្មធនាគារ ស្ថានភាពហិរញ្ញវត្ថុនៃប្រព័ន្ធធនាគារក្នុងឆមាសនេះ ត្រូវបានវាយតម្លៃថាមានលក្ខណៈល្អសមស្រប និងមិនទទួលរងផលប៉ះពាល់ពីវិបត្តិបំណុលនៅតំបន់អឺរ៉ុបឡើយ ។

[២] loan syndicate

លក្ខខណ្ឌសាធនភាពនៃប្រព័ន្ធធនាគារត្រូវបានបន្តរក្សាយ៉ាងហ្មត់ចត់ ដោយគ្រឹះស្ថានធនាគារទាំងអស់គោរព តាមកាតព្វកិច្ចអប្បបរមាដែលបានកំណត់ ។ ជាមួយគ្នានេះដែរ ប្រព័ន្ធធនាគារមានសន្ទនីយភាពសមស្រប ខណៈទ្រព្យសកម្មមានគុណភាពល្អប្រសើរ ។ អនុបាតឥណទានមិនដំណើរការបានថយចុះគួរឲ្យកត់សម្គាល់ ពី ៣,២% នៅខែមិថុនា ឆ្នាំ២០១១ មក ២,៥% នៅខែមិថុនា ឆ្នាំ២០១២ ដែលឆ្លុះបញ្ចាំងជាបឋមនូវដំណើរការ ល្អនៃវិស័យឯកជន ក៏ដូចជាស្ថិរភាពនៃអត្រាការប្រាក់កម្ចី ។

ក្នុងបរិការណ៍ប្រទេសកំពុងអភិវឌ្ឍន៍ ការជំរុញវិស័យឯកជនត្រូវរួមបញ្ចូលផងដែរនូវការអភិវឌ្ឍវិស័យ មីក្រូហិរញ្ញវត្ថុ ហើយធនាគារជាតិនៃកម្ពុជាសម្រេចបាននូវវឌ្ឍនភាពដ៏ប្រសើរក្នុងវិស័យនេះ ជាពិសេស ការ ពង្រឹងក្របខ័ណ្ឌត្រួតពិនិត្យ និងបញ្ញត្តិកម្ម រួមទាំងបទប្បញ្ញត្តិសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ផងដែរ ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុ គឺជាផ្នែកដ៏សំខាន់មួយនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ ហិរញ្ញវត្ថុរយៈកាលវែងរបស់រាជរដ្ឋាភិបាល ។ បច្ចុប្បន្ន ការផ្តល់ឥណទានដោយវិស័យនេះមានការកើនឡើង គួរឲ្យកត់សម្គាល់ដល់ប្រមាណ ៧% ខណៈប្រាក់បញ្ញើបានកើនឡើង ១៦% ធៀបនឹងឆមាសទី១ ឆ្នាំ២០១១ ។

ដោយឡែក ហេដ្ឋារចនាសម្ព័ន្ធវិស័យហិរញ្ញវត្ថុក៏ត្រូវបានពង្រឹងជាបន្តបន្ទាប់ ។ ការងារអាទិភាព បាន ផ្តោតលើការអភិវឌ្ឍប្រព័ន្ធទូទាត់និងផាត់ទាត់ដែលមានលក្ខណៈមជ្ឈការ ដើម្បីជំរុញការប្រើប្រាស់ឧបករណ៍ ទូទាត់ផ្សេងៗក្រៅពីមូលប្បទានបត្រ ព្រមទាំងបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពនៃការទូទាត់ ។ ក្របខ័ណ្ឌ បទប្បញ្ញត្តិ និងនីតិវិធីសម្រាប់ដំណើរការប្រព័ន្ធនេះ កំពុងត្រូវបានរៀបចំ ។ លើសពីនេះ ប្រព័ន្ធចែករំលែក ព័ត៌មានឥណទានក៏ត្រូវបានដាក់ឲ្យដំណើរការ ហើយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់វិស័យហិរញ្ញវត្ថុក៏ត្រូវ បានលើកកម្ពស់ដែរ តាមរយៈការរៀបចំប្រព័ន្ធផ្ញើរបាយការណ៍របស់គ្រឹះស្ថានធនាគារតាមបណ្តាញអ៊ិនធឺណែត មកធនាគារជាតិនៃកម្ពុជា ។

ក្នុងការជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារនិងរូបិយវត្ថុ ធនាគារជាតិនៃកម្ពុជាបានរៀបចំកិច្ចបញ្ជិកា គណនេយ្យ និងប្រព័ន្ធចុះបញ្ជីសម្រាប់ការចេញផ្សាយមូលបត្រអាចជួញដូរបានរបស់ធនាគារជាតិនៃកម្ពុជា និងកំពុងរៀបចំលក្ខណៈចរិតជាយុទ្ធសាស្ត្រនៃឧបករណ៍នេះ ដើម្បីធានាការចេញផ្សាយប្រកបដោយប្រសិទ្ធភាព និងសង្គតិភាពជាមួយគោលនយោបាយរូបិយវត្ថុនិងហិរញ្ញវត្ថុ ។

ដើម្បីពង្រឹងតួនាទីវិស័យហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ច រាជរដ្ឋាភិបាលបានអនុម័តបច្ចុប្បន្នកម្ម "ផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០" នាឆ្នាំ២០១១ ។ ផែនការនេះត្រូវបានប្រកាសផ្សព្វ-ផ្សាយជាផ្លូវការនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១២ ។ ក្នុងនាមភ្នាក់ងារប្រតិបត្តិគម្រោងជំនួយរបស់ធនាគារ អភិវឌ្ឍន៍អាស៊ី ធនាគារជាតិនៃកម្ពុជាបន្តសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នពាក់ព័ន្ធ សំដៅធានាការអនុវត្ត ការងារអាទិភាពដូចមានចែងក្នុងយុទ្ធសាស្ត្រនេះ ប្រកបដោយប្រសិទ្ធភាព ។ ការងារមួយដ៏សំខាន់ចំពោះមុខ គឺការពង្រឹងការប្រើប្រាស់ប្រាក់រៀល ដែលបច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាកំពុងសិក្សារៀបចំវិធីសាស្ត្រ គោល នយោបាយ និងយន្តការសហប្រតិបត្តិការ សំដៅឈានទៅសម្រេចបាននូវគោលដៅរយៈកាលវែងរបស់រាជ រដ្ឋាភិបាល ក្នុងការធ្វើបដិដុល្លារូបនីយកម្មដោយប្រុងប្រយ័ត្ន ។

លើសពីនេះ ការងារអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាក៏មានការរីកចម្រើនជាលំដាប់ ទាំងផ្នែក សហប្រតិបត្តិការបរទេស និងការពង្រឹងសមត្ថភាពក្នុងប្រទេស ។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុវៀតណាម បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្ដីពីការផ្លាស់ប្ដូរព័ត៌មានអំពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ។ អង្គភាពក៏បានខិតខំផងដែរដើម្បីបន្តអនុវត្តអនុសាសន៍របស់ "ក្រុមការងារហិរញ្ញវត្ថុ" និងបានណែនាំដល់គ្រឹះស្ថានហិរញ្ញវត្ថុឲ្យបង្កើត និងពង្រឹងយន្តការ ព្រមទាំងក្របខ័ណ្ឌផ្ទៃក្នុងសម្រាប់អនុវត្តកាតព្វកិច្ចពាក់ព័ន្ធ ។ ប្រព័ន្ធរាយការណ៍ព័ត៌មានក៏ត្រូវបានរៀបចំកាន់តែប្រសើរ ។

ចំពោះសហប្រតិបត្តិការវិស័យធនាគារនិងហិរញ្ញវត្ថុក្នុងតំបន់និងអន្តរជាតិ ធនាគារជាតិនៃកម្ពុជាបានពង្រឹងបន្ថែមទៀតនូវទំនាក់ទំនងជិតស្និទ្ធជាមួយបណ្ដាធនាគារកណ្ដាល និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ។ ក្នុងឆមាសទី១នេះ ធនាគារជាតិនៃកម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំអន្តរជាតិមួយចំនួន ទាំងក្នុងក្របខ័ណ្ឌអាស៊ាន អាស៊ានបូកបី និងស៊ាសិន ក្នុងនោះជាពិសេសគឺ កិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្ដាលអាស៊ានលើកទី៨ និងកិច្ចប្រជុំពាក់ព័ន្ធ រួមទាំងសន្និបាតប្រចាំឆ្នាំនៃសមាគមឥណទានកសិកម្មជនបទនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (APRACA) និងកិច្ចប្រជុំក្រុមប្រឹក្សាទេសាភិបាលធនាគារកណ្ដាលស៊ាសិនលើកទី៣១ ។

ចំពោះមុខ ធនាគារជាតិនៃកម្ពុជានឹងបន្តខិតខំរក្សាស្ថិរភាពរូបិយវត្ថុ និងគ្រប់គ្រងអត្រាអតិផរណាឲ្យស្ថិតក្នុងកម្រិតមួយខ្ទង់ ទន្ទឹមនឹងការផ្ដត់ផ្ដង់សន្ទនីយភាពសមស្របសម្រាប់ការរីកចម្រើននៃសេដ្ឋកិច្ច តាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុទន់ភ្លន់ ។ លើសពីនេះ ចាំបាច់ក៏ត្រូវពង្រឹងការយកចិត្តទុកដាក់បន្ថែមទៀតដើម្បីធានាស្ថិរភាព និងអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុប្រកបដោយចីរភាព រួមទាំងអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុមានលក្ខណៈទូលាយ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

ជារួម ជាមួយនឹងការខិតខំប្រកបដោយការប្ដេជ្ញាចិត្តរបស់មន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់ និងការគាំទ្រប្រកបដោយប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាភិបាលនៃធនាគារជាតិនៃកម្ពុជា ជាពិសេស រាជរដ្ឋាភិបាល និងកិច្ចសហការពីសំណាក់ដៃគូអភិវឌ្ឍន៍ទាំងឡាយ ធនាគារជាតិនៃកម្ពុជាសម្រេចបានលទ្ធផលល្អប្រសើរជាច្រើននៅឆមាសទី១នេះ ។ ខ្ញុំសូមសម្ដែងការអរគុណដ៏ជ្រាលជ្រៅចំពោះក្រុមប្រឹក្សាភិបាល មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា និងគ្រប់ស្ថាប័នពាក់ព័ន្ធ ព្រមទាំងដៃគូអភិវឌ្ឍន៍នានា ដែលបានរួមចំណែកដ៏មានតម្លៃ ក្នុងការសម្រេចបាននូវសមិទ្ធផលទាំងអស់នេះ ។

**ទេសាភិបាល**

# មាតិកា

* * *


ក- របាយការណ៍ប្រចាំឆមាសទី១ ឆ្នាំ២០១២ ១

សេចក្តីផ្តើម ២

I- ការអនុវត្តគោលនយោបាយរូបិយវត្ថុ និងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា ៣

១- ស្ថានភាពថ្លៃ និងតម្លៃប្រាក់រៀល ៣

១.១- ការវិវត្តន៍ថ្លៃទំនិញ និងអតិផរណា ៣

១.២- ស្ថានភាពអត្រាប្តូរប្រាក់ ៥

១.២.១- ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ៥

១.២.២- ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណមួយចំនួន ៧

១.២.៣- ស្ថានភាពអត្រាប្តូរប្រាក់ដុល្លារអាមេរិកធៀបនឹងរូបិយប័ណ្ណមួយចំនួន ៨

២- ការវិវត្តន៍រូបិយវត្ថុ ៨

២.១- ការផ្គត់ផ្គង់រូបិយវត្ថុ ៩

២.២- កត្តាជះឥទ្ធិពលដល់បរិមាណរូបិយវត្ថុ ១០

២.២.១- ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា ១០

២.២.២- ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់គ្រឹះស្ថានធនាគារ ១១

២.៣- អត្រាការប្រាក់លើប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់គ្រឹះស្ថានធនាគារ ១១

៣- ជញ្ជីងទូទាត់ ១៣

៣.១- គណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) ១៣

៣.២- គណនីបង្វែរផ្លូវការ និងហិរញ្ញវត្ថុ ១៤

៤- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ១៥

៤.១- ការដាក់វិនិយោគទុនបម្រុងអន្តរជាតិ ១៥

៤.២- អន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់ ១៦

៤.៣- ការគ្រប់គ្រងអាជីវកម្មមាស និងប្តូរប្រាក់ ១៦

៥- សម្ព័ន្ធការជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ១៦

៥.១- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ១៧

៥.១.១- ការត្រួតពិនិត្យលើឯកសារ ១៧

៥.១.២- ការត្រួតពិនិត្យដល់ទីកន្លែង ១៧

៥.១.៣- ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ១៧

៥.២- ការងារនីតិកម្ម ១៨

៥.៣- ការងារផ្តល់អាជ្ញាប័ណ្ណ និងជម្រះបញ្ជី ១៩

៦- ការផ្គត់ផ្គង់សេវាធនាគារកណ្តាល ១៩

៦.១- សេវាគ្រប់គ្រងគណនី ១៩

៦.១.១- ស្ថាប័នរដ្ឋ ១៩

៦.១.២- គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ១៩

៦.២- សេវាផ្ទេរប្រាក់ក្នុងប្រទេស ២០

៦.៣- សេវាផាត់ទាត់មូលប្បទានបត្រ ២០

៦.៣.១- ការផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល ២០

៦.៣.២- ការផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់ដុល្លារអាមេរិក ២០

៦.៤- ការងារឥណទាន ២០

៦.៥- ការងារគ្រប់គ្រងមូលបត្រ ២០

៦.៦- ការងារអនុវត្តហិរញ្ញប្បទាន និងកម្ចីពីរដ្ឋាភិបាលជប៉ុន ២១

៧- ការគ្រប់គ្រងចរាចរណ៍ធនបត្រ ២២

៨- ការអភិវឌ្ឍប្រព័ន្ធទូទាត់ ២៣

៩- ការងារព័ត៌មានវិទ្យា ២៣

II- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា ២៤
១- សកម្មភាពក្រុមប្រឹក្សាភិបាល ២៤
២- ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស ២៤
២.១- ស្ថិតិមន្ត្រីបុគ្គលិក ២៤
២.២- ការងារបណ្តុះបណ្តាល ២៥
៣- ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ២៥
៤- ការងារគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា ២៦
III- ទំនាក់ទំនងអន្តរជាតិ ២៧
១- ទំនាក់ទំនងពហុភាគី ២៧
១.១- មូលនិធិរូបិយវត្ថុអន្តរជាតិ ២៧
១.២- ធនាគារអភិវឌ្ឍន៍អាស៊ី ២៧
១.៣- អាស៊ាន និងអាស៊ាន+៣ ២៧
១.៤- មជ្ឈមណ្ឌលធនាគារកណ្តាលអាស៊ីអាគ្នេយ៍ (ស៊ាសិន - SEACEN) ២៩
១.៥- សមាគមធនាគារកណ្តាលនៃបណ្តាប្រទេសនិយាយភាសាបារាំង (ហ្វ្រង់កូហ្វូន - Francophone) ២៩
១.៦- សមាគមឥណទានកសិកម្មជនបទនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (APRACA) ២៩
២- ទំនាក់ទំនងទ្វេភាគី ៣០
សន្និដ្ឋាន ៣១
ខ- ទិសដៅការងារឆមាសទី២ ឆ្នាំ២០១២ ៣៣
១- ការងាររូបិយវត្ថុ ៣៤
២- ការងារគ្រប់គ្រងអត្រាប្តូរប្រាក់ និងទុនបម្រុង ៣៤
៣- ការងារអភិវឌ្ឍន៍ប្រព័ន្ធទូទាត់ ៣៤
៤- ការងារត្រួតពិនិត្យ ៣៤
៥- ការងារប្រតិបត្តិការ ៣៥

៦- ការងារបោះផ្សាយ និងឃ្លាំងបេឡា ៣៥

៧- ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ៣៥

៨- ការងារគ្រប់គ្រងសាខា ៣៥

៩- ការងារព័ត៌មានវិទ្យា ៣៥

១០- ការងារបណ្តុះបណ្តាល ៣៥

១១- ការងារទំនាក់ទំនងអន្តរជាតិ ៣៦

ឧបសម្ព័ន្ធ ៣៧

ឧបសម្ព័ន្ធ ១ ការវិវត្តន៍នៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវា ៣៨

ឧបសម្ព័ន្ធ ២ ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ (អត្រាទិញចុងខែ) ៣៩

ឧបសម្ព័ន្ធ ៣ ស្ថានភាពរូបិយវត្ថុ (ឯកតា : ពាន់លានរៀល) ៤០

ឧបសម្ព័ន្ធ ៤ ស្ថានភាពរូបិយវត្ថុ (បម្រែបម្រួលជាភាគរយប្រចាំខែ) ៤១

ឧបសម្ព័ន្ធ ៥ តារាងគណនីវិភាគធនាគារជាតិនៃកម្ពុជា ៤២

ឧបសម្ព័ន្ធ ៦ តារាងគណនីវិភាគធនាគារពាណិជ្ជ ៤៣

ឧបសម្ព័ន្ធ ៧ ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច ៤៤

ឧបសម្ព័ន្ធ ៨ ជញ្ជីងទូទាត់ប្រទេសកម្ពុជា (ឆ្នាំ២០០៨ ដល់ ឆមាសទី១ ឆ្នាំ២០១២) ៤៥

# ក- របាយការណ៍ប្រចាំឆមាសទី១ ឆ្នាំ២០១២

## សេចក្តីផ្តើម

រាជរដ្ឋាភិបាលព្យាករថា នៅឆ្នាំ២០១២នេះ សេដ្ឋកិច្ចកម្ពុជាមានមូលដ្ឋានកំណើនរឹងមាំ និងមានអត្រាកំណើនប្រហាក់ប្រហែលឆ្នាំមុន ។ កំណើននេះ ត្រូវបានគាំទ្រដោយការធ្វើពិពិធកម្មសេដ្ឋកិច្ចលើវិស័យកសិកម្ម និងទេសចរណ៍ និងការបន្តងើបឡើងសន្សឹមៗនៃវិស័យឧស្សាហកម្ម កាត់ដេរ និងសំណង់ ។ ភាពរឹងមាំនៃវិស័យធនាគារនិងហិរញ្ញវត្ថុ និងការរីកចម្រើននៃហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចជារូបវន្តទូទាំងប្រទេស គួបផ្សំនឹងជំនឿទុកចិត្តរបស់វិនិយោគិនជាតិ-អន្តរជាតិ បានជួយគាំទ្រដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចជាតិ ។

ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធររូបិយវត្ថុនិងត្រួតពិនិត្យ បានរួមចំណែកយ៉ាងសកម្មក្នុងការសម្រេចបានសមិទ្ធផលនេះ ដោយបានអនុវត្តនយោបាយរូបិយវត្ថុប្រកបដោយភាពទន់ភ្លន់ និងប្រុងប្រយ័ត្ន ដើម្បីរក្សាស្ថិរភាពថ្លៃ និងពង្រឹងស្ថិរភាពប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ស្របតាមគោលនយោបាយរបស់រាជ-រដ្ឋាភិបាល ។ ក្នុងបរិការណ៍នៃសេដ្ឋកិច្ចដុល្លារូបនីយកម្មខ្ពស់ ធនាគារជាតិនៃកម្ពុជាបានខិតខំពង្រឹងយន្តការប្រើប្រាស់ប្រាក់រៀល ។ អត្រាប្តូរប្រាក់នៅតែជាឧបករណ៍ចម្បង ហើយរបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រងបានអនុញ្ញាតឲ្យការអនុវត្តនយោបាយរូបិយវត្ថុមានភាពទន់ភ្លន់ល្អ ។ ជាលទ្ធផល បច្ចុប្បន្ន អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកត្រូវបានរក្សាឲ្យមានស្ថិរភាពល្អប្រសើរ ហើយបានរួមចំណែកធ្វើឲ្យអត្រាអតិផរណាស្ថិតនៅក្នុងកម្រិតទាបអាចគ្រប់គ្រងបាន ។

ជាមួយគ្នានេះ ប្រព័ន្ធធនាគារត្រូវបានពង្រឹង និងរក្សាឲ្យមានសុវត្ថិភាព ខណៈដែលប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិនៅពុំទាន់មានភាពនឹងនរ ។ វឌ្ឍនភាពនេះអាចឆ្លុះបញ្ចាំងតាមរយៈកំណើននៃភាពស៊ីជម្រៅហិរញ្ញវត្ថុ អន្តរការិយកម្មហិរញ្ញវត្ថុ និងចំនួនប្រតិបត្តិករប្រព័ន្ធធនាគារ ។ លើសពីនេះទៅទៀត ក្នុងគោលបំណងអភិវឌ្ឍប្រព័ន្ធធនាគារឲ្យប្រព្រឹត្តទៅដោយរលូន រឹងមាំ និងមានសុវត្ថិភាព មានលក្ខណៈប្រកួតប្រជែង និងសមាហរណជាមួយប្រទេសក្នុងតំបន់ និងពិភពលោក ធនាគារជាតិនៃកម្ពុជាបានខិតខំពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិ និងការត្រួតពិនិត្យឲ្យកាន់តែមានប្រសិទ្ធភាពស្របតាមការវិវត្តន៍រីកចម្រើននៃវិស័យហិរញ្ញវត្ថុក្នុងតំបន់ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ របស់រាជរដ្ឋាភិបាល ។ ក្រៅពីនេះ ប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់ការគ្រប់គ្រង និងកាត់បន្ថយហានិភ័យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

ទន្ទឹមនឹងនេះ ធនាគារជាតិនៃកម្ពុជាក៏បានបន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលនៃប្រទេសក្នុងតំបន់ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដើម្បីផ្លាស់ប្តូរព័ត៌មាននិងបទពិសោធន៍ថ្មីៗ ដែលទាក់ទងនឹងបញ្ហាប្រឈម និងការស្វែងរកដំណោះស្រាយក្នុងការគ្រប់គ្រងប្រតិបត្តិការធនាគារកណ្តាល និងការអភិវឌ្ឍប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុឲ្យកាន់តែស៊ីជម្រៅថែមទៀត ។

## I-ការអនុវត្តគោលនយោបាយរូបិយវត្ថុ និងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា

### ១-ស្ថានភាពថ្លៃ និងតម្លៃប្រាក់រៀល

#### ១.១-ការវិវត្តន៍ថ្លៃទំនិញ និងអតិផរណា

សម្ពាធអតិផរណានៃប្រទេសដៃគូពាណិជ្ជកម្មក្នុងតំបន់ និងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ គួបផ្សំនឹងការអភិវឌ្ឍគួរឲ្យកត់សម្គាល់នៃអន្តរការិយកម្មហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារក្នុងស្រុកផងនោះ បានជះឥទ្ធិពលដល់អតិផរណានៅកម្ពុជា ។ប៉ុន្តែដោយបានបន្តអនុវត្តនយោបាយរូបិយវត្ថុសមស្របទន់ភ្លន់ និងប្រុងប្រយ័ត្ន អតិផរណាក្នុងស្រុកត្រូវបានរក្សាឲ្យស្ថិតនៅក្នុងកម្រិតទាបសមរម្យ ។ អត្រាអតិផរណាមធ្យមប្រចាំឆ្នាំនាឆមាសទី១ ឆ្នាំ២០១២ នេះ មានកម្រិត ៤,២% ធៀបនឹង ៤,៩% នាគ្រាដូចគ្នានៃឆ្នាំ២០១១។

ក្រាហ្វ ១ : **អតិផរណាឆ្នាំលើឆ្នាំ**




ពិនិត្យលើបម្រែបម្រួលឆ្នាំលើឆ្នាំឃើញថា នាដំណាច់ឆមាសទី១នេះ អតិផរណាមានអត្រា ១,៨% ទាបជាង ៧,១% នៅឆ្នាំ២០១១ និង ២,៦% នាឆ្នាំ២០១០ ។ ជារួម អតិផរណាមាននិន្នាការថយចុះជាបន្តបន្ទាប់ចាប់ពីខែកុម្ភៈរហូតដល់ខែមិថុនា ។ គួរបញ្ជាក់ថា ការថយចុះជាបន្តបន្ទាប់ក្នុងអំឡុងឆមាសទី១ នេះ បណ្តាលមួយផ្នែកមកពីការកើនឡើងខ្ពស់នៃកម្រិតអតិផរណានៅគ្រាដូចគ្នាឆ្នាំ២០១១ ដែលជាឆ្នាំមូលដ្ឋាននៃការគណនាអតិផរណាឆ្នាំលើឆ្នាំ ។

ក្រាហ្វ ២ : **ក្រុមមុខទំនិញដែលឡើងថ្លៃខ្លាំងជាងគេក្នុងឆមាសទី១ ឆ្នាំ២០១២** (ឆ្នាំលើឆ្នាំ)




ចលនាថយចុះនៃអត្រាអតិផរណាឆ្នាំលើឆ្នាំនាឆមាសទី១នេះ ឆ្លុះបញ្ចាំងដោយការថយចុះនៃសន្ទស្សន៍ថ្លៃក្រុមគមនាគមន៍ ០,៨% និងក្រុមសុខាភិបាល ០,៣% ក្រុមដឹកជញ្ជូន ០,៣% រួមជាមួយនឹងការកើនឡើងក្នុងកម្រិតទាបជាងគ្រាដូចគ្នាឆ្នាំមុននៃសន្ទស្សន៍ថ្លៃក្រុមទំនិញមួយចំនួនទៀត រួមមានក្រុម ផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ននិងឥន្ទនៈដទៃទៀត ០,៦% ម្ហូបអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង ២,៣% ភោជនីយដ្ឋាន ៣,៦% និង ទំនិញនិងសេវាកម្មផ្សេងៗ ៤,២% សម្លៀកបំពាក់និងស្បែកជើង ៤,៣% ។ ការកើនឡើងនៃសន្ទស្សន៍ថ្លៃក្រុមម្ហូបអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង ដែលជាក្រុមមានមេគុណខ្ពស់ជាងគេបំផុតនោះ ជាចម្បងបណ្តាលមកពីការឡើងថ្លៃសាច់គោ ១៤,២% បន្លែ ១១,៨% ប្រេងឆានិងខ្លាញ់ ៨,៣% សាច់ទា ៤,៥% អង្ករ ៤,៤% និងផ្លែឈើ ១,១% ខណៈដែល សាច់ជ្រូកបានធ្លាក់ថ្លៃ ០,៩% ។ ដោយឡែក ការថយចុះនៃសន្ទស្សន៍ថ្លៃក្រុមការដឹកជញ្ជូនដែលរាប់បញ្ចូលទាំងថ្លៃប្រេងឥន្ទនៈផងនោះ ជាចម្បងគឺបណ្តាលមកពីការថយចុះថ្លៃ ប្រេងសាំង ៤,៤% ប្រេងម៉ាស៊ូត ៣,៧% និងប្រេងម៉ាស៊ីន ១,២% ។

ក្រាហ្វ ៣ : **ការរួមចំណែកក្នុងអតិផរណា** (ឆ្នាំលើឆ្នាំ)



កត្តាមួយចំនួនដែលបានរួមចំណែកក្នុងអតិផរណារួមប្រចាំឆមាសដែលស្មើ ១,៨% នេះ រួមមាន ក្រុមម្ហូបអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង ១% (ត្រូវនឹងសមាមាត្រ ៥៦% នៃអត្រាអតិផរណារួម) ក្រុមភោជនីយដ្ឋាន ០,២% (ត្រូវនឹងសមាមាត្រ ១១,៦% នៃអត្រាអតិផរណារួម) ក្រុមសម្លៀកបំពាក់និងស្បែកជើង ០,១% (ត្រូវនឹងសមាមាត្រ ៦,៣% នៃអត្រាអតិផរណារួម) ក្រុមផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ននិងឥន្ធនៈដទៃទៀត ០,១% (ត្រូវនឹងសមាមាត្រ ៥,៥% នៃអត្រាអតិផរណារួម) ក្រុមសង្ហារិម និងសម្ភារៈប្រើប្រាស់គ្រួសារនិងការថែទាំផ្ទះជាប្រចាំ ០,១% (ត្រូវនឹងសមាមាត្រ ៥,៣% នៃអត្រាអតិផរណារួម) និង ៧ក្រុមទៀតដែលនៅសល់បានចូលរួមចំណែកតែ ០,១% ប៉ុណ្ណោះ (ត្រូវនឹងសមាមាត្រ ៧,៨% នៃអត្រាអតិផរណារួម) ។

ក្រាហ្វ ៤ : **អតិផរណាមិនរាប់បញ្ចូលក្រុមទំនិញមួយចំនួន** (ឆ្នាំលើឆ្នាំ)




ខណៈដែលអតិផរណារួមមានកម្រិត ១,៨% អត្រាអតិផរណាមិនរាប់បញ្ចូលក្រុមម្ហូបអាហារមានកម្រិត ០,៩% ដែលបញ្ជាក់ឲ្យឃើញថា ថ្លៃទំនិញក្រុមម្ហូបអាហារមានឥទ្ធិពលខ្លាំងក្នុងការជំរុញឲ្យអតិផរណារួមកើនឡើង ។ ដោយឡែក អត្រាអតិផរណាមិនរាប់បញ្ចូលក្រុមទំនិញនិងសេវាពាក់ព័ន្ធនិងប្រេងឥន្ធនៈដែលបញ្ចូលទាំងថ្លៃសេវាដឹកជញ្ជូនផងនោះ មានអត្រា ២,៣% ទិន្នន័យនេះបង្ហាញថា ថ្លៃប្រេងឥន្ធនៈ និងសេវាដឹកជញ្ជូនមិនបានជំរុញឲ្យអតិផរណាសរុបកើនឡើងទេ តែផ្ទុយទៅវិញ ទំនិញក្រុមនេះបានទាញឲ្យអត្រាអតិផរណារួមថយចុះទៅវិញ ។

### ១.២-ស្ថានភាពអត្រាប្តូរប្រាក់

#### *១.២.១-ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក*

ក្នុងឆមាសទី១ ឆ្នាំ២០១២ នេះ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកមានស្ថិរភាពល្អប្រសើរក្នុងអំឡុង ៤ខែដើមឆ្នាំ និងបានធ្លាក់ថ្លៃបន្តិច នៅខែឧសភា និងខែមិថុនា ។ តាមការសង្កេតចលនាអត្រាប្តូរប្រាក់ប្រចាំខែ អត្រាទិញទីផ្សារចុងគ្រាមាននិន្នាការធ្លាក់ចុះជាបន្តបន្ទាប់ ពី ៤.០៥៧ រៀល ក្នុង១ដុល្លារអាមេរិក នៅខែធ្នូ ឆ្នាំ២០១១ មក ៤.០៤២ រៀល ក្នុង១ដុល្លារអាមេរិក នៅខែមេសា ឆ្នាំ២០១២ ពោលគឺប្រាក់រៀលបានឡើងថ្លៃ ០,៤% បន្ទាប់មកបានកើនឡើងរហូតដល់ ៤.០៩០ រៀល ក្នុង១ដុល្លារអាមេរិក នៅដំណាច់ឆមាសទី១ នេះ ។

ផ្អែកលើអត្រាមធ្យមប្រចាំខែ ក្នុងអំឡុងពីខែមករា ដល់ខែមេសា ប្រាក់រៀលបានឡើងថ្លៃ 0,៦% ដោយអត្រាទិញទីផ្សារបានធ្លាក់ចុះពី ៤.០៣៦ រៀល នាខែធ្នូ ឆ្នាំ២០១១ មក ៤.០១៣ រៀល នាខែមេសា ឆ្នាំ២០១២ ។ ការឡើងថ្លៃប្រាក់រៀល ក្នុងអំឡុងបួនខែដើមឆ្នាំ បណ្តាលមកពីកំណើនតម្រូវការប្រាក់រៀលសម្រាប់ការងារប្រមូលកសិផល ការចាយវាយក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ គួបផ្សំនឹងការប្រើប្រាស់ប្រាក់រៀលក្នុងទីផ្សារហ៊ុនដែលទើបនឹងចាប់ដំណើរការជួញដូរនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២នេះ ។ ទន្ទឹមនឹងនោះ តម្លៃប្រាក់ដុល្លារអាមេរិកធៀបនឹងរូបិយប័ណ្ណផ្សេងៗក៏បានចុះថ្លៃផងដែរ ។ ប៉ុន្តែ នៅខែឧសភា និងខែមិថុនា ប្រាក់រៀលបានធ្លាក់ថ្លៃបន្តិចមកវិញ ដោយសារតម្រូវការប្រាក់រៀលបានថយចុះបន្តិច បន្ទាប់ពីរដូវប្រមូលផលបានកន្លងផុត ។

គួរកត់សម្គាល់ផងដែរថា ក្នុងឆមាសទី១ នេះ ធនាគារជាតិនៃកម្ពុជាបានទិញប្រាក់ដុល្លារអាមេរិកចំនួន ៨៤,៥ លានដុល្លារអាមេរិក ដោយចំណាយប្រាក់រៀលអស់ចំនួន ៣៣៨,៧ ពាន់លានរៀល ។ តែទោះជាយ៉ាងនេះក្តី ក៏ប្រាក់រៀលនៅតែរក្សាបានភាពខ្លាំងរបស់ខ្លួន ដោយមានស្ថិរភាពប្រឈមនឹងការប្រែប្រួលតម្លៃប្រាក់ដុល្លារអាមេរិកនៅលើទីផ្សារអន្តរជាតិ ។

ក្រាហ្វ ៥ : **ការវិវត្តន៍នៃអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក**
**(អត្រាទិញទីផ្សារចុងគ្រា)**



## តារាង ១: អត្រាប្តូរប្រាក់ប្រចាំខែ (ចុងខែ)

| | អត្រាទីផ្សារ | | | អត្រាផ្លូវការ | | |
|---|---|---|---|---|---|---|
| | អត្រាទិញ | អត្រាលក់ | អត្រាមធ្យម | អត្រាទិញ | អត្រាលក់ | អត្រាមធ្យម |
| មិថុនា-១១ | ៤.១២២ | ៤.១២៧ | ៤.១២៥ | ៤.១១៥ | ៤.១២៣ | ៤.១១៩ |
| កក្កដា-១១ | ៤.០៩៨ | ៤.១០៦ | ៤.១០២ | ៤.១០០ | ៤.១០៨ | ៤.១០៤ |
| សីហា-១១ | ៤.០៩៦ | ៤.១០៣ | ៤.១០០ | ៤.០៩៣ | ៤.១០១ | ៤.០៩៧ |
| កញ្ញា-១១ | ៤.០៨៤ | ៤.០៩៨ | ៤.០៩១ | ៤.០៨០ | ៤.០៨៨ | ៤.០៨៤ |
| តុលា-១១ | ៤.០៩២ | ៤.០៩៨ | ៤.០៩៥ | ៤.១០០ | ៤.១០៨ | ៤.១០៤ |
| វិច្ឆិកា-១១ | ៤.០៣០ | ៤.០៣៧ | ៤.០៣៤ | ៤.០៣១ | ៤.០៣៩ | ៤.០៣៥ |
| ធ្នូ-១១ | ៤.០៥៧ | ៤.០៦៦ | ៤.០៦២ | ៤.០៣៩ | ៤.០៣៩ | ៤.០៣៩ |
| មករា-១២ | ៤.០៧៣ | ៤.០៨២ | ៤.០៧៨ | ៤.០៦៤ | ៤.០៦៤ | ៤.០៦៤ |
| កុម្ភៈ-១២ | ៤.០១៣ | ៤.០១៨ | ៤.០១៦ | ៤.០១៥ | ៤.០១៥ | ៤.០១៥ |
| មីនា-១២ | ៣.៩៩៥ | ៤.០០៥ | ៤.០០០ | ៣.៩៩៥ | ៣.៩៩៥ | ៣.៩៩៥ |
| មេសា-១២ | ៤.០៤២ | ៤.០៥៦ | ៤.០៤៩ | ៤.០២៥ | ៤.០២៥ | ៤.០២៥ |
| ឧសភា-១២ | ៤.០៩៥ | ៤.១០៥ | ៤.១០០ | ៤.០៦៥ | ៤.០៦៥ | ៤.០៦៥ |
| មិថុនា-១២ | ៤.០៩០ | ៤.០៩៦ | ៤.០៩៣ | ៤.០៦៥ | ៤.០៦៥ | ៤.០៦៥ |

### *១.២.២- ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណមួយចំនួន*

ប្រាក់រៀលជាមួយរូបិយប័ណ្ណនៃប្រទេសដៃគូពាណិជ្ជកម្មរបស់កម្ពុជាក្នុងឆមាសទី១ ឆ្នាំ២០១២ នេះ បានបង្ហាញថា ប្រាក់រៀលបានចុះថ្លៃធៀបនឹង ប្រាក់ប៉េសូហ្វីលីពីន ៤,១% ប្រាក់ដុល្លារនូហ្សេលែន ២,៤% ប្រាក់ដុល្លារតៃវ៉ាន់ ២,៣% ប្រាក់ដុល្លារសិង្ហបុរី ២,១% ប្រាក់ដុងវៀតណាម ១% ប្រាក់ដុល្លារហុងកុង ០,៨% និងប្រាក់វ៉ុនកូរ៉េ ០,១% ។ ទន្ទឹមនឹងនោះ ប្រាក់រៀលបានឡើងថ្លៃធៀបនឹង ប្រាក់រូពីឥណ្ឌូនេស៊ី ៣,៩% ប្រាក់អឺរ៉ូ ៣,៣% ប្រាក់យ៉េនជប៉ុន ១,៤% ប្រាក់ដុល្លារអូស្ត្រាលី ០,៦% និងប្រាក់រីងហ្គីតម៉ាឡេស៊ី ០,២% ខណៈដែលពុំមានការប្រែប្រួលធៀបនឹង ប្រាក់យ៉ន់ចិន និងប្រាក់បាតថៃ ។

ក្រាហ្វ ៦ : **ការវិវត្តន៍នៃតម្លៃប្រាក់រៀលធៀបនឹងរូបិយប័ណ្ណមួយចំនួន**

**(សន្ទស្សន៍: ចុងខែធ្នូ ២០១១ = ១០០)**




### *១.២.៣- ស្ថានភាពអត្រាប្តូរប្រាក់ដុល្លារអាមេរិកធៀបនឹងរូបិយប័ណ្ណមួយចំនួន*

ការប្រៀបធៀបអត្រាប្តូរប្រាក់ដុល្លារអាមេរិកជាមួយនឹងរូបិយប័ណ្ណនៃប្រទេសដៃគូពាណិជ្ជកម្មរបស់កម្ពុជាក្នុងឆមាសទី១ ឆ្នាំ២០១២នេះ បានបង្ហាញថា ប្រាក់ដុល្លារអាមេរិកបានចុះថ្លៃធៀបនឹង ប្រាក់ប៉េសូហ្វីលីពីន ៣,៤% ប្រាក់ដុល្លារតៃវ៉ាន់ ១,៥% ប្រាក់ដុល្លារសិង្ហបុរី ១,៤% ប្រាក់ដុងវៀតណាម ០,៥% និងប្រាក់ដុល្លារហុងកុង ០,២% ។ ទន្ទឹមនឹងនោះ ប្រាក់ដុល្លារអាមេរិកបានឡើងថ្លៃធៀបនឹង ប្រាក់រូពីឥណ្ឌូនេស៊ី ៤,៧% ប្រាក់អឺរ៉ូ ៤,១% ប្រាក់យ៉េនជប៉ុន ២,១% ប្រាក់ដុល្លារអូស្ត្រាលី ១,២% ប្រាក់រីងហ្គីតម៉ាឡេស៊ី ០,៨% ប្រាក់យ៉ន់ចិន ០,៦% ប្រាក់បាតថៃ ០,៤% និងប្រាក់វុនកូរ៉េ ០,២% ។

ក្រាហ្វ ៧ : **ការវិវត្តន៍នៃតម្លៃប្រាក់ដុល្លារអាមេរិកធៀបនឹងរូបិយប័ណ្ណមួយចំនួន**

**(សន្ទស្សន៍: ចុងខែធ្នូ ២០១១ = ១០០)**




## ២- ការវិវត្តន៍រូបិយវត្ថុ

សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០១២នេះ ត្រូវបានរំពឹងថានឹងបន្តមានអត្រាកំណើនប្រហាក់ប្រហែលឆ្នាំមុន ដែលគាំទ្រដោយវិស័យកសិកម្ម ឧស្សាហកម្ម និងសេវា ព្រមទាំងវិស័យហិរញ្ញវត្ថុផងដែរ ។ ជាក់ស្តែង បរិមាណឥណទានចំពោះវិស័យឯកជន និងរូបិយវត្ថុទូទៅ (M2) បានបន្តកើនឡើងគួរឲ្យកត់សម្គាល់ ។

លើសពីនេះទៀត ទ្រព្យសកម្មបរទេសសុទ្ធ និងដើមទុនរបស់ប្រព័ន្ធធនាគារនៅតែបន្តរក្សាកំណើនល្អប្រសើរ ។ ការណ៍នេះ បានឆ្លុះបញ្ចាំងពីជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារ ។

### ២.១- ការផ្គត់ផ្គង់រូបិយវត្ថុ

ក្នុងអំឡុងឆមាសទី១នេះ រូបិយវត្ថុទូទៅ (M2) របស់ប្រព័ន្ធធនាគារបានកើនឡើងចំនួន ២.៩៩៧ពាន់លានរៀល (១២,៧%) ពោលគឺកើនពី ២៣.៦៥៥ ពាន់លានរៀល នៅខែធ្នូ ឆ្នាំ២០១១ ទៅ ២៦.៦៥២ ពាន់លានរៀល នៅខែមិថុនា ឆ្នាំ២០១២ ។ ការកើនឡើងនេះជាចម្បងបណ្តាលមកពី កំណើននៃប្រាក់បញ្ញើជារូបិយប័ណ្ណរបស់និវាសជន ៣.០១៣ ពាន់លានរៀល (១៥,៧%) ប្រាក់បញ្ញើជារៀល ១២៤ ពាន់លានរៀល (១៦,៧%) ខណៈដែលរូបិយវត្ថុក្នុងចរាចរណ៍ថយចុះចំនួន ១៤០ ពាន់លានរៀល (៣,៧%) ។ គួរកត់សម្គាល់ផងដែរថា នៅក្នុងប្រាក់បញ្ញើជារូបិយប័ណ្ណសរុបមាន ៤៤% ជាប្រាក់បញ្ញើមានកាលកំណត់ ៣៣% ជាប្រាក់បញ្ញើសន្សំ ១៨% ជាប្រាក់បញ្ញើចរន្ត និង ៥% ជាប្រាក់បញ្ញើផ្សេងៗ ។ ប្រាក់បញ្ញើជារូបិយប័ណ្ណមានការកើនឡើងជារៀងរាល់ខែក្នុងអំឡុងឆមាសទី១ នេះ ។

ក្រាហ្វ ៨ : **សមាសធាតុនៃការផ្គត់ផ្គង់រូបិយវត្ថុ**




**តារាង ២ : បម្រែបម្រួលជាភាគរយនៃស្ថិតិរូបិយវត្ថុសំខាន់ៗនិងសន្ទស្សន៍ថ្លៃទំនិញនិងសេវា**

(បម្រែបម្រួលឆ្នាំលើឆ្នាំជាភាគរយ)

| | មករា-១២ | កុម្ភៈ-១២ | មីនា-១២ | មេសា-១២ | ឧសភា-១២ | មិថុនា-១២ |
|---|---|---|---|---|---|---|
| ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល | ២,៨ | ០,៨ | -១២,៩ | -៤,០ | ២,២ | -៩,៩ |
| ឥណទានផ្នែកឯកជន | ៣៥,៦ | ៣៤,៦ | ៣៥,១ | ៣៥,៦ | ៣៣,៩ | ៣១,៣ |
| រូបិយវត្ថុទូទៅ (M2) | ២២,៧ | ២៤,៧ | ២២,៦ | ២០,២ | ២០,១ | ២១,១ |
| រូបិយវត្ថុក្នុងចរាចរណ៍ | ២១,៨ | ១៨,៦ | ១៣,៩ | ៧,៣ | ១២,២ | ៨,៨ |
| អតិផរណាប្រចាំឆ្នាំ | ៥,៨ | ៥,៤ | ៥,៤ | ៤,៨ | ២,២ | ១,៨ |

### ២.២- ករត្តាជះឥទ្ធិពលដល់បរិមាណរូបិយវត្ថុ

ក្នុងឆមាសទី១ ឆ្នាំ២០១២ រូបិយវត្ថុទូទៅមានកំណើន ២១,១% ធៀបនឹង ១៣% នៅឆមាសទី១ និង ៧,៥% នៅឆមាសទី២ ឆ្នាំ២០១១ ។ ការកើនឡើងនេះ ឆ្លុះបញ្ចាំងតាមរយៈកំណើននៃទ្រព្យសកម្មបរទេសសុទ្ធរបស់ប្រព័ន្ធធនាគារចំនួន ៨៣៦ ពាន់លានរៀល (៤,៧%) និងទ្រព្យសកម្មក្នុងស្រុកសុទ្ធ ២.១៦២ ពាន់លានរៀល (៣៧,៥%) ។ ការកើនឡើងនៃទ្រព្យសកម្មបរទេសសុទ្ធនេះបណ្តាលមកពីកំណើននៃទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជាចំនួន ១.៦៦៥ ពាន់លានរៀល (១០,៤%) ខណៈដែលទ្រព្យសកម្មបរទេសសុទ្ធរបស់គ្រឹះស្ថានធនាគារថយចុះ ៨២៩ ពាន់លានរៀល (៤៤%) ។ ចំណែកឯការវិវឌ្ឍនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធវិញ បណ្តាលមកពីការកើនឡើងនៃឥណទានចំពោះវិស័យឯកជន[៣] ២.៥២៩ ពាន់លានរៀល (១៤,៤%) ខណៈដែលដើមទុននិងទុនបម្រុងរបស់ប្រព័ន្ធធនាគារកើនឡើង ១.៣២៤ ពាន់លានរៀល (១៣,៦%) និងឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលថយចុះ ២៧៧ ពាន់លានរៀល (១៣%) ។ នៅក្នុងលំហូរឥណទានចំពោះវិស័យឯកជនសរុប វិស័យដែលរួមចំណែកធំជាងគេមានឥណទានចំពោះវិស័យជួញដូរដុំនិងរាយ ៣៣% សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗទៀត ១៨% កសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ១៨% កម្មន្តសាល ១១% និង សំណង់និងការជួញដូរអចលនទ្រព្យ ៧% ។



ក្រាហ្វ ៩ : ស្ថានភាពរូបិយវត្ថុ

#### *២.២.១- ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា*

ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ធនាគារជាតិនៃកម្ពុជាបានថយចុះចំនួន ១៤៦ ពាន់លានរៀល (២,៩%) ពោលគឺថយចុះពី -៤.៩៧៧ ពាន់លានរៀល ក្នុងខែធ្នូ ឆ្នាំ២០១១ មក -៥.១២៣ ពាន់លានរៀល ក្នុងខែមិថុនា ឆ្នាំ២០១២ បន្ទាប់ពីបានកើនឡើង ៣៣២ ពាន់លានរៀល (៦,៣%) ក្នុងឆមាសទី២ ឆ្នាំ២០១១ ។ ការថយចុះនេះ បណ្តាលមកពីការថយចុះនៃឥណទេយ្យសុទ្ធពីគ្រឹះស្ថានធនាគារ ៤៦ ពាន់លាន

[៣] ឥណទានដុល=ឥណទានសរុប+ការប្រាក់បង្គរ

រៀល (៨%) និងឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាល ១៦៣ ពាន់លានរៀល (៩,១%) ខណៈដែលខ្ទង់ផ្សេងៗសុទ្ធកើនឡើងតិចតួចចំនួន ៦២ ពាន់លានរៀល (២,៤%) ។ ការថយចុះនៃឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាល ជារួមបណ្តាលមកពីកំណើននៃប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាល ។

ចំណែកឯទ្រព្យសកម្មបរទេសសុទ្ធវិញ បានកើនឡើងចំនួន ១.៦៦៥ ពាន់លានរៀល (១០,៤%) ។ ការវិវឌ្ឍនេះបណ្តាលមកពីកំណើននៃទ្រព្យសកម្មបរទេស ១.៦៦៣ ពាន់លានរៀល (១០,១%) គួបផ្សំនិងការថយចុះនៃទ្រព្យអកម្មបរទេស ២ ពាន់លានរៀល (០,៥%) ។

### ២.២.២- *ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់គ្រឹះស្ថានធនាគារ*

ទ្រព្យសកម្មសរុបរបស់គ្រឹះស្ថានធនាគារមានចំនួន ៣៩.៩០៨ ពាន់លានរៀល ពោលគឺកើន ៧.៦៩៣ ពាន់លានរៀល (២៣,៩%) ដែលជួយទ្រទ្រង់ដល់កំណើនឥណទានរបស់ធនាគារ និងរួមចំណែកដល់ការធ្វើហិរញ្ញប្បទានសកម្មភាពវិនិយោគនៅក្នុងប្រទេស ។កំណើននេះ ឆ្លុះបញ្ចាំងមួយផ្នែកតាមរយៈដើមទុនរបស់គ្រឹះស្ថានធនាគារដែលបើកថ្មី ការបង្កើនដើមទុនរបស់ធនាគារដែលមានស្រាប់ និងការកើនឡើងប្រាក់បញ្ញើរបស់អតិថិជន ។ ប្រាក់បញ្ញើសរុបមានចំនួន ២២.៩៥៦ ពាន់លានរៀល កើនឡើង ៣.១២៦ ពាន់លានរៀល (១៥,៨%) ដែលក្នុងនោះប្រាក់បញ្ញើជារូបិយប័ណ្ណមានសមាមាត្រ ៩៦% នៃប្រាក់បញ្ញើសរុប ។

ទ្រព្យសកម្មក្នុងស្រុកសុទ្ធបានកើនឡើងចំនួន ១.៨៨២ ពាន់លានរៀល (១៧,៦%) ។ ការប្រែប្រួលនេះ ជាចម្បងបណ្តាលមកពីការកើនឡើងនៃឥណទានចំពោះវិស័យឯកជន ២.៥២៩ ពាន់លានរៀល (១៤,៤%) ខណៈដែលមានការថយចុះនៃខ្ទង់ផ្សេងៗសុទ្ធ ៤៩៦ ពាន់លានរៀល (៧,៦%) និងឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាល ១១៤ ពាន់លានរៀល (៣៣,៦%) ។ ការថយចុះនៃខ្ទង់ផ្សេងៗសុទ្ធជាលទ្ធផលពីការកើនឡើងនៃដើមទុន ១.៣៧០ ពាន់លានរៀល (២១,៣%) និងបំណុលអន្តរធនាគារ ១.០៧០ ពាន់លានរៀល (៧៩,២%) ខណៈដែលទ្រព្យសកម្មផ្សេងៗកើនឡើង ១.៩៣៨ ពាន់លានរៀល (៥៩,៥%) ។ ទន្ទឹមនេះដែរ ប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារនៅធនាគារជាតិនៃកម្ពុជា ដែលជាធាតុផ្សំនៃទុនបម្រុងអន្តរជាតិ បានកើនឡើង ១.៩៨៣ ពាន់លានរៀល (២៨,១%) ។

ទ្រព្យសកម្មបរទេសសុទ្ធរបស់គ្រឹះស្ថានធនាគារបានថយចុះចំនួន ៨២៩ ពាន់លានរៀល (៤៤%) គឺពី ១.៨៨៤ ពាន់លានរៀល នាដំណាច់ឆ្នាំ២០១១ មក ១.០៥៥ ពាន់លានរៀល នាឆមាសទី១ ឆ្នាំ ២០១២ ។ ការថយចុះនេះ បណ្តាលមកពីកំណើនទ្រព្យអកម្មបរទេសចំនួន ១.៩៧៨ ពាន់លានរៀល (៨៦,១%) ខ្ពស់ជាងកំណើនទ្រព្យសកម្មបរទេសដែលមានចំនួន ១.១៤៩ ពាន់លានរៀល (២៧,៥%) ។

## ២.៣- អត្រាការប្រាក់លើប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់គ្រឹះស្ថានធនាគារ

ចលនាអត្រាការប្រាក់បញ្ញើរយៈពេល៦ខែ[៤] របស់គ្រឹះស្ថានធនាគារមាននិន្នាការថយចុះបន្តិច ចាប់តាំងពីដើមឆ្នាំមក ។ អត្រាការប្រាក់បញ្ញើជារៀលបានថយចុះចំនួន ០,៤៣% ពោលគឺថយពី ៥,២៨% ក្នុងខែធ្នូ ឆ្នាំ២០១១ មក ៤,៨៥% នាខែមិថុនា ឆ្នាំ២០១២ ។ ចំណែកឯអត្រាការប្រាក់បញ្ញើជាដុល្លារអាមេរិក

[៤] អត្រាការប្រាក់វាស់ដោយកម្រិតមធ្យមថ្លឹងតាមទំហំនៃប្រតិបត្តិការធនាគារ

មានកម្រិត ៣,៤១% គឺបានថយចុះតិចតួច ០,០២% ធៀបនឹងខែធ្នូ ឆ្នាំ២០១១ ។

ទន្ទឹមនឹងនោះ អត្រាការប្រាក់កម្ចីជារៀលរយៈពេល៦ខែ បានថយចុះពី ១៦,៩៩% នាខែធ្នូ ឆ្នាំ២០១១ មក ១១,៧៣% នាខែមិថុនា ឆ្នាំ២០១២ ពោលគឺថយចុះ ៥,២៦% ។ ចំណែកឯ អត្រាការប្រាក់កម្ចីជាដុល្លារអាមេរិកមានកម្រិត ១២,១៣% បានថយចុះចំនួន ៤,២៥% ធៀបនឹងខែធ្នូ ឆ្នាំ២០១១ ។




ក្នុងអំឡុងឆមាសទី១ ឆ្នាំ២០១២នេះ គម្លាតអត្រាការប្រាក់ជារៀលបានថយចុះពី ១១,៧១% នាខែធ្នូ ឆ្នាំ២០១១ មក ៦,៨៨% នៅខែមិថុនា ឆ្នាំ២០១២ ។ ចំណែកឯគម្លាតអត្រាការប្រាក់ជាដុល្លារអាមេរិក បានថយចុះពី ១២,៩៥% នាខែធ្នូ ឆ្នាំ២០១១ មក ៨,៧២% នៅខែមិថុនា ឆ្នាំ២០១២ ។

**តារាង ៣ : អត្រាការប្រាក់លើប្រាក់កម្ចី និងប្រាក់បញ្ញើ ( អត្រាមធ្យម៦ខែ - ជាភាគរយ )**

| | មិថុនា ២០១១ | ធ្នូ ២០១១ | មករា ២០១២ | កុម្ភៈ ២០១២ | មីនា ២០១២ | មេសា ២០១២ | ឧសភា ២០១២ | មិថុនា ២០១២ |
|---|---|---|---|---|---|---|---|---|
| អត្រាការប្រាក់បញ្ញើជារៀល | ៥,៤២ | ៥,២៨ | ៥,២៩ | ៥,២៣ | ៥,០៣ | ៥,០៩ | ៥,០៧ | ៤,៨៥ |
| អត្រាការប្រាក់កម្ចីជារៀល | ១៤,៨០ | ១៦,៩៩ | ១៦,៩៦ | ១៧,៦៧ | ១៧,៦៧ | ១៣,២៥ | ១១,៦៧ | ១១,៧៣ |
| គម្លាត | ៩,៣៨ | ១១,៧១ | ១១,៦៧ | ១២,៤៤ | ១២,៦៤ | ៨,១៦ | ៦,៦០ | ៦,៨៨ |
| | | | | | | | | |
| អត្រាការប្រាក់បញ្ញើជាដុល្លារ | ៣,៤៤ | ៣,៤៣ | ៣,៤៣ | ៣,៤២ | ៣,៤២ | ៣,៤៣ | ៣,៤៣ | ៣,៤១ |
| អត្រាការប្រាក់កម្ចីជាដុល្លារ | ១៥,៣៧ | ១៦,៣៨ | ១៣,៨៦ | ១៤,០០ | ១៤,០៦ | ១២,៦៤ | ១១,៩៨ | ១២,១៣ |
| គម្លាត | ១១,៩៣ | ១២,៩៥ | ១០,៤០ | ១០,៥៨ | ១០,៦៤ | ៩,២១ | ៨,៥៥ | ៨,៧២ |

## ៣- ជញ្ជីងទូទាត់

ទិន្នន័យបឋមនៃស្ថានដំបូងនៃប្រតិបត្តិការជញ្ជីងទូទាត់កម្ពុជាបានបង្ហាញថា សមតុល្យរួមមានអតិរេក ចំនួន ២០២ លានដុល្លារអាមេរិក ដោយបានថយចុះ ៣ លានដុល្លារអាមេរិក (១,៣%) ធៀបនឹងឆមាសទី១ ឆ្នាំ២០១១ ។ កត្តាចម្បងដែលបណ្តាលឲ្យមានការថយចុះនេះគឺ ការថយចុះសមតុល្យគណនីហិរញ្ញវត្ថុ ប្រមាណ ១១៥ លានដុល្លារអាមេរិក (២០,៥%) និងសមតុល្យគណនីចរន្ត ២៤២ លានដុល្លារអាមេរិក (៣២,៧%) ។ ផលធៀបរវាងឱនភាពសមតុល្យគណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) និងផ.ស.ស មាន កម្រិត ៦,៩% ។

### ៣.១- គណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ)

សមតុល្យគណនីចរន្តមានឱនភាពប្រមាណ ៤៩៩ លានដុល្លារអាមេរិក បានថយចុះ ២៤២ លាន ដុល្លារអាមេរិក (៣២,៧%) ធៀបនឹងឆមាសទី១ ឆ្នាំ២០១១ ដោយសារការថយចុះនៃឱនភាពជញ្ជីងពាណិជ្ជកម្ម ១១ លានដុល្លារអាមេរិក និងឱនភាពគណនីប្រាក់ចំណូលសុទ្ធ ៨ លានដុល្លារអាមេរិក ព្រមទាំងកំណើន អតិរេកនៃគណនីសេវាសុទ្ធ ២២៧ លានដុល្លារអាមរិក (៦៦,៤%) ។ ឱនភាពគណនីចរន្តនេះ ត្រូវបានផាត់ទាត់ ដោយការថយចុះនៃគណនីបង្វែរឯកជនសុទ្ធ ៤ លានដុល្លារអាមេរិក (៤,៤%) ។

ការនាំចេញសរុបមានចំនួនប្រមាណ ២.៨៦៥ លានដុល្លារអាមេរិក បានកើនឡើង ៤២៤ លាន ដុល្លារអាមេរិក (១៧,៤%) ធៀបនឹងឆមាសទី១នៃឆ្នាំកន្លងទៅ ។ កត្តារួមចំណែកយ៉ាងសំខាន់ក្នុងការកើន ឡើងនេះគឺការនាំចេញតាមប្រព័ន្ធអនុគ្រោះពន្ធទូទៅ (GSP) ដែលបានកើនឡើងប្រមាណ ៣៩៩ លាន ដុល្លារអាមេរិក (១៨,៥%) ។ បើធៀបនឹងឆមាសទី១ដូចគ្នា ការនាំចេញតាមប្រព័ន្ធអនុគ្រោះពន្ធទូទៅបាន បន្តកើនឡើងជាលំដាប់គឺមាន ១.៤៧៦ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១០ ២.១៥៣ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១១ និង ២.៥៥២ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១២ ។ ស្របពេលនេះដែរ ការនាំចេញផ្សេង ទៀតមានកំណើនប្រមាណ ១៣,៥% ។

ក្រាហ្វ ១១: **ជញ្ជីងពាណិជ្ជកម្ម**



ការនាំចូលទំនិញសម្រាប់ប្រើប្រាស់ក្នុងស្រុកមាន ៣.៦០៧ លានដុល្លារអាមេរិក បានកើនឡើង ៤០៩ លានដុល្លារអាមេរិក (១២,៨%) ធៀបនឹងឆមាសទី១នៃឆ្នាំកន្លងទៅ ។ កំណើននេះបណ្តាលមកពីការកើនឡើងនៃការនាំចូលវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ ១៦០ លានដុល្លារអាមេរិក (១៩,៧%) ប្រេងឥន្ធនៈ ៧៣ លានដុល្លារអាមេរិក (១៥,៥%) ទំនិញសម្រាប់ប្រើប្រាស់ក្នុងស្រុកផ្សេងទៀត ១៧២ លានដុល្លារអាមេរិក (៩,២%) និងអគ្គិសនី ៥ លានដុល្លារអាមេរិក (៧,៧%) ។

គណនីសេវាសុទ្ធមានអតិរេក ៥៦៩ លានដុល្លារអាមេរិក បានកើនឡើង ២២៧ លានដុល្លារអាមេរិក (៦៦,៤%) ធៀបនឹងឆមាសទី១ ឆ្នាំ២០១១ ។ ការកើនឡើងនៃអតិរេកនេះ ជាលទ្ធផលនៃកំណើនប្រាក់ចំណូលពីផ្នែកសេវា បន្ទាប់ពីផាត់ទាត់ការចំណាយលើផ្នែកសេវាដែលផ្តល់ដោយអនិវាសជន ។ ចំណូលពីសេវាទេសចរណ៍មាន ៨៧១ លានដុល្លារអាមេរិក បានកើនឡើង ១៨៦ លានដុល្លារអាមេរិក (២៧,១%) និងចំណូលពីសេវាដឹកជញ្ជូនបានកើនឡើង ៩ លានដុល្លារអាមេរិក (៦,៧%) ដែលជាប្រភពដ៏សំខាន់ បណ្តាលឲ្យប្រាក់ចំណូលផ្នែកសេវាមានការកើនឡើង ។

គណនីប្រាក់ចំណូលសុទ្ធមានឱនភាពប្រមាណ ៣០១ លានដុល្លារអាមេរិក បានថយចុះ ៨ លានដុល្លារអាមេរិក (២,៧%) ធៀបនឹងឆមាសទី១ ឆ្នាំ២០១១ ។ ការថយចុះឱនភាពនេះបណ្តាលមកពីការថយចុះការផ្ទេរប្រាក់ចេញទៅឱ្យអនិវាសជន ១០ លានដុល្លារអាមេរិក (២,៨%) ។ គណនីបង្វែរឯកជនសុទ្ធមានអតិរេកប្រមាណ ៩១ លានដុល្លារអាមេរិក បានថយចុះ ៤ លានដុល្លារអាមេរិក (៤,៤%) ធៀបនឹងឆមាសដូចគ្នានៃឆ្នាំកន្លងទៅ ។

### ៣.២- គណនីបង្វែរផ្លូវការ និងហិរញ្ញវត្ថុ

បង្វែរផ្លូវការសុទ្ធក្រោមរូបភាពជាហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណងមានប្រមាណ ៣០១ លានដុល្លារអាមេរិក បានថយចុះ ៣១ លានដុល្លារអាមេរិក (៩,៥%) ធៀបនឹងឆមាសទី១ ឆ្នាំ២០១១ ។ គណនីហិរញ្ញវត្ថុបានបង្ហាញថាមានអតិរេក ៤៤៦ លានដុល្លារអាមេរិក បានថយចុះ ២០,៥% ដែលឆ្លុះបញ្ចាំងពីលំហូរកម្ចីផ្លូវការ និងវិនិយោគឯកជន ។ ប្រាក់កម្ចីផ្លូវការសុទ្ធមាន ១១៧ លានដុល្លារអាមេរិក បានកើនឡើង ៤ លានដុល្លារអាមេរិក (៣,៣%) ធៀបនឹងឆមាសទី១នៃឆ្នាំមុន ។ ចំណែកលំហូរវិនិយោគឯកជនត្រូវបានឆ្លុះបញ្ចាំងជាចម្បងពីលំហូរវិនិយោគផ្ទាល់បរទេសសុទ្ធ ដែលមានចំនួន ៤៤៤ លានដុល្លារអាមេរិក បានកើនឡើង ១១០ លានដុល្លារអាមេរិក (៣២,៨%) ធៀបនឹងឆមាសទី១ នៃឆ្នាំកន្លងទៅ ដែលបង្ហាញពីបរិយាកាសប្រសើរឡើងវិញនៃលំហូរវិនិយោគបរទេសនៅកម្ពុជា ។

ក្រាហ្វ១២: **ជញ្ជីងទូទាត់កម្ពុជា**




ក្នុងអំឡុងឆមាសទី១ ឆ្នាំ២០១២ នេះ ប្រតិបត្តិការជញ្ជីងទូទាត់ បានបង្ហាញពីលទ្ធភាពគ្រប់គ្រាន់សម្រាប់ផាត់ទាត់ឲ្យឱនភាពគណនីចរន្ត ទោះបីមានការថយចុះលំហូរចូលនៃគណនីបង្វែរផ្លូវការ និងគណនីហិរញ្ញវត្ថុក៏ដោយ ។ ជាលទ្ធផល សមតុល្យរួមនៃប្រតិបត្តិការជញ្ជីងទូទាត់មានអតិរេក ២០២ លានដុល្លារអាមេរិក ។ គិតដល់ចុងខែមិថុនា ទុនបម្រុងអន្តរជាតិដុលអាចទ្រទ្រង់ និងទូទាត់ការនាំចូលទំនិញនិងសេវាបានប្រមាណ ៤,៥ ខែ ។

## ៤- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

### ៤.១- ការងារវិនិយោគទុនបម្រុងអន្តរជាតិ

ធនាគារជាតិនៃកម្ពុជាវិនិយោគទុនបម្រុងអន្តរជាតិក្រោមរូបភាពអូវើណាយ ប័ណ្ណរតនាគារអាមេរិក ឧបករណ៍ហិរញ្ញវត្ថុរយៈកាលមធ្យម (MTI) សញ្ញាប័ណ្ណរយៈពេលវែង និងប្រាក់បញ្ញើរយៈកាលខ្លីជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ធនាគារកណ្តាលនៃប្រទេសអភិវឌ្ឍន៍ និងគ្រឹះស្ថានធនាគារពាណិជ្ជដែលមានស្តង់ដារ និងក្រេឌីតរ៉េតទីងខ្ពស់ ។ ទន្ទឹមនេះ ទុនបម្រុងអន្តរជាតិមួយចំនួនក៏ត្រូវបានវិនិយោគតាមរយៈអ្នកចាត់ការខាងក្រៅផងដែរ ។

នៅក្នុងឆមាសទី១ ឆ្នាំ២០១២ អត្រាការប្រាក់គោលប្រាក់ដុល្លារអាមេរិកត្រូវបានរក្សានៅត្រឹម ០,២៥% អត្រាការប្រាក់គោលប្រាក់អឺរ៉ូ ១% និងអត្រាការប្រាក់គោលប្រាក់ផោនស្ទែរលីង ០,៥% ។ ដោយឡែក អត្រាការប្រាក់គោលប្រាក់ដុល្លារអូស្ត្រាលីត្រូវបានកាត់បន្ថយចំនួន ២ដង ចំនួន ៧៥ពិន្ទុ ពី ៤,២៥% មកត្រឹម ៣,៥០% ហើយអាចនឹងត្រូវបានកាត់បន្ថយថែមទៀតនៅក្នុងឆមាសទី២ ឆ្នាំ២០១២ ដើម្បីទប់ទល់នឹងការធ្លាក់ចុះនៃអត្រាអតិផរណា ។

ក្នុងបរិការណ៍នេះ អនុលោមតាមសេចក្តីណែនាំស្តីពីការវិនិយោគដែលកំណត់ដោយគណៈកម្មការវិនិយោគធនាគារជាតិនៃកម្ពុជា ការវិនិយោគទុនបម្រុងអន្តរជាតិ ត្រូវបានអនុវត្តដោយផ្អែកលើគោលការណ៍សុវត្ថិភាព និងសន្ទនីយភាពជាប់ជាប្រចាំ ។ ធនាគារជាតិនៃកម្ពុជាបានចល័តទុនបម្រុងទៅវិនិយោគជាមួយ

ដៃគូដែលមានរេ៉តទីងខ្ពស់ និងផ្តល់ចំណូលការប្រាក់សមស្រប និងបានបង្កើនការវិនិយោគទៅលើសញ្ញាប័ណ្ណផ្សេងៗ ។ បច្ចុប្បន្ន ទុនបម្រុងអន្តរជាតិសរុបដែលបានវិនិយោគគិតជាប្រាក់ដុល្លារអាមេរិក[៣] មានចំនួន ៣.៤៥០ លានដុល្លារអាមេរិក កើនឡើង ៧,៤% ធៀបនឹងចុងខែធ្នូ ឆ្នាំ២០១១ (៣.២១៣ លានដុល្លារអាមេរិក) ។

**៤.២. អន្តរាគមន៍ទៅលើទីផ្សារប្តូរប្រាក់**

ធនាគារជាតិនៃកម្ពុជាបានអន្តរាគមទិញប្រាក់ដុល្លារអាមេរិកចំនួន ១៧ លើក ដែលមានទឹកប្រាក់សរុបចំនួន ៨៤,៥ លានដុល្លារអាមេរិក និងបានចំណាយប្រាក់រៀលចំនួន ៣៣៨,៧ ពាន់លានរៀល ។

**៤.៣. ការគ្រប់គ្រងអាជីវកម្មមាស និងប្តូរប្រាក់**

ក្រុមហ៊ុននាំចេញ-នាំចូលមាសចំនួនពីរបានបញ្ឈប់សកម្មភាព ។ បច្ចុប្បន្ន អាជ្ញាប័ណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូលមាសមានចំនួន ១៦ ច្បាប់ ។ នៅក្នុងឆមាសទី១ ឆ្នាំ២០១២ ការនាំចូលមាសមានចំនួន ៣៩២ គីឡូក្រាម ។

**៥- សម្ព័ន្ធការជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ**

បច្ចុប្បន្ន ប្រព័ន្ធធនាគារនៅកម្ពុជាមានធនាគារពាណិជ្ជចំនួន ៣២ ធនាគារឯកទេស ៧ ការិយាល័យតំណាងធនាគារបរទេស ៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៣២ (ក្នុងនោះមានគ្រឹះស្ថាន ៧ ត្រូវបានអនុញ្ញាតឲ្យទទួលប្រាក់បញ្ញើពីសាធារណជន) ប្រតិបត្តិករឥណទានជនបទដែលបានចុះបញ្ជីចំនួន ៣០ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ១ តតិយភាគី ១ ការិយាល័យព័ត៌មានឥណទាន ១ និងមានអាជីវកម្មប្តូរប្រាក់ ១.៥១២ (ក្នុងនោះ មានអាជ្ញាប័ណ្ណចំនួន ៤៧) ។

បណ្តាញសាខា និងប្រតិបត្តិករនៅក្នុងប្រព័ន្ធធនាគារមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់នាពេលបច្ចុប្បន្ននេះ ។ ជាក់ស្តែង ការរីកចម្រើននៃគ្រឹះស្ថានធនាគារអាចឆ្លុះបញ្ចាំងតាមរយៈអ្នកដាក់ប្រាក់បញ្ញើ បានកើនឡើងដល់ ១.៣៦៨.៦៣១ នាក់ និងអ្នកទទួលឥណទានបានកើនដល់ ៣២១.២៩៦ នាក់ ។ ផលិតផលហិរញ្ញវត្ថុនៅក្នុងវិស័យធនាគារមានការរីកលូតលាស់ជាលំដាប់ដូចជា ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (មានចំនួន ៦១៣) ប័ណ្ណឥណទាន ប័ណ្ណឥណពន្ធ សេវាសន្សំជាមាស សេវាធនាគារអេឡិចត្រូនិក (E-Banking) និងប្រតិបត្តិការធនាគារចល័ត ជាដើម ។

អនុបាតសាធនភាពជាមធ្យមមាន ២៨,៦% ខ្ពស់ជាងកម្រិតអប្បបរមា១៥% ហើយអនុបាតសាច់ប្រាក់ងាយស្រួលមាន ៨៩,២% លើសពីកម្រិតអប្បបរមា ៥០% ។ អនុបាតឥណទានមិនដំណើរការបានថយចុះពី ៣,២% នៅឆមាសទី១ ឆ្នាំ២០១១ មកត្រឹម ២,៤% ។ ជារួម គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានអនុវត្តនូវបទបញ្ជាប្រុងប្រយ័ត្នយ៉ាងខ្ជាប់ខ្ជួន ។

ទន្ទឹមនឹងនេះ ដើម្បីពង្រឹងគុណភាពទិន្នន័យ និងសម្រួលការងារឲ្យបានរហ័ស សុក្រិត្យ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ធនាគារជាតិនៃកម្ពុជាបានរៀបចំទម្រង់របាយការណ៍ហិរញ្ញវត្ថុថ្មី និងតម្រូវឲ្យគ្រប់

---

[៣] មិនរាប់បញ្ចូលមាសចំនួន១២.៤៣៦,០៧៩៥១គីឡូក្រាមនិងប្រាក់ SDR ចំនួន ៦៨,៤៦លានSDR ។

គ្រឹះស្ថានធនាគារផ្ញើរបាយការណ៍ហិរញ្ញវត្ថុតាមគ្រានីមួយៗរបស់ខ្លួន មកធនាគារជាតិនៃកម្ពុជាតាមរយៈប្រព័ន្ធអ៊ិនធឺណែត ។

### ៥.១. ការត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

#### ៥.១.១. ការត្រួតពិនិត្យលើឯកសារ

ស្របពេលដែលវិស័យធនាគារមានការរីកចម្រើនទាំងផ្នែកវិសាលភាព និងទំហំប្រតិបត្តិការ ការត្រួតពិនិត្យលើឯកសារត្រូវបានពង្រឹងជាប់ជាប្រចាំ ។ ជាក់ស្តែងក្នុងឆមាសទី១ នេះ បន្ទាប់ពីបានពិនិត្យពីភាពរឹងមាំតាមបទប្បញ្ញត្តិប្រុងប្រយ័ត្នរួចមក ធនាគារជាតិនៃកម្ពុជាបានអនុញ្ញាតឲ្យគ្រឹះស្ថានធនាគារបើកសាខាចំនួន ១១ កន្លែងនៅក្នុងប្រទេស និងការិយាល័យតំណាងនៅប្រទេសឡាវ និងមីយ៉ាន់ម៉ាផងដែរ ។ ទន្ទឹមនឹងនេះ សាខាធនាគារបរទេសមួយទៀតបានប្រែក្លាយខ្លួនមកជាធនាគារបុត្រសម្ព័ន្ធក្នុងស្រុក ដោយបន្ថែមដើមទុន ដើម្បីពង្រីកប្រតិបត្តិការស្របតាមផែនការយុទ្ធសាស្ត្ររបស់ខ្លួន។

ចំពោះការងារត្រួតពិនិត្យគ្រឹះស្ថានធនាគារ ធនាគារជាតិនៃកម្ពុជាបានបន្តការតាមដាន និងវិភាគជាប់ជាប្រចាំលើរបាយការណ៍ហិរញ្ញវត្ថុតាមវិធីសាស្ត្រ COBRA ដើម្បីពិនិត្យពីភាពរឹងមាំ ស្ថានភាពហិរញ្ញវត្ថុ និងការអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិ ក្នុងគោលបំណងរកឲ្យឃើញកំហុសឆ្គងនិងភាពមិនប្រក្រតី សំដៅចាត់វិធានការជួយដោះស្រាយឲ្យទាន់ពេលវេលា ។ ជាលទ្ធផល ស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារ និងការអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិមានភាពល្អប្រសើរ ។ ជាមួយគ្នានេះដែរ ធនាគារជាតិនៃកម្ពុជាកំពុងអភិវឌ្ឍប្រព័ន្ធវិភាគរបាយការណ៍ COBRA ទៅជាប្រព័ន្ធថ្មីមួយដែលមានឈ្មោះថា "ប្រព័ន្ធត្រួតពិនិត្យលើឯកសារ (Off-Site Surveillance System)" ។ ប្រព័ន្ធនេះ ជាប្រព័ន្ធត្រួតពិនិត្យផ្អែកលើហានិភ័យដែលមានធាតុសំខាន់ៗ ដូចជា ទិន្នន័យហិរញ្ញវត្ថុ ការវិភាគពីស្ថានភាពហិរញ្ញវត្ថុនិងហានិភ័យ សាវតាធនាគារ និងវឌ្ឍនភាពនៃសកម្មភាពកែតម្រូវបន្ទាន់ ។

#### ៥.១.២. ការងារត្រួតពិនិត្យដល់ទីកន្លែង

ធនាគារជាតិនៃកម្ពុជាបានធ្វើការត្រួតពិនិត្យដល់ទីកន្លែងចំពោះធនាគារពាណិជ្ជចំនួន ១១ ធនាគារឯកទេស ២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៥ និងប្រតិបត្តិករឥណទានជនបទ ៣ ។

លទ្ធផលនៃការត្រួតពិនិត្យដល់ទីកន្លែងបានបង្ហាញថា ស្ថានភាពហិរញ្ញវត្ថុ និងការអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានលក្ខណៈល្អប្រសើរ ។ ប៉ុន្តែ គ្រឹះស្ថានមួយចំនួនតូចនៅមានបញ្ហាប្រឈមទាក់ទងទៅនឹងការអនុវត្តតាមប្រកាសស្តីពី ការត្រួតពិនិត្យផ្ទៃក្នុង និងប្រកាសស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ ធនាគារជាតិនៃកម្ពុជាបានផ្តល់អនុសាសន៍ចំពោះគ្រឹះស្ថានសាមី ដើម្បីធ្វើការកែតម្រូវរាល់ចំណុចខ្វះចន្លោះ និងតាមដានរាល់ការអនុវត្តតាមអនុសាសន៍ ។ ជាលទ្ធផល គ្រឹះស្ថានសាមីបានខិតខំអនុវត្តតាមអនុសាសន៍ដែលបានផ្តល់ដោយធនាគារជាតិនៃកម្ពុជា ។

#### ៥.១.៣. ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាបន្តរីកចម្រើនលូតលាស់ជាលំដាប់ ក្រោមបរិយាកាសស្ថិរភាពនយោបាយ និងកំណើននៃជំនឿទុកចិត្តពីសាធារណជនទាំងវិនិយោគិនក្នុងស្រុក និងបរទេស ស្របពេលដែលផលិតផល

មីក្រូហិរញ្ញវត្ថុកាន់តែសំបូរបែប ។ សមតុល្យឥណទានសរុបមាន ២.៩៩២ ពាន់លានរៀល បានកើន ៤៥,១% ធៀបនឹងឆមាសទី១ ឆ្នាំ២០១១ ដោយបានផ្តល់ជូនអតិថិជនចំនួន ១.១៩៤.៥០៧ នាក់ ក្នុងនោះ ៨២% ជាស្រ្តីនៅតាមជនបទ ។ ក្នុងអំឡុងពេលនេះដែរ ប្រតិបត្តិករឥណទានជនបទមានចំនួន ២៩ ដែល បានផ្តល់ឥណទាន ៦៣,៥ ពាន់លានរៀល ដល់អតិថិជន ៣៤.១៥២ នាក់ ។

តាមរយៈការត្រួតពិនិត្យលើឯកសារ និងដល់ទីកន្លែងបានបង្ហាញថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានបន្តអនុវត្តយ៉ាងប្រុងប្រយ័ត្ន និងគោរពតាមច្បាប់ ប្រកាស និងបទប្បញ្ញត្តិនានា រួមទាំងប្រកាសដែលបានដាក់ឲ្យអនុវត្តនាពេលថ្មីៗនេះ ដូចជា ប្រកាស ស្តីពីការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្តីពីការចែករំលែកព័ត៌មានឥណទាន និងស្តីពីតម្លាភាពក្នុងការផ្តល់សេវាឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាដើម ។ ជាមួយគ្នានេះដែរ គ្រឹះស្ថានបានបន្តអនុវត្តការគ្រប់គ្រងហានិភ័យប្រតិបត្តិការយ៉ាងប្រុងប្រយ័ត្ន ជាពិសេសប្រតិបត្តិការឥណទាន ។ ជាលទ្ធផល គុណភាពឥណទានកាន់តែមានភាពប្រសើរឡើង ដែលឆ្លុះបញ្ចាំងតាមរយៈការថយចុះនៃអនុបាតឥណទានមិនដំណើរការពី ០,៨% នៅឆមាសទី១ ឆ្នាំ២០១១ មក ០,៣% ។ ទន្ទឹមនឹងនេះ ការកេណ្ឌប្រមូលប្រាក់សន្សំរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានកើន ឡើង ១៥៦ % និងប្រតិបត្តិករឥណទានជនបទ ៧២% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន ។

ដើម្បីបន្តពង្រឹង និងអភិវឌ្ឍវិស័យនេះ ធនាគារជាតិនៃកម្ពុជាបានធ្វើបច្ចុប្បន្នកម្ម និងដាក់ចេញនូវបទប្បញ្ញត្តិនានា សំដៅសម្រួលដល់ប្រតិបត្តិការអាជីវកម្មរបស់គ្រឹះស្ថាន ។ ជាក់ស្តែង ប្រកាសស្តីពីការអនុវត្តការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យនិងទស្សនៈឆ្ពោះទៅអនាគត ត្រូវបានដាក់ឲ្យអនុវត្តក្នុងគោលបំណង ប៉ាន់ប្រមាណជាមុននូវផលប៉ះពាល់អវិជ្ជមានជាយថាហេតុ និងចេញអធិបញ្ញាសមស្រប ដើម្បីដោះស្រាយឲ្យបានទាន់ពេលវេលា ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងប្រព័ន្ធត្រួតពិនិត្យទាំងការត្រួតពិនិត្យលើឯកសារ និងដល់ទីកន្លែង ដើម្បីរក្សានូវតម្លាភាពនៃប្រតិបត្តិការហិរញ្ញវត្ថុ និងការពារផលប្រយោជន៍សាធារណៈជន ។ ទន្ទឹមនោះ ប្រព័ន្ធព័ត៌មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (Microfinance Information System) ដែលជាប្រព័ន្ធរាយការណ៍អេឡិចត្រូនិក ត្រូវបានដាក់ឲ្យគ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអនុវត្តជាផ្លូវការ ចាប់ពីដើមឆ្នាំ ២០១២ ដើម្បីធានានូវប្រសិទ្ធភាពរបាយការណ៍ មានទម្រង់បទដ្ឋានតែមួយ ជួយកាត់បន្ថយទាំងថ្លៃចំណាយ និងពេលវេលារបស់គ្រឹះស្ថាន ។ ជាមួយគ្នានេះដែរ ធនាគារជាតិនៃកម្ពុជាបន្តអភិវឌ្ឍធនធានមនុស្សរបស់ខ្លួនលើការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយបានសហការជាមួយដៃគូអភិវឌ្ឍន៍នានា ជាពិសេស ធនាគារអភិវឌ្ឍន៍អាស៊ី ។

### ៥.២. ការងារនីតិកម្ម

ខណៈដែលវិស័យធនាគាររីកចម្រើនទាំងផ្នែកបណ្តាញសេវា និងផលិតផលហិរញ្ញវត្ថុ ជាពិសេសទីផ្សារហ៊ុនដែលទើបនឹងបង្កើតឡើង ធនាគារជាតិនៃកម្ពុជាបន្តពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិប្រុងប្រយ័ត្នដើម្បីឲ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រព្រឹត្តទៅដោយរលូន ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព ស្របតាមការរីកចម្រើននៃវិស័យហិរញ្ញវត្ថុ ។ ទន្ទឹមនេះ ក្របខ័ណ្ឌបទប្បញ្ញត្តិនៃការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីបុគ្គលិកត្រូវបានពង្រឹង ឲ្យស្របតាមការប្រែប្រួលនៃស្ថាបត្យកម្មហិរញ្ញវត្ថុអន្តរជាតិ អភិក្រមអន្តរជាតិ និងការអភិវឌ្ឍរីកចម្រើននៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា ។

ជាក់ស្តែង ថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវសៀវភៅ "កម្រងច្បាប់ និងបទប្បញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បច្ចុប្បន្នកម្មឆ្នាំ២០១១" សំដៅពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិប្រកបដោយភាពរលូន និងប្រសិទ្ធភាពខ្ពស់ ។

### ៥.៣. ការងារផ្តល់អាជ្ញាប័ណ្ណ និងជម្រះបញ្ជី

ធនាគារជាតិនៃកម្ពុជាបានផ្តល់អាជ្ញាប័ណ្ណជូនដល់ធនាគារពាណិជ្ជចំនួន ១ ចេញលិខិតអនុញ្ញាតថ្មីសម្រាប់ការិយាល័យតំណាងធនាគារបរទេសចំនួន ២ ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជីចំនួន ១ តតិយភាគីចំនួន ១ លិខិតអនុញ្ញាតអាជីវកម្មប្តូរប្រាក់ចំនួន ១១ និងបញ្ឈប់ប្តូរប្រាក់ឲ្យគ្រឹះស្ថានធនាគារចំនួន ១។

អនុវត្តតាមប្រកាសស្តីពីការចែករំលែកព័ត៌មានឥណទាន និងដើម្បីកាត់បន្ថយហានិភ័យឥណទាននៅក្នុងប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជាបានផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនក្រេឌីតប្បូរ៉ូ (ខេមបូឌា) ដែលជាអ្នកដំណើរការប្រព័ន្ធចែករំលែកព័ត៌មានឥណទានរបស់អតិថិជន សំដៅជំរុញការផ្តល់ឥណទានឲ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងការទទួលខុសត្រូវ ។ ក្រុមហ៊ុននេះ ត្រូវធានាឲ្យមានប្រព្រឹត្តកម្មស្មើភាព រក្សាការសម្ងាត់ និងចែករំលែកព័ត៌មានត្រឹមត្រូវរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាសមាជិក ។

ចំពោះការងារជម្រះបញ្ជី ធនាគារជាតិនៃកម្ពុជាបានសហការជាមួយក្រុមហ៊ុនសវនកម្មឯករាជ្យ Ernst & Young បញ្ចប់ការជម្រះបញ្ជីធនាគារឯកទេស១ ជាស្ថាពរ ។

## ៦- ការផ្គត់ផ្គង់សេវាធនាគារកណ្តាល

### ៦.១- សេវាគ្រប់គ្រងគណនី

បច្ចុប្បន្ននេះ ធនាគារជាតិនៃកម្ពុជាគ្រប់គ្រងគណនីជារូបិយវត្ថុជាតិ និងជាដុល្លារអាមេរិកមានចំនួន ៩៤៨ គណនី ។ គណនីទាំងនោះជារបស់ស្ថាប័នរដ្ឋនិងអង្គភាពរដ្ឋបាលកណ្តាល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានការអនុញ្ញាតឲ្យធ្វើអាជីវកម្ម និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ។

#### *៦.១.១- ស្ថាប័នរដ្ឋ*

ដើម្បីរួមចំណែកក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការបង្កើនប្រសិទ្ធភាពកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ ធនាគារជាតិនៃកម្ពុជាបានទទួលបើកគណនីជូនស្ថាប័នរដ្ឋ និងផ្តល់សេវាទូទាត់មានដូចជា ដកសាច់ប្រាក់ ផ្ទេរប្រាក់ បើកប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ និងចាត់សម្រួលសាច់ប្រាក់តាមរយៈការបង្វែរប្រាក់របស់រតនាគារជាតិ ។

ការបង់ពន្ធដារ និងពន្ធគយដោយផ្ទាល់នៅធនាគារជាតិនៃកម្ពុជាបានប្រព្រឹត្តទៅដោយរលូន និងមានទំហំទឹកប្រាក់សរុបចំនួន ២.២០៤ ពាន់លានរៀល ។

#### *៦.១.២- គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ*

គណនីដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបើកនៅធនាគារជាតិនៃកម្ពុជារួមមាន គណនីចរន្ត គណនីប្រាក់បញ្ញើធានាលើដើមទុន គណនីប្រាក់បម្រុងកាតព្វកិច្ច និងគណនីប្រាក់បញ្ញើមានកាលកំណត់ ។ សមតុល្យសរុបនៃប្រាក់បញ្ញើទាំងនោះមានចំនួន ៥៧៩ ពាន់លានរៀល និង ១.៨៩០ លានដុល្លារអាមេរិក ។

**៦.២- សេវាផ្ទេរប្រាក់ក្នុងប្រទេស**

. **ការផ្ទេរចូលមកទីស្នាក់ការកណ្តាលៈ**

- ជាប្រាក់រៀលមានចំនួន ៤២២ ពាន់លានរៀល
- ជាប្រាក់ដុល្លារមានចំនួន ៣៥៤ លានដុល្លារអាមេរិក ។

. **ការផ្ទេរចេញទៅសាខារាជធានី-ខេត្តៈ**

- ជាប្រាក់រៀលមានចំនួន ៥៣៧ ពាន់លានរៀល
- ជាប្រាក់ដុល្លារមានចំនួន ៦២ លានដុល្លារអាមេរិក ។

**៦.៣- សេវាផាត់ទាត់មូលប្បទានបត្រ**

ប្រតិបត្តិការផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក ត្រូវបានអនុវត្តជារៀងរាល់ថ្ងៃធ្វើការ ។ ការទូទាត់តាមរយៈសភាផាត់ទាត់នេះ បានដំណើរការប្រកបដោយប្រសិទ្ធភាព ។

***៦.៣.១- ការផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល***

សភាផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀលមានសមាជិកចូលរួមចំនួន ៣១ ក្នុងនោះមានធនាគារពាណិជ្ជចំនួន ២៨ ធនាគារឯកទេសចំនួន ២ និងធនាគារជាតិនៃកម្ពុជា ។

ក្នុងឆមាសទី១នេះ ការផាត់ទាត់បានដំណើរការចំនួន ១១៦ថ្ងៃ ហើយបានផាត់ទាត់មូលប្បទានបត្រចំនួន ១៩.៣១០ សន្លឹក ស្មើនឹងទឹកប្រាក់ ១.១៨២ ពាន់លានរៀល ។ បើធៀបនឹងឆមាសទី២ ឆ្នាំ២០១១ ចំនួនមូលប្បទានបត្រកើន ៩% និងចំនួនទឹកប្រាក់កើន ២៩% ។

***៦.៣.២- ការផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់ដុល្លារអាមេរិក***

សភាផាត់ទាត់មូលប្បទានបត្រជាប្រាក់ដុល្លារអាមេរិក មានសមាជិកចូលរួមចំនួន ៣៨ ក្នុងនោះមានធនាគារពាណិជ្ជចំនួន ៣២ ធនាគារឯកទេសចំនួន ៥ និងធនាគារជាតិនៃកម្ពុជា ។

ក្នុងឆមាសទី១ ការផាត់ទាត់បានដំណើរការចំនួន ១១៦ថ្ងៃ ហើយបានផាត់ទាត់មូលប្បទានបត្រចំនួន ៣១១.៤៧២ សន្លឹក ស្មើនឹងទឹកប្រាក់ ៦.៣៨២,៥ លានដុល្លារអាមេរិក ។ បើធៀបទៅនឹងឆមាសទី២ ឆ្នាំ២០១១ ចំនួនមូលប្បទានបត្រកើន ៧% និងចំនួនទឹកប្រាក់កើន ២៦% ។

**៦.៤- ការងារឥណទាន**

ធនាគារជាតិនៃកម្ពុជាបានផ្តល់ឥណទានចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រមូលបំណុលដែលដល់កាលទូទាត់សង ដូចខាងក្រោមៈ

- សមតុល្យដើមគ្រា ១៨,៥ ពាន់លានរៀល
- ឥណទានដែលបានផ្តល់ ៤៧,២ ពាន់លានរៀល
- ឥណទានដែលបានទូទាត់សង ១៨,៥ ពាន់លានរៀល
- សមតុល្យចុងគ្រា ៤៧,២ ពាន់លានរៀល ។

**៦.៥- ការងារគ្រប់គ្រងមូលបត្រ**

ចំពោះការគ្រប់គ្រងមូលបត្រ ធនាគារជាតិនៃកម្ពុជាបានសហការទូទាត់ចុះបញ្ជីគ្រប់គ្រងប័ណ្ណសងតាមបញ្ជា ដែលចេញផ្សាយដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភព

លោក និងសម្របសម្រួលការងារពាក់ព័ន្ធនឹងការគ្រប់គ្រងប័ណ្ណសងតាមបញ្ហានោះបានយ៉ាងល្អប្រសើរ ។

ទន្ទឹមនឹងនោះ ប្រតិបត្តិការគ្រប់គ្រងប័ណ្ណរតនាគាររបស់រាជរដ្ឋាភិបាលត្រូវបានផ្អាកដំណើរការជាបណ្ដោះអាសន្ន ។ តែទោះជាយ៉ាងណា ធនាគារជាតិនៃកម្ពុជាបានត្រៀមលក្ខណៈសម្រាប់បម្រើប្រតិបត្តិការនេះប្រសិនបើរាជរដ្ឋាភិបាលមានតម្រូវការចេញផ្សាយ ។

ធនាគារជាតិនៃកម្ពុជាកំពុងរៀបចំគម្រោងអភិវឌ្ឍន៍ទីផ្សារអន្តរធនាគារ និងមូលដ្ឋានគតិយុត្តិ បង្កើតនីតិវិធីប្រតិបត្តិការសម្រាប់ចេញផ្សាយមូលបត្រ ព្រមទាំងសាកល្បងប្រព័ន្ធចុះបញ្ជីមូលបត្រ ដើម្បីស្វែងរកចំណុចខ្វះខាតមួយចំនួន សំដៅធានាដល់ដំណើរការចេញផ្សាយ និងគ្រប់គ្រងមូលបត្រប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

### ៦.៦- ការងារអនុវត្តហិរញ្ញប្បទាន និងកម្ចីពីរដ្ឋាភិបាលជប៉ុន

#### ***ក- ហិរញ្ញប្បទានឥតសំណង***

##### ***ក.១- ហិរញ្ញប្បទានឥតសំណងជាគម្រោង***

ធនាគារជាតិនៃកម្ពុជាពុំបានចុះហត្ថលេខា Banking Arrangement សម្រាប់ទូទាត់ហិរញ្ញប្បទានឥតសំណងក្នុងគម្រោងថ្មីទេ ។ ចំពោះហិរញ្ញប្បទានដែលទទួលពីមុនមកនិងកំពុងតែប្រើប្រាស់ រួមមាន ៖

១- គម្រោងការពារទឹកជំនន់ក្នុងទីក្រុងភ្នំពេញជំហានទី៣ មានទឹកប្រាក់ ៣.៧០០ លានយ៉េន

២- គម្រោងបំពាក់ឧបករណ៍សម្រាប់សកម្មភាពបោសសម្អាតមីនជំហានទី៦ មានទឹកប្រាក់ ១.២៩៨ លានយ៉េន

៣- គម្រោងជួសជុល និងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅទីរួមខេត្តនានា មានទឹកប្រាក់ ២.៧៦០ លានយ៉េន

៤- គម្រោងអាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស (Scholarship 1113) មានទឹកប្រាក់ ២៧៣ លានយ៉េន

៥- គម្រោងបំពាក់ឧបរណ៍អប់រំនៅដេប៉ាតឺម៉ង់ទេព្យកោសល្យធនធានរ៉ែនិងភូគព្ភសាស្ត្រនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា មានទឹកប្រាក់ ៥៥,៧ លានយ៉េន

៦- គម្រោងអាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស ( Scholarship 0811) មានទឹកប្រាក់ ៣៥៣ លានយ៉េន និង

៧- គម្រោងសាងសង់ស្ពានអ្នកលឿង (Bridge 2014) មានទឹកប្រាក់ ១១.៩៤០ លានយ៉េន ។

##### ***ក.២- ហិរញ្ញប្បទានឥតសំណងក្រៅគម្រោង***

រដ្ឋាភិបាលជប៉ុន បានផ្ដល់ហិរញ្ញប្បទានឥតសំណងក្រៅគម្រោងដល់រាជរដ្ឋាភិបាលកម្ពុជានូវទឹកប្រាក់សរុបចំនួន ៦០០ លានយ៉េន សម្រាប់ការពារគ្រោះធម្មជាតិដែលបណ្ដាលមកពីទឹកជំនន់ ។ ដើម្បីសម្រួលដល់ការទូទាត់ ធនាគារជាតិនៃកម្ពុជាបានចុះហត្ថលេខា Banking Arrangement ជាមួយធនាគារ The Bank of Tokyo-Mitsubishi UFJ, Ltd. រួចហើយ ។

#### ***ខ- កម្ចីសម្បទាន***

ធនាគារជាតិនៃកម្ពុជាពុំបានចុះហត្ថលេខា Banking Arrangement ជាមួយធនាគារ Bank of Tokyo-Mitsubishi UFJ, Ltd. សម្រាប់កម្ចីសម្បទានថ្មីទៀតទេ ។

គម្រោងដែលបានបញ្ចប់នៅឆមាសទី១នេះ មាន គម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ (L/A No.CP-P6) ដែលមានទឹកប្រាក់ចំនួន ៣១៨ លានយ៉េន ។ គម្រោងកំពុងអនុវត្តមានដូចខាងក្រោម ៖

១- គម្រោងអភិវឌ្ឍន៍កំពុងផែពហុបំណងខេត្តព្រះសីហនុ (L/A No.CP-P10) មានទឹកប្រាក់ ៧.១៧៦ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០១០)

២- គម្រោងផ្គត់ផ្គង់ទឹកស្អាតនិរោធ (L/A No.CP-P9) មានទឹកប្រាក់ ៣.៥១៣ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០១០)

៣- គម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ (L/A No.CP-P8) មានទឹកប្រាក់ ៣.៦៥១ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០០៨)

៤- គម្រោងអភិវឌ្ឍន៍ខ្សែបណ្តាញថាមពលអគ្គិសនីមហាអនុតំបន់ទន្លេមេគង្គ (L/A No.CP-P7) មានទឹកប្រាក់ ២.៦៣២ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០០៧) និង

៥- គម្រោងបង្កើតបណ្តាញទូរគមនាគមន៍មហាអនុតំបន់ទន្លេមេគង្គ (L/A No.CP-P5) មានទឹកប្រាក់ ៣.០២៩ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០០៥) ។

**៧- ការគ្រប់គ្រងចរាចរណ៍ធនបត្រ**

ក្នុងឆមាសទី១ ឆ្នាំ២០១២ ចំណូលសាច់ប្រាក់រៀលតាមបេឡាប្រតិបត្តិការមានចំនួន ៣.៧៧៣,៤ ពាន់លានរៀល បើធៀបនឹងគ្រាដូចគ្នាឆ្នាំ២០១១ កើនឡើង ១៥,២% ក្នុងនោះចំណូលពីឃ្លាំងសម្រប សម្រួលបោះផ្សាយ កើនឡើង ១៣៧ ពាន់លានរៀល (៨,២%) ប្រាក់បញ្ញើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ កើនឡើង ១៤៤,៣ ពាន់លានរៀល (៣០,៩%) ប្រាក់បញ្ញើរតនាគារជាតិ កើនឡើង ៤៦,២ ពាន់លានរៀល (២៣,៧%) ប្រាក់បញ្ញើអគ្គិសនីកម្ពុជា កើនឡើង ៣៦ ពាន់លានរៀល (១២,៥%) ពីសាខាធនាគារជាតិនៃកម្ពុជា កើនឡើង ៤៣,៨ ពាន់លានរៀល (២៣,៣%) ប្រាក់បញ្ញើអាជីវករ កើនឡើង ៦២ ពាន់លានរៀល (១៩,៦%) និងសាច់ប្រាក់ផ្សេងៗ កើនឡើង ២៩,៧ ពាន់លានរៀល (២០,៧%) ។

ចំពោះការចំណាយសាច់ប្រាក់តាមបេឡាប្រតិបត្តិការវិញមានចំនួន ៣.៧៣៧,៤ ពាន់លានរៀល បើធៀបនឹងគ្រាដូចគ្នាឆ្នាំ២០១១ កើនឡើង ១៦,២% ក្នុងនោះចំណាយបញ្ចេញទៅឃ្លាំងសម្របសម្រួលបោះផ្សាយ កើនឡើង ៣១៣ ពាន់លានរៀល (២៣%) ចំណាយឲ្យរតនាគារជាតិ កើនឡើង ១៦៧,៨ ពាន់លានរៀល (១៧,៧%) ចំណាយលើការដកប្រាក់បញ្ញើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ កើនឡើង ៦៧,២ ពាន់លានរៀល (៥៤%) និងចំណាយផ្សេងៗ កើនឡើង ៣០,៦ ពាន់លានរៀល (១៨,៨%) ។ ផ្ទុយទៅវិញ ចំណាយអាជីវករដកប្រាក់បញ្ញើ ថយចុះ ៤៩,៨ ពាន់លានរៀល (២៧,៩%) និងចំណាយឲ្យសាខាធនាគារជាតិនៃកម្ពុជា ថយចុះ ៧,៩ ពាន់លានរៀល (១,៨%) ។

ក្នុងគ្រានេះដែរ សកម្មភាពប្រាក់ដុល្លារអាមេរិកបង់ចូលតាមបេឡាប្រតិបត្តិការសរុបមានចំនួន ១.៩៦២,២ លានដុល្លារអាមេរិក កើនឡើង ៥៣៣,៦ លានដុល្លារអាមេរិក (៣៧,៤%) ហើយចំណាយតាមរយៈបេឡាប្រតិបត្តិការមានចំនួន ១.៩៦២,៣ លានដុល្លារអាមេរិក កើនឡើង ៥៣៣,៥ លានដុល្លារអាមេរិក (៣៧,៣%) បើធៀបនឹងគ្រាដូចគ្នាឆ្នាំ២០១១ ។

ដើម្បីសម្រួលដល់ចរាចរណ៍ក្រដាសប្រាក់រៀល ធនាគារជាតិនៃកម្ពុជា បានផ្តល់ក្រដាសប្រាក់ថ្មីឲ្យសាខាធនាគារជាតិនៃកម្ពុជាចំនួន ២០១,៣ ពាន់លានរៀល សម្រាប់ដូរយកក្រដាសប្រាក់ ចាស់ ទក់ រហែក បើធៀបនឹងគ្រាដូចគ្នាឆ្នាំ ២០១១ កើនឡើង ៥៣,៨ ពាន់លានរៀល (៣៦,៥%) ហើយបានធ្វើការកាត់កម្ទេច និងបំផ្លាញចោលក្រដាសប្រាក់ ចាស់ ទក់ រហែក ដោយម៉ាស៊ីនធម្មតាចំនួន ៤៦១,២ ពាន់លានរៀល កើនឡើង ៩៨,៩ ពាន់លានរៀល (២៧,៣%) និងសាច់ប្រាក់ដែលបានកាត់កម្ទេចដោយម៉ាស៊ីនស្វ័យប្រវត្តចំនួន ៣០៤,១ ពាន់លានរៀល កើនឡើង ១២៣,៩ ពាន់លានរៀល (៦៨,៨%) បើធៀបនឹងគ្រាដូចគ្នាឆ្នាំ២០១១ ។

ចំពោះការងារគ្រប់គ្រងសាច់ប្រាក់ និងការងាររាំងខ្ទប់ចរាចរណ៍ក្រដាសប្រាក់ក្លែងក្លាយ ធនាគារជាតិនៃកម្ពុជាតែងតែតាមដាន និងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចជាប្រចាំ ហើយបានដកហូតក្រដាសប្រាក់រៀលក្លែងក្លាយប្រភេទថតចម្លងចំនួន ៣៦៩សន្លឹក កើនឡើង ២ដង បើធៀបនឹងគ្រាដូចគ្នាឆ្នាំ២០១១ ។

## ៨- ការអភិវឌ្ឍប្រព័ន្ធទូទាត់

តាមរយៈជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងការគាំទ្រពីសមាគមធនាគារកម្ពុជា ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍប្រព័ន្ធជាតិទូទាត់សងប្រាក់ដែលមានលក្ខណៈមជ្ឈការ ដើម្បីសម្រួលដល់ការទូទាត់តាមរយៈការប្រើប្រាស់ឧបករណ៍ទូទាត់ផ្សេងៗ ដូចជា មូលប្បទានបត្រ និងការផ្ទេរអេឡិចត្រូនិកជាដើម ។ ធនាគារជាតិនៃកម្ពុជាបានបំពាក់ប្រព័ន្ធ Client Module សម្រាប់ប្រព័ន្ធទូទាត់ដែលមានលក្ខណៈមជ្ឈការ និងបណ្តុះបណ្តាលពីការប្រើប្រាស់ប្រព័ន្ធនេះ ដល់គ្រប់ធនាគារជាសមាជិកសភាផាត់ទាត់ទាំង ៣៨ និងសាខាធនាគារជាតិនៃកម្ពុជាដែលមានសភាផាត់ទាត់ ។ ការធ្វើតេស្តលើប្រព័ន្ធថ្មីនេះត្រូវបានអនុវត្តរួមគ្នាជាមួយធនាគារសមាជិក ហើយប្រព័ន្ធថ្មីនេះនឹងដាក់ឲ្យអនុវត្តជាផ្លូវការនៅក្នុងឆមាសទី២ ឆ្នាំ២០១២ ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាកំពុងរៀបចំឡើងវិញនូវឯកសារស្តីពី "វិធាន និងនីតិវិធីសម្រាប់សភាផាត់ទាត់" ដើម្បីសម្រួលដល់ការប្រើប្រាស់ប្រព័ន្ធថ្មីនេះ ។

## ៩- ការងារព័ត៌មានវិទ្យា

ចំពោះការងារព័ត៌មានវិទ្យា ធនាគារជាតិនៃកម្ពុជាកំពុងរៀបចំប្រព័ន្ធទូទាត់និងផាត់ទាត់ថ្នាក់ជាតិ (CNCSS), ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងការចេញផ្សាយមូលបត្រអាចជួញដូរបានរបស់ធនាគារជាតិនៃកម្ពុជា (NCD BES) និងប្រព័ន្ធផ្ញើរបាយការណ៍របស់គ្រឹះស្ថានធនាគារពាណិជ្ជនិងធនាគារឯកទេសតាមបណ្តាញអ៊ីនធឺណិតមកធនាគារជាតិនៃកម្ពុជា (BSRS) ។ ទាក់ទងនឹងគម្រោងប្រព័ន្ធទូទាត់និងផាត់ទាត់ថ្នាក់ជាតិ (CNCSS) ធនាគារជាតិនៃកម្ពុជាបានសហការជាមួយក្រុមហ៊ុន CMA បើកវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធផាត់ទាត់ថ្មី និងចុះបំពាក់ប្រព័ន្ធនេះដល់ធនាគារសមាជិកសភាផាត់ទាត់ទាំងអស់ ព្រមទាំងសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តដែលមានសភាផាត់ទាត់ រួមមាន ខេត្តសៀមរាប បាត់ដំបង ព្រះសីហនុ និងកំពង់ចាម ។ ចំណែកឯប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គាំទ្រដល់ការចេញផ្សាយមូលបត្រអាចជួញដូរបាន (NCDBES) ធនាគារជាតិនៃកម្ពុជាកំពុងរៀបចំនីតិវិធីសម្រាប់ការចេញផ្សាយនាពេលខាងមុខ ។ ទន្ទឹមនឹងនេះដែរ ប្រព័ន្ធផ្ញើរបាយការណ៍របស់គ្រឹះស្ថានធនាគារតាមបណ្តាញអ៊ីនធឺណិត (BSRS) ក៏បានដាក់ឲ្យប្រើប្រាស់សាកល្បងចាប់ពីដើមខែមេសា ឆ្នាំ២០១២ មក ។

## II-ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា

### ១- សកម្មភាពក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជានាពេលបច្ចុប្បន្ន មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - ឯកឧត្តម ជា ចាន់តូ | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ជាប្រធាន |
| - លោកជំទាវ នាវ ច័ន្ទថាណា | ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | ជាសមាជិកា |
| - ឯកឧត្តម អ៊ូន ព័ន្ធមុនីរ័ត្ន | តំណាងប្រមុខរាជរដ្ឋាភិបាល | ជាសមាជិក |
| - ឯកឧត្តម អ៊ីវ ចុង | តំណាងមជ្ឈដ្ឋានឧត្តមសិក្សា | ជាសមាជិក |
| - ឯកឧត្តម ជូ គឹមឡេង | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| - លោក ឡាយ ម៉េងស៊ុន | តំណាងមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច | ជាសមាជិក |
| - លោកស្រី ម៉ៅ សុន | តំណាងបុគ្គលិកធនាគារជាតិនៃកម្ពុជា | ជាសមាជិកា ។ |

ក្នុងអំឡុងឆមាសទី១នេះ ក្រុមប្រឹក្សាភិបាលបានប្រជុំចំនួន ៣ លើក ដើម្បីពិភាក្សានិងអនុម័តលើការងារមួយចំនួនដូចខាងក្រោម៖

- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៩០ នាថ្ងៃទី២៥ ខែមករា ឆ្នាំ២០១២ ស្តីពី៖
  (១) ការពិនិត្យនិងសម្រេចលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យធនាគារជាតិនៃកម្ពុជាសម្រាប់ការិយបរិច្ឆេទឆ្នាំ២០១១
  (២) របាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងសម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ របស់សវនករឯករាជ្យ PWC
  (៣) របាយការណ៍សវនកម្មនៅធនាគារជាតិនៃកម្ពុជា សម្រាប់ការិយបរិច្ឆេទឆ្នាំ២០០៧ ។
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៩១ នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១២ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ស្តីពី ស្ថានភាពថវិកាធនាគារជាតិនៃកម្ពុជាឆ្នាំ២០១១ និងផែនការថវិកាឆ្នាំ២០១២ ។
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៩២ នាថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១២ ដើម្បីពិនិត្យនិងអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១២ របស់ធនាគារជាតិនៃកម្ពុជា ។

### ២- ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស

#### ២.១- ស្ថិតិមន្ត្រីបុគ្គលិក

- ក្របខ័ណ្ឌធនាគារជាតិនៃកម្ពុជា (ទីស្នាក់ការកណ្តាល) មានចំនួន ៨៦៣រូប (ប្រុស ៤៩០រូប ស្រី ៣៧៣រូប)
- ក្របខ័ណ្ឌសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត មានចំនួន ៣៨៦រូប (ប្រុស ២២២រូប ស្រី ១៦៤រូប)

ដូច្នេះ សរុបក្របខ័ណ្ឌមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទូទាំងប្រទេស មានចំនួន ១.២៤៩រូប

(ប្រុស ៧១២រូប ស្រី ៥៣៧រូប) បើធៀបនឹងក្របខ័ណ្ឌក្នុងខែធ្នូ ឆ្នាំ២០១១ ដែលមានចំនួន ១.២៦០រូប (ប្រុស ៧១៨រូប ស្រី ៥៤២រូប) មានការប្រែប្រួលដូចតទៅ៖

- ទីស្នាក់ការកណ្តាល : ថយចុះ ១១រូប (ចូល ២រូប ចេញ ១៣រូប)
- សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត : ពុំមានការប្រែប្រួល (ចូល ២រូប ចេញ ២រូប) ។

**២.២- ការងារបណ្តុះបណ្តាល**

**ក- ការងារបណ្តុះបណ្តាលក្នុងប្រទេស**

ធនាគារជាតិនៃកម្ពុជាបានបើកវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលាចំនួន ១០ លើក (មន្ត្រីបុគ្គលិកចូលរួម ២៧០រូប) វគ្គឧទ្ទេសនាមសម្រាប់មន្ត្រីដែលបានត្រឡប់មកពីបណ្តុះបណ្តាលនៅក្រៅប្រទេសចំនួន ១២ លើក (មន្ត្រីបុគ្គលិកចូលរួម ៤៣១រូប) ។

វគ្គសិក្សានៅសាលាភូមិន្ទរដ្ឋបាល ២រូប វគ្គបណ្តុះបណ្តាលនៅមណ្ឌលសិក្សាបច្ចេកទេសធនាគារ ១៤រូប (ជំនាន់ទី ២០ ចំនួន ៨រូប និងជំនាន់ទី ២១ ចំនួន ៦រូប) វគ្គបណ្តុះបណ្តាលភាសាអង់គ្លេសនៅសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ធំចំនួន១វគ្គ (មន្ត្រីបុគ្គលិកសិក្សា ១១រូប) សិក្សាភាសាអង់គ្លេសនៅ ACE ចំនួន ១២រូប និងចូលរួមសិក្ខាសាលាវគ្គបណ្តុះបណ្តាលនិងកិច្ចប្រជុំផ្សេងៗតាមការអញ្ជើញពីបណ្តាក្រសួង-ស្ថាប័ននានាចំនួន ៥ លើក (មន្ត្រីបុគ្គលិកចូលរួម ២០រូប) ។

**ខ- ការងារបណ្តុះបណ្តាលក្រៅប្រទេស**

ធនាគារជាតិនៃកម្ពុជាបានបន្តបង្កើនសមត្ថភាព និងអភិវឌ្ឍធនធានមនុស្សតាមរយៈសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនៅក្រៅប្រទេសចំនួន ៤០ លើក (មន្ត្រីបុគ្គលិកចូលរួម ៥៧រូប) ទស្សនកិច្ចសិក្សាចំនួន ៣ លើក (មន្ត្រីបុគ្គលិកចូលរួម ១៤រូប) វគ្គសិក្សារយៈពេលខ្លីចំនួន ២២ លើក (មន្ត្រីបុគ្គលិកចូលរួម ៤៦រូប) វគ្គសិក្សារយៈពេលវែងថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ចំនួន ២លើក នៅប្រទេសអូស្ត្រាលី (មន្ត្រីបុគ្គលិកចូលរួម ២រូប) និងកិច្ចប្រជុំនានាចំនួន ២៨ លើក (មន្ត្រីបុគ្គលិកចូលរួម ៧២រូប) តាមការអញ្ជើញនិងឧបត្ថម្ភរបស់ប្រទេស និងស្ថាប័នអន្តរជាតិដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក ធនាគារកណ្តាលម៉ាឡេស៊ី ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារកណ្តាលប៉ាគីស្ថាន ធនាគារកណ្តាលកូរ៉េ រដ្ឋាភិបាលឥណ្ឌា រដ្ឋាភិបាល សាធារណរដ្ឋកូរ៉េ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន មជ្ឈមណ្ឌល SEACEN ធនាគារកណ្តាល សាធារណរដ្ឋឆែក ធនាគារកណ្តាលអាឡឺម៉ង់ និងស្ថាប័នផ្សេងៗទៀត ។

**៣- ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច**

ស្របតាមផែនការឆ្នាំ២០១២ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងតាមបណ្តាអង្គភាពក្រោមឱវាទ ហើយបានចេញផ្សាយរបាយការណ៍សវនកម្មសម្រេច លើនាយកដ្ឋានមួយចំនួន នៅទីស្នាក់ការកណ្តាលរួមមាន នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ ព្រមទាំងសាខាធនាគារជាតិនៃកម្ពុជាខេត្តស្វាយរៀង កំពត តាកែវ ក្រចេះ និងកំពង់ឆ្នាំង ដោយបានកំណត់អំពីចំណុចរកឃើញ និងផ្តល់អនុសាសន៍កែលម្អដើម្បីកាត់បន្ថយហានិភ័យដែលអាចកើតឡើងជាយថាហេតុ ។ ទន្ទឹមនឹងនេះ ធនាគារជាតិនៃកម្ពុជាបានបន្តចុះធ្វើសវនកម្មនៅការិយាល័យគ្រប់គ្រងនិងផ្គត់ផ្គង់នៃខុទ្ទកាល័យ និង

ធ្វើសវនកម្មលើការអនុវត្តការងារកិច្ចដំណើរការនៃប្រព័ន្ធ Flexcube នៅសាខាធនាគារជាតិនៃកម្ពុជាខេត្តពោធិ៍សាត់ ព្រៃវែង ស្ទឹងត្រែង និងសៀមរាប ។ ជាងនេះទៅទៀត ក្រុមសវនករបានចុះពិនិត្យតាមដាន ការអនុវត្តតាមអនុសាសន៍នៅនាយកដ្ឋានរោងពុម្ព និងសាខាធនាគារជាតិនៃកម្ពុជារាជធានីភ្នំពេញ ខេត្តកំពង់ចាម និងបាត់ដំបង ពាក់ព័ន្ធនឹងនីតិវិធីនៃការគ្រប់គ្រងសាច់ប្រាក់ ការគ្រប់គ្រងទូទៅ និងការចំណាយផ្ទៃក្នុង ក្នុងគោលបំណងដើម្បីធានាថា សវនដ្ឋានបាននឹងកំពុងចាត់វិធានការកែតម្រូវតាមអនុសាសន៍របស់ក្រុមសវនករ ។

ក្រៅពីការងារសវនកម្ម សវនករបានចូលរួមក្នុងការពិនិត្យផ្ទៀងផ្ទាត់លើតារាងប្តូរប្រាក់ប្រចាំថ្ងៃ អត្រាប្តូរប្រាក់ប្រចាំខែ ស្ថិតិរូបិយវត្ថុប្រចាំខែ និងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ប្រចាំខែ របស់នាយកដ្ឋានស្ថិតិសម្រាប់ផ្ញើជូនមូលនិធិរូបិយវត្ថុអន្តរជាតិ ។

ការងារអធិការកិច្ចត្រូវបានដំណើរការតាមរយៈការចុះឆ្នក់ត្រួតពិនិត្យដោយមិនជូនដំណឹងមុន លើសាខាធនាគារជាតិនៃកម្ពុជាចំនួន ៩ ដែលការចុះត្រួតពិនិត្យបានផ្តោតជាសំខាន់លើការងារធានាសុវត្ថិភាពឃ្លាំងប្រាក់ ការងារគ្រប់គ្រងសាច់ប្រាក់ និងការអនុវត្តរាល់សេចក្តីណែនាំរបស់នាយកដ្ឋានជំនាញដែលបានដាក់ចុះ ព្រមទាំងពង្រឹងគុណវុឌ្ឍិ និងវិន័យការងារមន្ត្រីបុគ្គលិកនៅតាមសាខាឲ្យបានកាន់តែប្រសើរ ។

ទន្ទឹមនឹងនេះ ការត្រួតពិនិត្យបានដំណើរការជាប្រចាំលើរបាយការណ៍ប្រចាំខែរបស់បណ្តានាយកដ្ឋាននៅទីស្នាក់ការកណ្តាល និងសាខាធនាគារជាតិនៃកម្ពុជា ដោយបានពិនិត្យឡើងវិញអំពីការអនុវត្តមុខងារ-ភារកិច្ច និងផ្ទៀងផ្ទាត់ទិន្នន័យ ដើម្បីរកឲ្យឃើញនូវភាពត្រឹមត្រូវប្រាកដប្រជា ។

### ៤- ការងារគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលជំហានទី២ ឲ្យកាន់តែមានប្រសិទ្ធ-ភាព និងបន្តតាមដានការអនុវត្តកម្មវិធីប្រព័ន្ធធនាគារស្នូល (CBS) នៅតាមសាខារាជធានី-ខេត្ត ព្រមទាំងបន្តបណ្តុះបណ្តាលនិងផ្គត់ផ្គង់ធនធានមនុស្សបន្ថែមទៀត ដើម្បីពង្រឹងការអនុវត្តប្រព័ន្ធនេះ ឲ្យកាន់តែមានប្រសិទ្ធភាព ។ ដោយឡែក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបន្តសាកល្បងជំហានទី៣ លើការគ្រប់គ្រងចំណូល-ចំណាយថវិការដ្ឋ ដោយបានបើកគណនីប្រតិបត្តិការចំណូល-ចំណាយថវិការដ្ឋ នៅធនាគារអេស៊ីលីដា និងធនាគារកាណាឌីយ៉ា រួមមាន រាជធានីភ្នំពេញ កំពង់ធំ ពោធិ៍សាត់ កំពត ក្រចេះ និងរតនគិរី និងអនុញ្ញាតជាគោលការណ៍ឲ្យមន្ទីរ-អង្គភាពជំនាញនិងរតនាគាររាជធានី-ខេត្តទាំងនេះ បិទគណនីនៅសាខាធនាគារជាតិនៃកម្ពុជា ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានអនុញ្ញាតឲ្យក្រុង ស្រុក ខណ្ឌ ចំណុះខេត្តទាំង ៦ រួមមានខេត្តព្រៃវែង ស្វាយរៀង តាកែវ កំពង់ឆ្នាំង កំពង់ស្ពឺ និងប៉ៃលិន បើកគណនីប្រាក់បញ្ញើនៅសាខាធនាគារជាតិនៃកម្ពុជា ។

## III- ទំនាក់ទំនងអន្តរជាតិ

### ១- ទំនាក់ទំនងពហុភាគី

#### ១.១- មូលនិធិរូបិយវត្ថុអន្តរជាតិ

មូលនិធិរូបិយវត្ថុអន្តរជាតិបានមកបំពេញទស្សនកិច្ចនៅធនាគារជាតិនៃកម្ពុជាចំនួន ២ លើក ។ បេសកកម្មលើកទី១ ធ្វើឡើងចាប់ពីថ្ងៃទី២៣ ខែមេសា ដល់ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១២ ស្តីពី **ការងារបច្ចេក-ទេសជាមួយនាយកដ្ឋានស្ថិតិ** ក្នុងគោលបំណងពិភាក្សា និងតាមដានអនុសាសន៍ និងផែនការសកម្មភាព ដែលរៀបចំឡើងដោយក្រុមបេសកកម្មនៅឆ្នាំ២០១០ ពាក់ព័ន្ធនឹងការពង្រឹង និងចងក្រងស្ថិតិជញ្ជីងទូទាត់ ព្រមទាំងស្ថានភាពវិនិយោគអន្តរជាតិ ឲ្យស្របតាមរូបមន្តនៃលើកទី ៦ របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។

បេសកកម្មលើកទី២ ធ្វើឡើងចាប់ពីថ្ងៃទី២៣-២៩ ខែឧសភា ឆ្នាំ២០១២ ស្តីពី **ស្ថានភាពសេដ្ឋកិច្ច និងការពិភាក្សាគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច** ដែលមានគោលបំណងផ្តោតទៅលើ (១) ស្ថានភាពរូបិយវត្ថុបច្ចុប្បន្ន និងការព្យាករស្ថានភាពរូបិយវត្ថុអនាគត (២) ទិដ្ឋភាពនៃការគរពូនទុនបម្រុងអន្តរជាតិឆ្នាំ២០១២-២០១៣ (៣) ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១២-២០១៣ និង (៤) ស្ថានភាពបច្ចុប្បន្ននៃក្របខ័ណ្ឌព្យាករសន្ទនីយភាពនៃប្រព័ន្ធធនាគារ ។

#### ១.២- ធនាគារអភិវឌ្ឍន៍អាស៊ី

ធនាគារជាតិនៃកម្ពុជាដែលជាភ្នាក់ងារប្រតិបត្តិគម្រោង បានរួមសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងគណៈកម្មការមូលបត្រកម្ពុជា ដែលជាភ្នាក់ងារអនុវត្តគម្រោង ដើម្បីបន្តអនុវត្តកម្មវិធីកំណែទម្រង់ក្នុងអនុកម្មវិធីទី២ នៃកម្មវិធីឥណទានសម្រាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុជំហានទី III (FSPL III) ទៀត ។ ធនាគារអភិវឌ្ឍន៍អាស៊ីក៏បានអនុម័តផ្តល់ឥណទាន និងជំនួយបច្ចេកទេសសម្រាប់ការអនុវត្តកំណែទម្រង់នៅក្នុងអនុកម្មវិធីទី២ ទៀត ដែលមានទឹកប្រាក់ចំនួន ១៥ លានដុល្លារអាមេរិក ក្នុងអត្រាការប្រាក់ ១,៥% ។ អនុកម្មវិធីទី២ មានផែនការសកម្មភាពចំនួន ៣២ ដែលក្នុងនោះមាន ១២ ពាក់ព័ន្ធនឹងធនាគារជាតិនៃកម្ពុជា ។ តាមគម្រោងផែនការសកម្មភាពនៅក្នុងអនុកម្មវិធីទី២ ត្រូវបំពេញបញ្ចប់នៅចុងឆ្នាំ២០១២ ដើម្បីឲ្យធនាគារអភិវឌ្ឍន៍អាស៊ីសុំការអនុម័តពីក្រុមប្រឹក្សាភិបាលរបស់ខ្លួន ផ្តល់ប្រាក់តាមសន្យានៅដើមត្រីមាសទី១ ឆ្នាំ២០១៣ ។

លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជាបានបន្តសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ដើម្បីរៀបចំការបកប្រែឯកសារបច្ចុប្បន្នកម្ម "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០" ជាភាសាអង់គ្លេសឲ្យបានសុក្រិត្យតាមខ្លឹមសារនៃឯកសារជាភាសាខ្មែរ ហើយឯកសារយុទ្ធសាស្ត្រនេះត្រូវបានប្រកាសផ្សព្វផ្សាយជាផ្លូវការនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១២ ។

#### ១.៣- អាស៊ាន និងអាស៊ាន+៣

ធនាគារជាតិនៃកម្ពុជាបានបន្តរួមចំណែកយ៉ាងសកម្ម ក្នុងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន និង អាស៊ាន+៣ ដើម្បីពង្រឹងសហប្រតិបត្តិការហិរញ្ញវត្ថុក្នុងតំបន់ ព្រមទាំងផ្លាស់ប្តូរបទពិសោធន៍លើវិធានការគោលនយោបាយនានា និងការអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗទាំងក្នុងតំបន់និងអន្តរជាតិ ។ ធនាគារជាតិនៃកម្ពុជាបាន

ធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី ៨ និងកិច្ចប្រជុំថ្នាក់ទេសាភិបាលរងធនាគារកណ្តាល និងថ្នាក់អនុរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានលើកទី២០ ព្រមទាំងបានចូលរួមកិច្ចប្រជុំពាក់ព័ន្ធផ្សេងៗទៀត នៅរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី២៦ ដល់ថ្ងៃទី២៩ ខែមីនា ។ ធនាគារជាតិនៃកម្ពុជាបានចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុ និងថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ាន+៣ លើកទី ១៥ កាលពីថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១២ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ។ នេះជាកិច្ចប្រជុំលើកដំបូងក្នុងប្រវត្តិសាស្ត្រអាស៊ាន ដែលរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលអាស៊ាន+៣ បានជួបពិភាក្សារួមគ្នា ដើម្បីចែករំលែកជំនាញ និងបទពិសោធន៍គ្នាទៅវិញទៅមកក្នុងការពង្រឹងសហប្រតិបត្តិការហិរញ្ញវត្ថុក្នុងតំបន់ ។

កិច្ចប្រជុំទាំងនេះមានគោលដៅជំរុញសមាហរណកម្មហិរញ្ញវត្ថុអាស៊ានឲ្យបានស៊ីជម្រៅ ដែលផ្តោតទៅលើវិស័យអាទិភាព ៤ គឺការអភិវឌ្ឍទីផ្សារទុន សេរីភាវូបនីយកម្មគណនីដើមទុន សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់និងផាត់ទាត់ ។ លើសពីនេះ គណៈកម្មការជាន់ខ្ពស់ (Senior Level Committee - SLC) ស្តីពីការអនុវត្តបង្គោលចរ (milestones) សម្រាប់សមាហរណកម្មអាស៊ាន ដែលដឹកនាំដោយធនាគារកណ្តាលហ្វីលីពីន និងម៉ាឡេស៊ី បានដើរតួនាទីយ៉ាងសំខាន់ដើម្បីជំរុញសមាហរណកម្មលើវិស័យអាទិភាពទាំង ៤ និងជួយដឹកនាំការងាររបស់គណៈកម្មការលើវិស័យទាំង ៤ ខាងលើ ឲ្យកាន់តែរលូន និងមានប្រសិទ្ធភាព ។

បច្ចុប្បន្ននេះ វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន+៣ ក៏ទទួលបានលទ្ធផលគួរជាទីមោទនៈផងដែរ ។ សមិទ្ធផលចម្បងៗ ដែលសម្រេចបានពីយន្តការស្វ័យការពារក្នុងតំបន់ក្រោមក្របខ័ណ្ឌពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM) រួមមាន ការបង្កើនទំហំមូលនិធិពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ ពី១២០ ពាន់លានដុល្លារ ទៅ ២៤០ ពាន់លានដុល្លារអាមេរិក ការបង្កើនរយៈពេលឥណប្រតិទានពី៦ខែ ទៅ ១ឆ្នាំ ការបង្កើនទំហំសមាមាត្រមិនភ្ជាប់លក្ខខណ្ឌមូលនិធិរូបិយវត្ថុអន្តរជាតិពី ២០% ទៅ ៣០% និងការដាក់ឈ្មោះ "CMIM Precautionary Line" សម្រាប់យន្តការទប់ស្កាត់វិបត្តិ (CPF) ។ ក្រៅពីនេះ ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) ក៏មានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ផងដែរ ក្នុងនោះរួមមាន ការសម្ពោធជាផ្លូវការនូវការិយាល័យ AMRO នៅប្រទេសសិង្ហបុរីនាដើមខែមករា ឆ្នាំ២០១២ ការឯកភាពចំពោះផែនការរយៈពេលមធ្យមរបស់ AMRO ការគាំទ្រជំហានចាំបាច់នានាក្នុងការរៀបចំសមត្ថភាពគតិយុត្តិរបស់ការិយាល័យនេះជាស្ថាប័នអន្តរជាតិ និងការរៀបចំសេចក្តីព្រាងទី១ នៃសន្ធិសញ្ញារបស់ AMRO ។

ដោយឡែក ប្រទេសសមាជិកអាស៊ាន+៣ បានឯកភាពជាឯកច្ឆន្ទលើផែនទីគោចរថ្មីសម្រាប់គំនិតផ្តួចផ្តើមទីផ្សារសញ្ញាប័ណ្ណអាស៊ាន (ABMI) ដើម្បីអភិវឌ្ឍទីផ្សារសញ្ញាប័ណ្ណក្នុងតំបន់ឲ្យកាន់តែទូលំទូលាយ និងប្រកបដោយប្រសិទ្ធភាព តាមរយៈការកែនប្រមូលសន្សំក្នុងតំបន់ដើម្បីគាំទ្រការវិនិយោគក្នុងតំបន់វិញ ។ លើសពីនេះ ប្រទេសអាស៊ានរួមជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ីបានបញ្ចប់ការងារត្រៀមបម្រុងផ្សេងៗ ទាក់ទងនឹងយន្តការធានាលើឥណទាន និងវិនិយោគ (CGIF) ដែលមានទឹកប្រាក់សរុបចំនួន ៧០០ លានដុល្លារអាមេរិក ហើយយន្តការនេះត្រូវបានរំពឹងថានឹងដាក់ឲ្យដំណើរការប្រតិបត្តិការដំបូងរបស់ខ្លួនក្នុងពេលឆាប់ៗខាងមុខនេះ ។ ទន្ទឹមនឹងនេះ វេទិកាទីផ្សារសញ្ញាប័ណ្ណអាស៊ាន+៣ ក៏ត្រូវបានបង្កើតឡើងផងដែរ ដើម្បីជួយដល់ការសម្របសម្រួលស្តង់ដារ និងបទប្បញ្ញត្តិទាក់ទងនឹងប្រតិបត្តិការសញ្ញាប័ណ្ណឆ្លងដែនក្នុងតំបន់ ។

**១.៤- មជ្ឈមណ្ឌលធនាគារកណ្ដាលអាស៊ីអាគ្នេយ៍ ( ស៊ាសិន** - SEACEN )

ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្ដាសមាជិកនៃមជ្ឈមណ្ឌលស៊ាសិន ដោយបានចូលរួមសិក្ខាសាលាថ្នាក់នាយកប្រតិបត្តិ SEACEN-BIS ក្រោមប្រធានបទស្តីពី "Global Imbalance: Implications for SEACEN Economic and Moving Forward Asia as a Region" និងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិនៃមជ្ឈមណ្ឌលស៊ាសិន (EXCO) លើកទី១០ កាលពីថ្ងៃទី១២ ដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១២ នៅទីក្រុងកូឡុំបូ ប្រទេសស្រីលង្កា ។ ទន្ទឹមនោះដែរ ធនាគារជាតិនៃកម្ពុជាមានកិត្តិយសទទួលធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសិក្ខាសាលាលើកទី ៥ របស់មជ្ឈមណ្ឌលស៊ាសិន សហការជាមួយមជ្ឈមណ្ឌលសិក្សាធនាគារកណ្ដាលអង់គ្លេស ស្តីពី "ការគ្រប់គ្រងគោលនយោបាយរូបិយវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច" ចាប់ពីថ្ងៃទី១៨-២៤ ខែមីនា ឆ្នាំ២០១២ នៅខេត្តសៀមរាប ប្រកបដោយជោគជ័យ ។

**១.៥- សមាគមធនាគារកណ្ដាលនៃបណ្ដាប្រទេសនិយាយភាសាបារាំង**
( **ហ្វ្រង់កូហ្វូន** - Francophone )

បន្ទាប់ពីបានចូលជាសមាជិកនាឆ្នាំ១៩៩៣ មក កិច្ចសហប្រតិបត្តិការជាមួយសមាគមធនាគារកណ្ដាលនៃក្រុមប្រទេសនិយាយភាសាបារាំង (ហ្វ្រង់កូហ្វូន) កាន់តែមានប្រសិទ្ធភាព និងជិតស្និទ្ធបន្ថែមទៀត ជាពិសេស ការផ្លាស់ប្ដូរបទពិសោធន៍និងព័ត៌មានទៅវិញទៅមក និងស្វែងរកជំនួយឧបត្ថម្ភពីសំណាក់ធនាគារកណ្ដាលជាដៃគូ ។

ដើម្បីពង្រឹងនូវកិច្ចសហប្រតិបត្តិការជាមួយបណ្ដាសមាជិកនៃហ្វ្រង់កូហ្វូន គណៈប្រតិភូជាន់ខ្ពស់នៃធនាគារជាតិនៃកម្ពុជា ដែលដឹកនាំដោយឯកឧត្តមទេសាភិបាល បានទៅចូលរួមសន្និសីទថ្នាក់ទេសាភិបាលធនាគារកណ្ដាលនៃក្រុមប្រទេសនិយាយភាសាបារាំង (ហ្វ្រង់កូហ្វូន) ប្រចាំឆ្នាំលើកទី១៩ ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៣-២៦ ខែឧសភា ឆ្នាំ២០១២ នៅប្រទេសម៉ូរីស ។

**១.៦- សមាគមឥណទានកសិកម្មជនបទនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក** ( APRACA )

ធនាគារជាតិនៃកម្ពុជា បានចូលជាសមាជិករបស់សមាគមឥណទានកសិកម្មជនបទអាស៊ីប៉ាស៊ីហ្វិក តាំងពីឆ្នាំ១៩៩៩ ។ ការចូលជាសមាជិកភាពនៅក្នុងសមាគមឥណទានកសិកម្មជនបទអាស៊ីប៉ាស៊ីហ្វិក បានផ្ដល់ឱកាសជាច្រើនដល់ធនាគារជាតិនៃកម្ពុជាក្នុងការចូលរួមសន្និសីទ វេទិកាពិភាក្សា និងការបណ្ដុះបណ្ដាលជាច្រើន នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ។ កាលពីថ្ងៃទី៣០ ខែឧសភា ដល់ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១២ ធនាគារជាតិនៃកម្ពុជាមានកិត្តិយសធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទថ្នាក់តំបន់ស្តីពី "ការពង្រឹងសមត្ថភាពកសិករខ្នាតតូចតាមរយៈភាពច្នៃប្រឌិតនៃហិរញ្ញវត្ថុជនបទ" ដែលមានការចូលរួមពីភ្ញៀវជាតិ និងអន្តរជាតិ មកពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍ ប្រមាណ ២០០ នាក់ ។ ជាមួយគ្នានេះ ក៏មានការរៀបចំកិច្ចប្រជុំគណៈកម្មការប្រតិបត្តិលើកទី៦១ និងមហាសន្និបាតលើកទី១៨ របស់សមាគមឥណទានកសិកម្មជនបទអាស៊ីប៉ាស៊ីហ្វិក ផងដែរ ។

តាមការអនុម័តរបស់មហាសន្និបាតលើកទី ១៨ របស់សមាគមឥណទានកសិកម្មជនបទអាស៊ីប៉ាស៊ីហ្វិក ធនាគារជាតិនៃកម្ពុជាត្រូវបានជ្រើសតាំងជាប្រធានរបស់សមាគមនេះ ក្នុងអណត្តិរយៈពេល២ឆ្នាំ គិតចាប់ពីខែមិថុនា ឆ្នាំ២០១២ ដល់ខែឧសភា ឆ្នាំ២០១៤ ។

**២- ទំនាក់ទំនងទ្វេភាគី**

ទន្ទឹមនឹងជំនួយពហុភាគីធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់លើការកសាង និងពង្រឹងនូវទំនាក់ទំនងទ្វេភាគីជាមួយបណ្តាធនាគារកណ្តាល និងបណ្តាស្ថាប័នអន្តរជាតិមួយចំនួនទៀត ដើម្បីសម្រេចបាននូវគោលដៅរួមគឺ ការពង្រឹងប្រព័ន្ធធនាគារជាទូទៅនៅក្នុងបរិស្ថានសេដ្ឋកិច្ចពិភពលោកមួយដែលកាន់តែមានលក្ខណៈជាសកល ។

ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី ធនាគារជាតិនៃកម្ពុជាតែងតែបានទទួលជំនួយបច្ចេកទេសពីសំណាក់ធនាគារកណ្តាលអាឡឺម៉ង់ លើផ្នែកបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីរួមចំណែកលើកកម្ពស់សមត្ថភាពមន្ត្រីរបស់ធនាគារជាតិនៃកម្ពុជា ក្នុងទិសដៅអភិវឌ្ឍប្រព័ន្ធធនាគារឲ្យកាន់តែរឹងមាំថែមទៀត ។ ជាក់ស្តែង ក្នុងឆមាសទី១ ឆ្នាំនេះ ធនាគារកណ្តាលអាឡឺម៉ង់បានផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាលើប្រធានបទស្តីពី "ការរក្សាស្ថិរភាពហិរញ្ញវត្ថុក្នុងបរិបទសេដ្ឋកិច្ចទំហំតូច និងបើកចំហ" ដែលបានប្រព្រឹត្តទៅនៅធនាគារជាតិនៃកម្ពុជា ពីថ្ងៃទី២១-២៣ ខែកុម្ភៈ ឆ្នាំ២០១២ ។

កិច្ចសហប្រតិបត្តិការជាមួយធនាគាររៀតណាមត្រូវបានពង្រឹងបន្ថែមទៀត តាមរយៈកិច្ចប្រជុំទ្វេភាគី និងការចុះហត្ថលេខាលើអនុស្សរណៈយោគយល់ចំនួនពីរ គឺ ១- អនុស្សរណៈយោគយល់ស្តីពី ការផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និង ២- អនុស្សរណៈយោគយល់ស្តីពី ការបណ្តុះបណ្តាល ដែលបានធ្វើនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ។

ជាមួយគ្នានេះដែរការបង្កើនទំនាក់ទំនងជាមួយអាជ្ញាធររូបិយវត្ថុសិង្ហបុរីត្រូវបានធ្វើឡើងតាមរយៈកិច្ចប្រជុំពិភាក្សាការងារជាលក្ខណៈទ្វេភាគី កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ នៅសណ្ឋាគារសូហ្វីតែលរាជធានីភ្នំពេញ ។

## សន្និដ្ឋាន

ជារួម ស្ថានភាពសេដ្ឋកិច្ចកម្ពុជាមានភាពល្អប្រសើរ បន្ទាប់ពីរងឥទ្ធិពលនៃវិបត្តិពិភពលោកកាលពីឆ្នាំ ២០០៨-២០០៩ កន្លងទៅ ហើយទៅអនាគតក៏នឹងមានមូលដ្ឋានកំណើនរឹងមាំប្រកបដោយសុទិដ្ឋិនិយមផង ដែរ ខណៈដែលសេដ្ឋកិច្ចពិភពលោកកំពុងប្រឈមនឹងហានិភ័យនៃការធ្លាក់ចុះ និងមានកំណើនទាប ។ ភាព រឹងមាំនេះសម្រេចបានដោយសារាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយសេដ្ឋកិច្ចយ៉ាងត្រឹមត្រូវ ក្នុង ការធ្វើពិពិធកម្មវិស័យផលិតកម្ម ពិសេស វិស័យកសិកម្ម និងពិពិធកម្មទីផ្សារនាំចេញ គួបផ្សំនឹងគោល-នយោបាយម៉ាក្រូសេដ្ឋកិច្ច និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តទូទាំងប្រទេស ។ ស្ថានភាពនេះពិតជា បានជួយរួមចំណែកគាំទ្រដល់ការរីកលូតលាស់លើគ្រប់វិស័យ ។ សមិទ្ធផលទាំងនេះ គួបផ្សំនឹងបរិយាកាស នយោបាយល្អ និងសុវត្ថិភាពសន្តិសុខសង្គមផង អំណោយផលល្អដល់ការអនុវត្តគោលនយោបាយសេដ្ឋកិច្ច ដើម្បីជំរុញកំណើន សមធម៌ការងារ និងប្រសិទ្ធភាព ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។ សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងបន្តមានកំណើនល្អនៅឆមាសទី២ ឆ្នាំ២០១២ នេះ និងក្នុងរយៈពេល មធ្យម ។

នៅក្នុងបរិការណ៍នេះ ធនាគារជាតិនៃកម្ពុជាដែលជាធនាគារកណ្តាលរបស់ប្រទេស បានយកចិត្តទុក ដាក់យ៉ាងម៉ត់ចត់ ក្នុងការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព ដោយរក្សាបាននូវស្ថិរភាពអត្រាប្តូរប្រាក់ ស្ថិរភាពថ្លៃ និងគ្រប់គ្រងអតិផរណាឲ្យស្ថិតក្នុង កម្រិតទាប ។ ហេតុដូចនេះ កំណើនការផ្គត់ផ្គង់រូបិយវត្ថុនឹងត្រូវរក្សាក្នុងកម្រិតដែលអំណោយផលដល់ កំណើនសេដ្ឋកិច្ច ខណៈធានាការសម្រេចបាននូវអត្រាអតិផរណាទាប ។ ជាមួយគ្នានេះ នៅក្នុងលក្ខខណ្ឌ ដែលសេដ្ឋកិច្ចមានដុល្លារូបនីយកម្ម ការរក្សាតម្លៃរូបិយវត្ថុជាតិ នៅតែជាយន្តការដ៏សំខាន់រួមចំណែកចំពោះ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។ ម្យ៉ាងទៀត នៅចំពោះមុខការវិវត្តន៍ទីផ្សារហិរញ្ញវត្ថុពិភពលោកដ៏តឹងតែងនៅឡើយ ធនាគារជាតិនៃកម្ពុជាបន្តគ្រប់គ្រងទុនបម្រុង ដោយឈរលើគោលការណ៍ សុវត្ថិភាព និងសន្ទនីយភាព ព្រម ទាំងបានគរពូនឲ្យមានទំហំសមស្របសម្រាប់បម្រើគោលនយោបាយរូបិយវត្ថុ និងស្របតាមតម្រូវការរក្សា ស្ថានភាពល្អនៃជញ្ជីងទូទាត់ ។

ទន្ទឹមនេះ វិស័យធនាគារនៅកម្ពុជា បានបង្ហាញស្ថិរភាពគួរឲ្យកត់សម្គាល់ និងសម្រេចបាននូវវឌ្ឍន-ភាពមួយកម្រិតទៀត ដែលឆ្លុះបញ្ចាំងជាអាទិ៍ តាមរយៈកំណើនជាបន្តបន្ទាប់នៃសកម្មភាពវិស័យធនាគារ ស្ថិរភាពទីផ្សារប្តូរប្រាក់ ការបង្កើនប្រសិទ្ធភាពប្រព័ន្ធទូទាត់និងផាត់ទាត់ ការលើកកម្ពស់ក្របខ័ណ្ឌច្បាប់ និង ការពង្រឹងប្រតិបត្តិការតាមបទប្បញ្ញត្តិជាធរមាន ។ ការរីកចម្រើននៃសកម្មភាពវិស័យធនាគារ ប្រសិទ្ធភាព ប្រព័ន្ធទូទាត់និងផាត់ទាត់ ការពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិដែលធនាគារជាតិនៃកម្ពុជាដាក់ចេញ គឺជា កញ្ចក់ឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងអនុវត្តភារកិច្ចប្រកបដោយប្រសិទ្ធភាព និងមានការទទួលខុសត្រូវរបស់ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាបញ្ញត្តិករ និងជាអាជ្ញាធរលើប្រព័ន្ធធនាគារ ប្រព័ន្ធទូទាត់និងផាត់ទាត់ ស្រប តាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រាជរដ្ឋាភិបាល ។

ដោយឡែក ចំពោះសុខុមាលភាពធនាគារវិញ ធនាគារជាតិនៃកម្ពុជាបន្តខិតខំលើកកម្ពស់សមត្ថភាពនៃការត្រួតពិនិត្យជាប់ជាប្រចាំ និងបានរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិម៉ាក្រូនិងមីក្រូប្រុងប្រយ័ត្ន ស្របតាមវិសាលភាព និងទំហំសកម្មភាពធនាគារនាពេលបច្ចុប្បន្ន ដើម្បីធានានូវការចូលរួមឲ្យរលូន ប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងខណៈដែលទីផ្សារទុន ត្រូវបានបើកដំណើរការកាលពីពេលថ្មីៗកន្លងទៅនេះផងដែរ ។

ទន្ទឹមនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនឹងជួយបង្កើនការរួមចំណែកជាលំដាប់ចំពោះការរីកចម្រើននៃសេដ្ឋកិច្ចជាតិ តាមរយៈការពង្រីកការផ្តល់សេវាដល់អ្នកប្រើប្រាស់កាន់តែទូលំទូលាយ ។ ជាពិសេស គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចាំបាច់ត្រូវមានគោលនយោបាយ និងយន្តការគ្រប់គ្រងផ្ទៃក្នុងសមស្របផងដែរសម្រាប់គ្រប់គ្រងហានិភ័យ ពីព្រោះការរក្សាស្ថិរភាពហិរញ្ញវត្ថុមិនមែនមានន័យត្រឹមតែជាការដាក់ចេញនូវវិធានការ និងបទបញ្ញាប្រុងប្រយ័ត្ន ដោយអាជ្ញាធរត្រួតពិនិត្យនិងបញ្ញត្តិករប៉ុណ្ណោះទេ ប៉ុន្តែត្រូវទាមទារនូវឥរិយាបទល្អនិងប្រតិបត្តិការដ៏ប្រុងប្រយ័ត្នពីសំណាក់គ្រឹះស្ថានហិរញ្ញវត្ថុផ្ទាល់ផងដែរ ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាសង្ឃឹមយ៉ាងមុតមាំថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនឹងបំពេញតួនាទីអន្តរការិយកម្មរបស់ខ្លួនបានយ៉ាងល្អ ខណៈដែលធនាគារជាតិនៃកម្ពុជានឹងខិតខំបន្ថែមទៀត ដើម្បីធ្វើឲ្យបរិស្ថានហិរញ្ញវត្ថុកាន់តែមានភាពអំណោយផលចំពោះប្រតិបត្តិករ និងអ្នកចូលរួមទាំងឡាយក្នុងវិស័យនេះ ។ លើសពីនេះ នៅចំពោះមុខការវិវត្តដ៏លឿន និងភាពកាន់តែប្រទាក់ក្រឡានៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា ធនាគារជាតិនៃកម្ពុជានឹងខិតខំបន្ថែមទៀតក្នុងការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីជាមួយធនាគារកណ្តាលបរទេសក្នុងតំបន់ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិលើវិស័យហិរញ្ញវត្ថុ ដើម្បីពង្រឹងបណ្តាញសុវត្ថិភាពហិរញ្ញវត្ថុសំដៅរក្សាសុវត្ថិភាពហិរញ្ញវត្ថុក្នុងតំបន់ គាំទ្រដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងអភិវឌ្ឍកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព ។

# ខ- ទិសដៅការងារឆមាសទី២ ឆ្នាំ២០១២

## ទិសដៅការងារឆមាសទី២ ឆ្នាំ២០១២

ទោះបីជាស្ថានភាពសេដ្ឋកិច្ចពិភពលោកនៅមិនទាន់មានភាពនឹងនរដោយសារស្ថានភាពសេដ្ឋកិច្ចនៅតំបន់អឺរ៉ុបនៅជាប់គាំងក្នុងវិបត្តិបំណុលអធិបតេយ្យ និងអត្រានិកម្មភាពមានកម្រិតខ្ពស់ ក៏សេដ្ឋកិច្ចកម្ពុជានៅរក្សាបានកំណើនសេដ្ឋកិច្ចរឹងមាំគួរឲ្យកត់សម្គាល់នៅក្នុងឆមាសទី១នេះ ។ នៅក្នុងបរិការនេះ រាជរដ្ឋាភិបាលបានព្យាករកំណើនសេដ្ឋកិច្ចនៅឆ្នាំ២០១២ ក្នុងកម្រិត ៧% ។ ដើម្បីរួមចំណែកឲ្យសម្រេចទិសដៅ និងរក្សាឲ្យបាននូវកំណើនប្រកបដោយចីរភាពនេះ ធនាគារជាតិនៃកម្ពុជាបានបន្តអនុវត្តគោលនយោបាយរូបិយវត្ថុយ៉ាងប្រុងប្រយ័ត្ន ដើម្បីរក្សាស្ថិរភាពថ្លៃ ។ ទិសដៅនៃការងារសំខាន់ៗសម្រាប់ឆមាសទី២ ឆ្នាំ២០១២ មានដូចខាងក្រោម ៖

**១. ការងាររូបិយវត្ថុ** (បម្រែបម្រួលជាភាគរយប្រចាំឆ្នាំ)

| | |
|---|---|
| - រូបិយវត្ថុទូទៅ (M2) | ១៨% |
| - រូបិយវត្ថុក្នុងចរាចរណ៍ | ៧% |
| - ប្រាក់បញ្ញើជារូបិយប័ណ្ណ | ១៩% |
| - ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា | -១៥% |
| - ឥណទានសុទ្ធចំពោះរាជរដ្ឋាភិបាលពីវិស័យឯកជន | -២៧% |
| - ទុនបម្រុងផ្លូវការសុទ្ធ | ១៣% ។ |

**២. ការងារគ្រប់គ្រងអត្រាប្តូរប្រាក់ និងទុនបម្រុង**

- ពិនិត្យឡើងវិញនូវប្រកាសពាក់ព័ន្ធនឹងការគ្រប់គ្រងអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ
- ពង្រឹងការតាមដានព័ត៌មានពីប្រភពផ្សេងៗដើម្បីជាមូលដ្ឋានក្នុងការកំណត់អត្រាប្តូរប្រាក់ផ្លូវការ
- បន្តរៀបចំ "គោលនយោបាយវិនិយោគ" និង "សេចក្តីណែនាំការវិនិយោគ" និង
- រៀបចំលំហូរការងារសម្រាប់ការគ្រប់គ្រងទុនបម្រុង ។

**៣. ការងារអភិវឌ្ឍន៍ប្រព័ន្ធទូទាត់**

- ជំរុញការរៀបចំឡើងវិញនូវ "វិធាននិងនីតិវិធីសម្រាប់សភាផាត់ទាត់" ស្របតាមប្រព័ន្ធថ្មី
- រៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រតិបត្តិការ និងសេវាទូទាត់សងប្រាក់ និង
- រៀបចំឯកសារស្តីពីគោលការណ៍សម្រាប់ការទូទាត់តាមទូរស័ព្ទចល័ត ។

**៤. ការងារត្រួតពិនិត្យ**

- បន្តការចុះត្រួតពិនិត្យដល់ទីកន្លែងលើគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុតាមផែនការកំណត់
- បន្តរៀបចំកែលម្អច្បាប់ប្រកាស បទប្បញ្ញត្តិនិងសារាចរណែនាំនានា និង
- បន្តពិនិត្យ និងតាមដាននូវការអនុវត្តបទប្បញ្ញត្តិជាធរមានក្នុងការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងបន្តសិក្សាស្រាវជ្រាវនិងរៀបចំនូវបទប្បញ្ញត្តិថ្មីអនុលោមតាមស្តង់ដារ Basel និងនិយាមជាអន្តរជាតិ ។

## ៥. ការងារប្រតិបត្តិការ

- សិក្សារៀបចំប្រព័ន្ធចុះបញ្ជីនិងគ្រប់គ្រងមូលបត្រអាចជួញដូរបានចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា (Tradable Securities)
- បន្តការអភិវឌ្ឍនូវកម្មវិធីប្រព័ន្ធជាត់ទាត់ក្នុងដំណាក់កាលពេញលេញ (Full Solution) ដែលនឹងដាក់ឲ្យអនុវត្តនាពេលដ៏ខ្លីខាងមុខ ។

## ៦. ការងារបោះផ្សាយ និងឃ្លាំងបេឡា

- បន្តពង្រឹងការងារបម្រើអតិថិជនក្នុងការបើកសាច់ប្រាក់និងបង់សាច់ប្រាក់នៅបញ្ជរបេឡាឲ្យបានកាន់តែប្រសើរឡើង
- បន្តពង្រឹងការងារថែរក្សានិងការពារឃ្លាំងប្រាក់
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច រាំងខ្ទប់ចរាចរណ៍ក្រដាសប្រាក់ក្លែងក្លាយ និង
- បន្តពង្រឹងការងារដឹកជញ្ជូនធនបត្រ ។

## ៧. ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច

- បន្តចុះធ្វើសវនកម្មនៅនាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា នាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានគណនេយ្យ និងសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ចាម ព្រមទាំងចុះពិនិត្យតាមដានការអនុវត្តតាមអនុសាសន៍ដែលបានលើកឡើងក្នុងឆ្នាំ២០១១
- បន្តចុះពង្រឹងការងារ និងធ្វើអធិការកិច្ចនៅសាខាធនាគារជាតិនៃកម្ពុជា ។

## ៨. ការងារគ្រប់គ្រងសាខា

- ពង្រឹងប្រតិបត្តិការសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តឲ្យស្របតាមការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ចក្នុងតំបន់ទាំងនោះ
- សហការជាមួយអាជ្ញាធរមូលដ្ឋានប្រចាំសាខារាជធានី-ខេត្ត ដើម្បីជំរុញការប្រើប្រាស់ប្រាក់រៀលឲ្យកាន់តែទូលំទូលាយ ។

## ៩. ការងារព័ត៌មានវិទ្យា

- ពង្រឹងប្រព័ន្ធធនាគារស្នូលទាំងនៅទីស្នាក់ការកណ្តាល និងតាមបណ្តាសាខាខេត្ត ឲ្យមានដំណើរការដោយរលូន មានសុវត្ថិភាព និងមានប្រសិទ្ធភាព
- បន្តអនុវត្តគម្រោងអភិវឌ្ឍន៍ប្រព័ន្ធជាតិទូទាត់សងប្រាក់ ។

## ១០. ការងារបណ្តុះបណ្តាល

- សហការ និងរៀបចំកម្មវិធីបណ្តុះបណ្តាលសិក្ខាសាលានិងកិច្ចប្រជុំផ្សេងៗនៅធនាគារជាតិនៃកម្ពុជា
- បន្តពង្រឹងសមត្ថភាពមន្ត្រីបុគ្គលិក តាមរយៈការចាត់បញ្ជូនមន្ត្រីបុគ្គលិកទៅចូលរួមសិក្ខាសាលា និងវគ្គសិក្សានានានៅក្នុង និងក្រៅប្រទេស

- ត្រៀមរៀបចំប្រឡងជ្រើសរើសបុគ្គលិកដែលមានគុណវុឌ្ឍិ ស្របតាមការរីកចម្រើនរបស់ធនាគារជាតិនៃកម្ពុជា
- រៀបចំកែលម្អកម្មវិធីសិក្សា និងធ្វើបច្ចុប្បន្នកម្មលើមុខវិជ្ជាសិក្សាឲ្យស្របតាមការអភិវឌ្ឍរីកចម្រើនរបស់ប្រព័ន្ធធនាគារ
- លើកកម្ពស់ការកសាងសមត្ថភាពរបស់មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា ឲ្យស្របនឹងនិន្នាការនៃសមាហរណកម្មវិស័យធនាគារនិងហិរញ្ញវត្ថុក្នុងតំបន់ និងពិភពលោក ។

**១១. ការងារទំនាក់ទំនងអន្តរជាតិ**

- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូរពហុភាគី និងទ្វេភាគី ។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ ១

## តារាង១ - ការវិវត្តន៍នៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវា

| **សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់** (CPI) **និងសន្ទស្សន៍ថ្លៃតាមក្រុមមុខទំនិញ** | **២០១១** | | **២០១២** | | | | | |
|---|---|---|---|---|---|---|---|---|
| ( តុលា-ធ្នូ ២០០៦=១០០ ) | **មិថុនា** | **ធ្នូ** | **មករា** | **កុម្ភៈ** | **មីនា** | **មេសា** | **ឧសភា** | **មិថុនា** |
| **មុខទំនិញគ្រប់មុខ** | **១៤៤,៦៩** | **១៤៥,០៣** | **១៤៦,៥០** | **១៤៧,០២** | **១៤៧,៩២** | **១៤៨,៧២** | **១៤៧,១២** | **១៤៧,៣៣** |
| អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | ១៦៣,២៨ | ១៦៣,៦០ | ១៦៥,៦៣ | ១៦៥,០៩ | ១៦៥,៤៧ | ១៦៦,៩០ | ១៦៥,៥៧ | ១៦៧,០២ |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ១២៣,១៨ | ១២៣,៧២ | ១២៤,៦៤ | ១២៤,៣៣ | ១២៤,៣២ | ១២៤,៤៨ | ១២៥,៦៦ | ១២៦,២៤ |
| សម្លៀកបំពាក់ និងស្បែកជើង | ១១៧,០០ | ១១៨,០៩ | ១១៨,៧៥ | ១១៩,៩២ | ១២០,៥៨ | ១២១,៣៣ | ១២០,៨៣ | ១២១,៤៨ |
| ផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | ១២៤,៦១ | ១២៣,៦១ | ១២៤,៤៤ | ១២៥,២៩ | ១២៧,៩៥ | ១២៧,៩១ | ១២៦,៤២ | ១២៥,៣៥ |
| គ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់គ្រួសារនិងការថែទាំផ្ទះជាប្រចាំ | ១២៣,០៣ | ១២៤,៤៧ | ១២៥,៣៧ | ១២៧,២៤ | ១២៧,៣០ | ១២៦,៩៧ | ១២៧,០៧ | ១២៧,៤០ |
| សុខាភិបាល | ១១៦,៨៧ | ១១៥,៤០ | ១១៦,១១ | ១១៥,៦៥ | ១១៦,៥៩ | ១១៦,២៤ | ១១៦,៦១ | ១១៦,៤៨ |
| ការដឹកជញ្ជូន | ១២៧,៣៩ | ១២៨,២២ | ១២៩,៧៣ | ១៣២,៦៤ | ១៣៤,៤៩ | ១៣៤,៥៣ | ១៣១,០៧ | ១២៧,០១ |
| គមនាគមន៍ | ៧២,៦០ | ៧២,៩៨ | ៧២,២២ | ៧២,១៤ | ៧១,៧២ | ៧១,៨៣ | ៧១,៩៥ | ៧១,៩៩ |
| ការកម្សាន្ត និងវប្បធម៌ | ១០២,០៨ | ១០២,៣៤ | ១០២,៣៤ | ១០១,៩៩ | ១០២,៥១ | ១០២,៦៥ | ១០២,៨៧ | ១០៣,៦២ |
| ការសិក្សា | ១៣៩,៥៦ | ១៤២,៦៩ | ១៤២,៦៩ | ១៤២,៦៩ | ១៤២,៦៩ | ១៤២,៦៩ | ១៤២,៦៩ | ១៤២,៦៩ |
| ភោជនីយដ្ឋាន | ១៨៨,០២ | ១៨៩,៣៤ | ១៩១,៥១ | ១៩៤,៨០ | ១៩៤,០៦ | ១៩៦,៣៣ | ១៩១,២៩ | ១៩៤,៨១ |
| ទំនិញ និងសេវាកម្មផ្សេងៗ | ១៤៥,១១ | ១៥១,២៩ | ១៥២,១១ | ១៥៣,៣៣ | ១៥៣,៦៣ | ១៥៤,៧៦ | ១៥២,១៨ | ១៥១,១៨ |
| | | | **បម្រែបម្រួលជាភាគរយប្រចាំខែ** | | | | | |
| **មុខទំនិញគ្រប់មុខ** | **០,៥០** | **-០,៨៨** | **១,០១** | **០,៣៦** | **០,៦១** | **០,៥៤** | **-១,០៨** | **០,១៤** |
| អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | ០,៧២ | -១,៤៧ | ១,២៤ | -០,៣៣ | ០,២៣ | ០,៨៧ | -០,០៨ | ០,៨៨ |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ០,៣៧ | -០,១៧ | ០,៧៥ | -០,២៥ | -០,០១ | ០,១៣ | ០,៩៥ | ០,៤៦ |
| សម្លៀកបំពាក់ និងស្បែកជើង | ០,៧៩ | -០,៧៩ | ០,៥៦ | ០,៩៩ | ០,៥៥ | ០,៦២ | -០,៤២ | ០,៥៤ |
| ផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | -០,០១ | ០,០៩ | ០,៦៧ | ០,៦៨ | ២,១៣ | -០,០៣ | -១,១៧ | -០,៨៤ |
| គ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់គ្រួសារនិងការថែទាំផ្ទះជាប្រចាំ | ០,០៣ | -០,២៧ | ០,៧៣ | ១,៤៩ | ០,០៤ | -០,២៥ | ០,០៨ | ០,២៦ |
| សុខាភិបាល | -១,០០ | -១,៣៤ | ០,៦១ | -០,៣៩ | ០,៨១ | -០,៣០ | ០,៣២ | -០,១២ |
| ការដឹកជញ្ជូន | ០,៧៤ | ០,២៤ | ១,១៨ | ២,២៤ | ១,៤០ | ០,០៣ | -២,៥៧ | -៣,១០ |
| គមនាគមន៍ | -០,៨១ | ០,៥៩ | -១,០៤ | -០,១២ | -០,៥៨ | ០,១៦ | ០,១៦ | ០,០៦ |
| ការកម្សាន្ត និងវប្បធម៌ | -០,២៨ | ០,១៩ | ០,០០ | -០,៣៤ | ០,៥១ | ០,១៤ | -០,២១ | ០,៧៣ |
| ការសិក្សា | -០,៦៣ | ០,៣៦ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ |
| ភោជនីយដ្ឋាន | ០,៩៨ | -០,៧៥ | ១,១៥ | ១,៧២ | -០,៣៨ | ១,១៧ | -២,៥៧ | ១,៨៤ |
| ទំនិញ និងសេវាកម្មផ្សេងៗ | ០,៨៨ | -១,៦០ | ០,៥៤ | ០,៨០ | ០,២០ | ០,៧៣ | -១,៦៦ | -០,៦៥ |
| | | | **បម្រែបម្រួលជាភាគរយឆ្នាំលើឆ្នាំ** | | | | | |
| **មុខទំនិញគ្រប់មុខ** | **៧,០៦** | **៤,៩១** | **៥,៧៧** | **៥,៤២** | **៥,៣៥** | **៤,៧៨** | **២,១៩** | **១,៨៣** |
| អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | ៨,៩០ | ៦,១៦ | ៧,៧៣ | ៦,៧២ | ៦,២០ | ៥,៨១ | ២,១២ | ២,២៩ |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ០,៤៤ | ១,៥០ | ១,៥៩ | ១,១៥ | ១,០៣ | ០,៩៨ | ២,៤០ | ២,៤៩ |
| សម្លៀកបំពាក់ និងស្បែកជើង | ២,៩០ | ៣,០៤ | ៣,៣០ | ៥,០៨ | ៤,៤២ | ៤,៩០ | ៤,០៨ | ៣,៨២ |
| ផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | ៤,៥៥ | ២,១៣ | ១,៩៤ | ១,៨០ | ៣,៦២ | ២,៦៣ | ១,៤៤ | ០,៥៩ |
| គ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់គ្រួសារនិងការថែទាំផ្ទះជាប្រចាំ | ២,២៣ | ២,២២ | ២,២៩ | ៤,១០ | ៣,៩០ | ៣,២៣ | ៣,៣២ | ៣,៥៥ |
| សុខាភិបាល | ០,៩៥ | -១,៤៤ | -០,៤៧ | -១,១៣ | -០,៥៤ | -១,១២ | -១,២៣ | -០,៣៤ |
| ការដឹកជញ្ជូន | ៧,៤៦ | ៦,៣២ | ៦,៨៥ | ៨,២៨ | ៨,១៩ | ៥,៨៥ | ៣,៦៥ | -០,៣០ |
| គមនាគមន៍ | ១,៥៩ | -០,៥១ | -២,១៩ | -១,៨៧ | -២,១៤ | -១,៥៨ | -១,៧០ | -០,៨៤ |
| ការកម្សាន្ត និងវប្បធម៌ | -១,៧៦ | -១,១៩ | -០,៩៨ | -០,៨៨ | -០,១៨ | ០,០៣ | ០,៤៩ | ១,៥០ |
| ការសិក្សា | -០,៤៣ | ១,៨០ | ១,៨០ | ១,៨០ | ១,៨០ | ១,៥៥ | ១,៥៩ | ២,២៤ |
| ភោជនីយដ្ឋាន | ១០,៩៤ | ៧,៥១ | ៧,២៧ | ៦,៧៦ | ៥,៨៣ | ៦,៤៥ | ២,៧៣ | ៣,៦១ |
| ទំនិញ និងសេវាកម្មផ្សេងៗ | ៩,៣០ | ៨,៥៣ | ១០,០៣ | ៩,៦០ | ៨,៥១ | ៨,៣៩ | ៥,៧៩ | ៤,១៩ |
| | | | **សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គិតជាមធ្យមរំកិលបីខែ** | | | | | |
| **មុខទំនិញគ្រប់មុខ** | **១៤៣,៥៣** | **១៤៦,២១** | **១៤៥,៩៥** | **១៤៦,១៨** | **១៤៧,១៥** | **១៤៧,៨៩** | **១៤៧,៩២** | **១៤៧,៧៣** |
| បម្រែបម្រួលប្រចាំខែជាភាគរយ | **៦,២៧** | **៥,២៨** | **៥,៤៥** | **៥,៣៧** | **៥,៥១** | **៥,១៨** | **៤,០៩** | **២,៩២** |
| | | | **សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គិតជាមធ្យមរំកិលដប់ពីរខែ** | | | | | |
| **មុខទំនិញគ្រប់មុខ** | **១៣៩,៧០** | **១៤៣,៨៤** | **១៤៤,៥០** | **១៤៥,១៣** | **១៤៥,៧៦** | **១៤៦,៣២** | **១៤៦,៥៩** | **១៤៦,៨១** |
| បម្រែបម្រួលប្រចាំខែជាភាគរយ | **៣,៧៦** | **៥,៤៨** | **៥,៦៨** | **៥,៨១** | **៥,៩៤** | **៥,៩០** | **៥,៥៣** | **៥,០៨** |

***ប្រភព*** *: វិទ្យាស្ថានជាតិស្ថិតិ*

# តារាង២ - ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ (អត្រានិញ្ញចុងខែ)

| រូបិយប័ណ្ណ | ២០១១ | | | | | | | ២០១២ | | | | | | បម្រែបម្រួល% មិថុនា-១២ /មិថុនា-១១ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | |
| អេសដេអែរ | ៦.៥៧៩ | ៦.៥៧៣ | ៦.៥៨៩ | ៦.៤០០ | ៦.៥២៩ | ៦.២៧២ | ៦.១៨១ | ៦.២៨៩ | ៦.២៤៣ | ៦.១៧៣ | ៦.២៣៦ | ៦.១៤៥ | ៦.១៤១ | -៦,៧ |
| **អាស៊ី** | | | | | | | | | | | | | | |
| ដុល្លារ-អូស្ត្រាលី | ៤.៤០៦ | ៤.៥០៦ | ៤.៣៦៩ | ៤.០០០ | ៤.៣៨៧ | ៤.០៤៣ | ៤.០៩៨ | ៤.៣០១ | ៤.៣៣៤ | ៤.១៩៥ | ៤.២០៥ | ៣.៩៣៥ | ៤.០៧៥ | -៧,៥ |
| ដុល្លារ-ហុងកុង | ៥២៩ | ៥២៦ | ៥២៥ | ៥២៤ | ៥២៨ | ៥១៧ | ៥២០ | ៥២៤ | ៥១៨ | ៥១៤ | ៥១៩ | ៥២៣ | ៥២៤ | -០,១ |
| យ៉េន-ជប៉ុន | ៥១,០០ | ៥២,៦៨ | ៥៣,៣៨ | ៥៣,២២ | ៥៤,០១ | ៥១,៦៤ | ៥២,០១ | ៥៣,២៦ | ៤៩,៨៥ | ៤៨,៦២ | ៥០,០៩ | ៥១,៤៩ | ៥១,២៦ | ០,៥ |
| វ៉ុន-កូរ៉េ | ៣,៨៤ | ៣,៩០ | ៣,៨២ | ៣,៤៦ | ៣,៧១ | ៣,៥៣ | ៣,៥០ | ៣,៦០ | ៣,៥៨ | ៣,៥១ | ៣,៥៥ | ៣,៤៣ | ៣,៥១ | -៨,៦ |
| ដុល្លារ-ញ៉ូស៊ីឡែន | ៣.៤០៩ | ៣.៥៦៧ | ៣.៤៨៤ | ៣.១៣៨ | ៣.៣៧២ | ៣.០៧៦ | ៣.១១៩ | ៣.៣២៨ | ៣.៣៧៤ | ៣.២៦៤ | ៣.៣១១ | ៣.០៥០ | ៣.១៩៤ | -៦,៣ |
| យ៉ន់ចិន | ៦៣៧ | ៦៣៦ | ៦៤១ | ៦៣៧ | ៦៤៥ | ៦៣២ | ៦៣៩ | ៦៤១ | ៦៣៧ | ៦៣៣ | ៦៣៨ | ៦៣៩ | ៦៣៩ | ០,៣ |
| ដុល្លារ-តៃវ៉ាន់ | ១៤២ | ១៤២ | ១៤១ | ១៣៤ | ១៣៦ | ១៣៣ | ១៣៣ | ១៣៧ | ១៣៦ | ១៣៥ | ១៣៧ | ១៣៧ | ១៣៦ | -៤,២ |
| **អាស៊ាន** | | | | | | | | | | | | | | |
| រ៉ូពី-ឥណ្ឌូណេស៊ី | ០,៤៧៨ | ០,៤៨៣ | ០,៤៧៩ | ០,៤៥៤ | ០,៤៦៤ | ០,៤៤០ | ០,៤៤៥ | ០,៤៥២ | ០,៤៤០ | ០,៤៣៥ | ០,៤៣៨ | ០,៤៣០ | ០,៤២៨ | -១០,៥ |
| រីងហ្គីត-ម៉ាឡេស៊ី | ១.៣៦២ | ១.៣៨៩ | ១.៣៧៤ | ១.២៨១ | ១.៣៣៤ | ១.២៧០ | ១.២៧៤ | ១.៣៣០ | ១.៣៣៩ | ១.៣០០ | ១.៣២៦ | ១.២៧៦ | ១.២៧២ | -៦,៦ |
| ប៉េសូ-ហ្វីលីពីន | ៩៤,៦០ | ៩៦,៩៣ | ៩៦,៦២ | ៩៣,៥៤ | ៩៥,៧២ | ៩២,៣៥ | ៩២,១០ | ៩៤,២៧ | ៩៣,៥៩ | ៩២,៩០ | ៩៤,៩២ | ៩៣,៣៨ | ៩៥,៨៥ | ១,៣ |
| ដុល្លារ-សាំងហ្គាពួរ | ៣.៣៣៩ | ៣.៤០៨ | ៣.៣៩២ | ៣.១៥០ | ៣.២៩៧ | ៣.១១០ | ៣.១០៨ | ៣.២២៩ | ៣.២១៥ | ៣.១៧៣ | ៣.២៥០ | ៣.១៥២ | ៣.១៧៣ | -៥,០ |
| បាត-ថៃ | ១៣៤ | ១៣៨ | ១៣៦ | ១៣១ | ១៣៤ | ១២៩ | ១២៧ | ១៣០ | ១៣២ | ១២៩ | ១៣១ | ១២៧ | ១២៧ | -៥,២ |
| ដុង-វៀតណាម | ០,២០០ | ០,១៩៨ | ០,១៩៦ | ០,១៩៥ | ០,១៩៥ | ០,១៩២ | ០,១៩២ | ០,១៩៣ | ០,១៩២ | ០,១៩២ | ០,១៩៣ | ០,១៩៥ | ០,១៩៤ | -៣,០ |
| **អឺរ៉ុប** | | | | | | | | | | | | | | |
| អឺរ៉ូ | ៥.៩៥៥ | ៥.៨៧៦ | ៥.៩០៩ | ៥.៥៤៦ | ៥.៨១០ | ៥.៣៧១ | ៥.២៣០ | ៥.៣៣៨ | ៥.៤១០ | ៥.៣២០ | ៥.៣២៦ | ៥.០២៦ | ៥.០៥៦ | -១៥,១ |
| **ផ្សេង** | | | | | | | | | | | | | | |
| ផោន-អង់គ្លេស | ៦.៦១២ | ៦.៧០៨ | ៦.៦៧៦ | ៦.៣៧១ | ៦.៥៩២ | ៦.២៩០ | ៦.២២៥ | ៦.៣៨២ | ៦.៣៩១ | ៦.៣៧៥ | ៦.៥៤៩ | ៦.២៨៧ | ៦.៣០៩ | -៤,៦ |

# ឧបសម្ព័ន្ធ ៣

## តារាង៣ - ស្ថានភាពរូបិយវត្ថុ

(ឯកតា : ពាន់លានរៀល)

| | ២០១១ | | ២០១២ | | | | | |
|---|---|---|---|---|---|---|---|---|
| | មិថុនា | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **១៨.១០០** | **១៧.៨៩៤** | **១៨.៤៦៧** | **១៨.៧៦២** | **១៨.៦៥២** | **១៨.៦៤៤** | **១៨.១២៥** | **១៨,៧៣០** |
| ទ្រព្យសកម្មបរទេស | ២០.៩១៥ | ២០.៦១៧ | ២១.៦២៩ | ២២.១៨៨ | ២២.៦៣២ | ២៣.០៦៩ | ២២.៦៩៩ | ២៣.៤២៩ |
| ទ្រព្យអកម្មបរទេស | -២.៨១៥ | -២.៧២៣ | -៣.១៦២ | -៣.៤២៥ | -៣.៩៨០ | -៤.៤២៥ | -៤.៥៧៤ | -៤,៦៩៩ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **៣.៩០៨** | **៥.៧៦១** | **៥.៦៧៩** | **៦.០១១** | **៦.២១១** | **៦.៦៦៩** | **៧.៧៥៧** | **៧.៩២២** |
| **ឥណទានក្នុងស្រុក** | **១៣.១០៨** | **១៥.៤៣០** | **១៥.៩៨៦** | **១៦.២៤៥** | **១៦.២៤៧** | **១៦.៧៩០** | **១៧.៣៧៣** | **១៧.៦៨៦** |
| **ឥណទេយ្យសុទ្ធចំពោះរដ្ឋាភិបាល** | **-២.១៨៤** | **-២.១២៣** | **-២.២០០** | **-២.២០១** | **-២.៥៤២** | **-២.៤០៦** | **-២.៣១០** | **-២.៤០០** |
| ឥណទេយ្យចំពោះរដ្ឋាភិបាល | ២៧០ | ២៧០ | ២៧០ | ២៧០ | ២៧០ | ២៧០ | ២៧០ | ២៧០ |
| ប្រាក់បញ្ញើរដ្ឋាភិបាល | -២.៤៥៥ | -២.៣៩៣ | -២.៤៧១ | -២.៤៧១ | -២.៨១៣ | -២.៦៧៧ | -២.៥៨០ | -២.៦៧០ |
| **ផ្នែកមិនមែនរដ្ឋាភិបាល** | **១៥.២៩២** | **១៧.៥៥៣** | **១៨.១៨៦** | **១៨.៤៤៥** | **១៨.៧៨៩** | **១៩.១៩៦** | **១៩.៦៨២** | **២០.០៨៦** |
| ចំពោះសហគ្រាសរដ្ឋ | ២ | 0 | 0 | 0 | 0 | 0 | 0 | ៤ |
| ចំពោះផ្នែកឯកជន | ១៥.២៩១ | ១៧.៥៥៣ | ១៨.១៨៦ | ១៨.៤៤៥ | ១៨.៧៨៩ | ១៩.១៩៦ | ១៩.៦៨២ | ២០.០៨១ |
| ក្នុងនោះជារូបិយប័ណ្ណបរទេស | ១៤.៨៩៨ | ១៧.១១៥ | ១៨.០០០ | ១៨.២៦០ | ១៨.៦០៦ | ១៩.០០៩ | ១៩.៤៩៤ | ១៩.៨៩៣ |
| **ខ្ទង់ផ្សេងៗសុទ្ធ** | **-៩.២០០** | **-៩.៦៦៩** | **-១០.៣០៧** | **-១០.២៣៤** | **-១០.០៣៥** | **-១០.១២១** | **-៩.៦១៦** | **-៩.៧៦៤** |
| ប្រាក់បញ្ញើរឹតត្បិត | -៥៦៩ | -៦០៨ | -៦២១ | -៧១២ | -៦៧៦ | -៧១១ | -៧៣៥ | -៦៨៦ |
| ដើមទុន និងទុនបម្រុង | -៩.៥០៧ | -៩.៧០៣ | -១០.៧២៣ | -១០.៩១១ | -១០.៧៩៨ | -១១.០០៧ | -១០.៨៦០ | -១១.០២៦ |
| ផ្សេងៗ | ៨៧៥ | ៦៤១ | ១.០៣៧ | ១.៣៨៩ | ១.៤៣៩ | ១.៥៩៧ | ១.៩៧៩ | ១.៩៤៩ |
| **រូបិយវត្ថុទូទៅ** (M2) | **២២.០០៨** | **២៣.៦៥៥** | **២៤.១៤៦** | **២៤.៧៧៣** | **២៤.៨៦៤** | **២៥.៣១៣** | **២៥.៨៨២** | **២៦.៦៥២** |
| **រូបិយវត្ថុ** (M1) | **៣.៥៤០** | **៣.៩៥៦** | **៣.៩១៦** | **៣.៩៧១** | **៣.៩៨៥** | **៤.០២៩** | **៤.០៨៥** | **៣.៨៧២** |
| រូបិយវត្ថុក្រៅធនាគារ | ៣.៣៣៨ | ៣.៧៧២ | ៣.៦៦៧ | ៣.៧៥៦ | ៣.៨១១ | ៣.៧៤៤ | ៣.៨០០ | ៣.៦៣២ |
| ប្រាក់បញ្ញើចរន្ត | ២០២ | ១៨៥ | ២៤៩ | ២១៥ | ១៧៤ | ២៨៦ | ២៨៥ | ២៤០ |
| **រូបិយវត្ថុផ្សេងៗ** | **១៨.៤៦៨** | **១៩.៦៩៨** | **២០.២៣០** | **២០.៨០៣** | **២០.៨៧៩** | **២១.២៨៤** | **២១.៧៩៧** | **២២.៧៨០** |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | ៤៣០ | ៥៥៧ | ៧២០ | ៥៥៦ | ៨៩៦ | ៨៦៧ | ៧៣០ | ៦២៥ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ១៨.០៣៨ | ១៩.១៤១ | ១៩.៥១០ | ២០.២៤៧ | ១៩.៩៨៣ | ២០.៤១២ | ២១.០៦៧ | ២២.១៥៥ |

# ឧបសម្ព័ន្ធ ៤

## តារាង៤ - ស្ថានភាពរូបិយវត្ថុ

(បម្រែបម្រួលជាភាគរយប្រចាំខែ)

| | ២០១១ | | ២០១២ | | | | | |
|---|---|---|---|---|---|---|---|---|
| | មិថុនា | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **-១,១** | **០,៥** | **៣,២** | **១,៦** | **-០,៦** | **០,០** | **-២,៨** | **៣,៣** |
| ទ្រព្យសកម្មបរទេស | ០,៣ | -០,២ | ៤,៩ | ២,៦ | ២,០ | ១,៩ | -១,៦ | ៣,២ |
| ទ្រព្យអកម្មបរទេស | ១០,៤ | -៤,១ | ១៦,១ | ៨,៣ | ១៦,២ | ១១,២ | ៣,៤ | ២,៧ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **១៩,៩** | **១២,៤** | **-១,៤** | **៥,៨** | **៣,៣** | **៧,៤** | **១៦,៣** | **២,១** |
| **ឥណទានក្នុងស្រុក** | **៦,៣** | **៤,៤** | **៣,៦** | **១,៦** | **០,០** | **៣,៣** | **៣,៥** | **១,៨** |
| **ឥណទេយ្យសុទ្ធចំពោះរដ្ឋាភិបាល** | **៧,៥** | **-១,៣** | **-៣,៦** | **០,០** | **-១៥,៥** | **៥,៤** | **៤,០** | **-៣,៩** |
| ឥណទេយ្យចំពោះរដ្ឋាភិបាល | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| ប្រាក់បញ្ញើរដ្ឋាភិបាល | -៦,៨ | ១,២ | ៣,២ | ០,០ | ១៣,៨ | -៤,៨ | -៣,៦ | ៣,៥ |
| **ផ្នែកមិនមែនរដ្ឋាភិបាល** | **៤,០** | **៤,០** | **៣,៦** | **១,៤** | **១,៩** | **២,២** | **២,៥** | **២,០** |
| ចំពោះសហគ្រាសរដ្ឋ | -១,៣ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ១០០ |
| ចំពោះផ្នែកឯកជន | ៤,០ | ៤,០ | ៣,៦ | ១,៤ | ១,៩ | ២,២ | ២,៥ | ២,០ |
| ក្នុងនោះជារូបិយប័ណ្ណបរទេស | ៤,៧ | ៣,៧ | ៥,២ | ១,៤ | ១,៩ | ២,២ | ២,៥ | ២,០ |
| **ខ្ទង់ផ្សេងៗសុទ្ធ** | **-១,៣** | **-០,១** | **-៦,៦** | **០,៧** | **១,៩** | **-០,៨** | **៥,០** | **-១,៥** |
| ប្រាក់បញ្ញើរឹតត្បិត | ៥,៣ | ៣,៨ | ២,៣ | ១៤,៥ | -៥,០ | ៥,១ | -៣,៤ | -៦,៦ |
| ដើមទុន និងទុនបម្រុង | ១,១ | -០,៦ | ១០,៥ | ១,៨ | -១,០ | ១,៩ | -១,៣ | ១,៥ |
| ផ្សេងៗ | ១,៦ | -៦,៦ | ៦១,៨ | ៣៣,៩ | ៣,៦ | ១១,០ | ២៣,៩ | -១,៥ |
| **រូបិយវត្ថុទូទៅ** (M2) | **២,១** | **៣,១** | **២,១** | **២,៦** | **០,៤** | **១,៨** | **២,២** | **៣,០** |
| **រូបិយវត្ថុ** (M1) | **-០,៤** | **៥,០** | **-១,០** | **១,៤** | **០,៤** | **១,១** | **១,៤** | **-៥,២** |
| រូបិយវត្ថុក្រៅធនាគារ | -១,៥ | ៤,៧ | -២,៨ | ២,៤ | ១,៥ | -១,៨ | ១,៥ | -៤,៤ |
| ប្រាក់បញ្ញើចរន្ត | ២២,០ | ១២,២ | ៣៥,១ | -១៤,០ | -១៩,០ | ៦៤,៤ | ០,០ | -១៥,៩ |
| **រូបិយវត្ថុផ្សេងៗ** | **២,៦** | **២,៨** | **២,៧** | **២,៨** | **០,៤** | **១,៩** | **២,៤** | **៤,៥** |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | ០,៥ | -០,៦ | ២៩,៣ | -២២,៨ | ៦១,២ | -៣,៣ | -១៥,៨ | -១៤,៣ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ២,៦ | ២,៩ | ១,៩ | ៣,៨ | -១,៣ | ២,២ | ៣,២ | ៥,២ |

# ឧបសម្ព័ន្ធ ៥

## តារាង៥ - តារាងគណនីវិភាគធនាគារជាតិនៃកម្ពុជា

| | ២០១១ | | ២០១២ | | | | | |
|---|---|---|---|---|---|---|---|---|
| | មិថុនា | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
| | | | គិតជាពាន់លានរៀល | | | | | |
| **រូបិយវត្ថុបម្រុង** | **១០.៨៥៦** | **១១.០៣៣** | **១១.១៨៤** | **១១.៥៧៤** | **១១.៦៧៧** | **១១.៧៣៧** | **១១.៩៥៧** | **១២.៥៥២** |
| **រូបិយវត្ថុក្រៅធនាគារ** | **៣.៣៣៨** | **៣.៧៧២** | **៣,៦៦៧** | **៣.៧៥៦** | **៣.៨១១** | **៣.៧៤៤** | **៣.៨០០** | **៣.៦៣២** |
| **បេឡាធនាគារពាណិជ្ជ** | **១៥៧** | **១៧៦** | **២៣៣** | **២១៣** | **២៣០** | **២៨៦** | **២២៤** | **២៦៦** |
| **ប្រាក់បញ្ញើធនាគារ** | **៧.២៧៩** | **៧.០៣២** | **៧.២០៤** | **៧.៥៦១** | **៧.៦០១** | **៧.៦៣៦** | **៧.៨៤៤** | **៨.៥៩០** |
| ប្រាក់បម្រុងកាតព្វកិច្ច | ២.៤៦៩ | ២.៦៣៤ | ២.៧២៤ | ២.៧៨៩ | ២.៨៧៥ | ២.៩៣៤ | ៣.០០៩ | ៣.០៥៧ |
| ប្រាក់បញ្ញើផ្សេងៗ | ៤.៨១០ | ៤.៣៩៨ | ៤.៤៨០ | ៤.៧៧២ | ៤.៧២៦ | ៤.៧០២ | ៤.៨៣៥ | ៥.៥៣២ |
| **ផ្សេងៗ** | **៨១** | **៥៣** | **៨១** | **៤៥** | **៣៥** | **៧១** | **៨៨** | **៦៤** |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **១៦.១៦៥** | **១៦.០១០** | **១៦.៥៥៤** | **១៧.០៥១** | **១៧.១២៧** | **១៧.១៤៦** | **១៧.០៣៧** | **១៧.៦៧៥** |
| ទ្រព្យសកម្មបរទេស | ១៦.៦១៦ | ១៦.៤៣៥ | ១៦.៩៨៥ | ១៧.៤៧៩ | ១៧.៥៥១ | ១៧.៥៧៤ | ១៧.៤៥៧ | ១៨.០៩៨ |
| ទ្រព្យអកម្មបរទេស | ៤៥២ | ៤២៥ | ៤៣២ | ៤២៨ | ៤២៤ | ៤២៨ | ៤២១ | ៤២៣ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **-៥.៣០៩** | **-៤៩៧៧** | **-៥៣៧០** | **-៥.៤៧៦** | **-៥.៤៤៩** | **-៥.៤០៩** | **-៥.០៨០** | **-៥.១២៣** |
| **ឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាល** | **-១.៨៤៦** | **-១.៧៨៣** | **-១.៨១០** | **-១.៨១៥** | **-២.០៨៥** | **-១,៩៥២** | **-១.៨៨៤** | **-១.៩៤៦** |
| ឥណទេយ្យចំពោះរាជរដ្ឋាភិបាល | ២៧០ | ២៧០ | ២៧០ | ២៧០ | ២៧០ | ២៧០ | ២៧០ | ២៧០ |
| ប្រាក់បញ្ញើរាជរដ្ឋាភិបាល | ២.១១៦ | ២.០៥៤ | ២.០៨០ | ២.០៨៦ | ២.៣៥៥ | ២.២២២ | ២.១៥៤ | ២.២១៦ |
| **ឥណទានសុទ្ធចំពោះធនាគារពាណិជ្ជ** | **-៥០៥** | **-៥៧៦** | **-៥៤៥** | **-៦០៨** | **-៦១៤** | **-៦៥០** | **-៦៧៣** | **-៦២៣** |
| **ខ្ទង់ផ្សេងៗសុទ្ធ** | **-២៩៥៩** | **-២.៦១៧** | **-៣.០១៥** | **-៣.០៥៨** | **-២.៧៥០** | **-២.៨០៨** | **-២.៥២៣** | **-២.៥៥៥** |
| | | | បម្រែបម្រួលប្រចាំខែជាភាគរយ | | | | | |
| **រូបិយវត្ថុបម្រុង** | **០,៦** | **២,៥** | **១,៤** | **៣,៥** | **០,៩** | **០,៥** | **១,៩** | **៥,០** |
| **រូបិយវត្ថុក្រៅធនាគារ** | **-១,៥** | **៤,៧** | **-២.៨** | **២,៤** | **១,៥** | **-១,៨** | **១,៥** | **-៤,៤** |
| **បេឡាធនាគារពាណិជ្ជ** | **-៧,១** | **-២,៥** | **៣២,២** | **-៨,៦** | **៨,៤** | **២៤,១** | **-២១,៦** | **១៨,៩** |
| **ប្រាក់បញ្ញើធនាគារ** | **១,២** | **១,៣** | **២,៤** | **៥,០** | **០,៥** | **០,៥** | **២,៧** | **៩,៥** |
| ប្រាក់បម្រុងកាតព្វកិច្ច | ៣,២ | ១,៧ | ៣,៤ | ២,៤ | ៣,១ | ២,០ | ២,៦ | ១,៦ |
| ប្រាក់បញ្ញើផ្សេងៗ | ០,២ | ១,០ | ១,៩ | ៦,៥ | -១,០ | -០,៥ | ២,៨ | ១៤,៤ |
| **ផ្សេងៗ** | **៨០,៩** | **៤០,៧** | **៥១,១** | **-៤៣,៩** | **-២៣,០** | **១០៤,៣** | **២៤,៥** | **-២៧,៤** |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **០,០** | **០,២** | **៣,៤** | **៣,០** | **០,៤** | **០,១** | **-០,៦** | **៣,៧** |
| ទ្រព្យសកម្មបរទេស | ០,០ | ០,២ | ៣,៤ | ២,៩ | ០,៤ | ០,១ | -០,៧ | ៣,៧ |
| ទ្រព្យអកម្មបរទេស | ០,៨ | -១,០ | ១,៧ | -០,៩ | -០,៩ | ០,៨ | -១,៦ | ០,៥ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **១,១** | **៤,៦** | **-៧,៩** | **-២,០** | **០,៥** | **០,៧** | **៦,១** | **-០,៨** |
| **ឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាល** | **៥,០** | **-១,១** | **-១,៥** | **-០,៣** | **-១៤,៩** | **៦,៤** | **៣,៥** | **-៣,៣** |
| ឥណទេយ្យចំពោះរាជរដ្ឋាភិបាល | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| ប្រាក់បញ្ញើរាជរដ្ឋាភិបាល | -៤,៤ | ១,០ | ១,៣ | ០,៣ | ១២,៩ | -៥,៧ | -៣,១ | ២,៩ |
| **ឥណទានសុទ្ធចំពោះធនាគារពាណិជ្ជ** | **-៥,៩** | **-៧,២** | **៥,៥** | **-១១,៧** | **-១,០** | **-៥,៨** | -៣,៦ | ៧,៥ |
| **ខ្ទង់ផ្សេងៗសុទ្ធ** | **-០,២** | **១០,២** | **-១៥,២** | **-១,២** | **៩,៩** | **-២,១** | **១០,១** | **-១,៣** |

# ឧបសម្ព័ន្ធ ៦

## តារាង៦ - តារាងគណនីវិភាគធនាគារពាណិជ្ជ

| | ២០១១ | | ២០១២ | | | | | |
|---|---|---|---|---|---|---|---|---|
| | មិថុនា | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
| | | | គិតជាពាន់លានរៀល | | | | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **១.៩៣៥** | **១.៨៨៤** | **១.៩១៤** | **១.៧១២** | **១.៥២៦** | **១.៤៩៨** | **១.០៨៨** | **១.០៥៥** |
| ទ្រព្យសកម្មបរទេស | ៤.២៩៨ | ៤.១៨២ | ៤.៦៤៤ | ៤.៧០៩ | ៥.០៨២ | ៥.៤៩៥ | ៥.២៤១ | ៥.៣៣១ |
| ទ្រព្យអកម្មបរទេស | ២.៣៦៣ | ២.២៩៨ | ២.៧៣០ | ២.៩៩៧ | ៣.៥៥៦ | ៣.៩៩៧ | ៤.១៥៣ | ៤.២៧៧ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **៨.៧៨០** | **១០.៧៧២** | **១០.៦១០** | **១១.០២៨** | **១១.០៩៦** | **១១.៥០៩** | **១២.៣១៥** | **១២.៦០៤** |
| **ឥណទានក្នុងស្រុកសុទ្ធ** | **១៤,៤៥៥** | **១៧.២១៣** | **១៧.៧៥៥** | **១៨.០២០** | **១៨.២៩១** | **១៨.៧០១** | **១៩.២១៦** | **១៩.៥៩១** |
| ឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាល | -៣៣២ | -៣៤០ | -៣៩០ | -៣៨៥ | -៤៥៧ | -៤៥៤ | -៤២៦ | -៤៥៤ |
| ឥណទានចំពោះសហគ្រាសរដ្ឋ | ២ | ០ | ០ | ០ | ០ | ០ | ០ | ៤ |
| ឥណទានចំពោះផ្នែកឯកជន | ១៥.២៩១ | ១៧.៥៥៣ | ១៨.១៨៦ | ១៨.៤៤៥ | ១៨.៧៨៩ | ១៩,១៩៦ | ១៩.៦៨២ | ២០.០៨១ |
| ឥណទេយ្យសុទ្ធចំពោះធនាគារជាតិនៃកម្ពុជា | -១២ | ០ | -៤១ | -៤១ | -៤១ | -៤១ | -៤១ | -៤១ |
| **ខ្ទង់ផ្សេងៗសុទ្ធ** | **-៦.១៦២** | **-៦.៤៩២** | **-៧.១៤៦** | **-៦.៩៩២** | **-៧.១៩៥** | **-៧.១៩២** | **-៦.៩០១** | **-៦.៩៨៧** |
| **ទុនបម្រុង** | **៧.៨៧៣** | **៧.២២៤** | **៧.៨៧៥** | **៨.២៣២** | **៨.៣៩៦** | **៨.៤៩១** | **៨.៥៩១** | **៩.២៩៨** |
| សាច់ប្រាក់នៅធនាគារពាណិជ្ជ | ១៥៧ | ១៧៦ | ២៣៣ | ២១៣ | ២៣០ | ២៨៦ | ២២៤ | ២៦៦ |
| ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា | ៧.៧១៦ | ៧.០៤៨ | ៧.៦៤៣ | ៨.០២០ | ៨.១៦៦ | ៨,២០៦ | ៨.៣៦៧ | ៩.០៣១ |
| **ប្រាក់បញ្ញើ (ទ្រព្យអកម្មក្នុងស្រុកសុទ្ធ)** | **១៨.៥៨៨** | **២១.៤៩៩** | **២០.៣៩៩** | **២០.៩៧២** | **២១.០១៨** | **២១.៤៩៩** | **២២.២៧៧** | **២២.៩៥៦** |
| ប្រាក់បញ្ញើចរន្ត | ១២១ | ២១៥ | ១៦៩ | ១៦៩ | ១៣៩ | ២១៥ | ១៩៧ | ១៧៦ |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | ៤៣០ | ៨៦៧ | ៧២០ | ៥៥៦ | ៨៩៦ | ៨៦៧ | ៧៣០ | ៦២៥ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ១៨.០៣៨ | ២០.៤១៧ | ១៩.៥១០ | ២០.២៤៧ | ១៩.៩៨៣ | ២០.៤១៧ | ២១.០៦៧ | ២២.១៥៥ |
| **ទ្រព្យសកម្មសរុប = ទ្រព្យអកម្មសរុប** | **២៩.៩៣៣** | **៣២,២១៦** | **៣៤.៦២៨** | **៣៥.៦៦២** | **៣៦.៧១២** | **៣៧,៥៨០** | **៣៨,៥២១** | **៣៩.៩០៨** |
| | | | បម្រែបម្រួលប្រចាំខែជាភាគរយ | | | | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **-៩,២** | **២,៨** | **១,៦** | **-១០,៦** | **-១០,៩** | **-១,៨** | **-២៧,៤** | **-៣,១** |
| ទ្រព្យសកម្មបរទេស | ១,៥ | -១,៥ | ១១,០ | ១,៤ | ៧,៩ | ៨,១ | -៤,៦ | ១,៧ |
| ទ្រព្យអកម្មបរទេស | ១២,៥ | -៤,៧ | ១៨,៨ | ៩,៨ | ១៨,៦ | ១២,៤ | ៣,៩ | ៣,០ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **៧,៨** | **៨,២** | **-១,០** | **៣,៩** | **០,៦** | **៣,៧** | **៧,០** | **២,៣** |
| **ឥណទានក្នុងស្រុកសុទ្ធ** | **៤,៨** | **៤,០** | **៣,១** | **១,៥** | **១,៥** | **២,២** | **២,៨** | **២,០** |
| ឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាល | ១៩,៤ | -២,៦ | -១៤,៨ | ១,២ | -១៨,៧ | ០,៧ | ៦,៣ | -៦,៦ |
| ឥណទានចំពោះសហគ្រាសរដ្ឋ | -១,៣ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ឥណទានចំពោះផ្នែកឯកជន | ៤,០ | ៤,០ | ៣,៦ | ១,៤ | ១,៩ | ២,២ | ២,៥ | ២,០ |
| ឥណទេយ្យសុទ្ធចំពោះធនាគារជាតិនៃកម្ពុជា | -៤១,០ | ០ | ០ | ០ | ០ | ០,១ | -០,១ | ០ |
| **ខ្ទង់ផ្សេងៗសុទ្ធ** | **-០,៨** | **២,២** | **-១០,១** | **២,២** | **-២,៩** | **០,០** | **៤,០** | **-១,២** |
| **ទុនបម្រុង** | **០,៤** | **-៤,៤** | **៩,០** | **៤,៥** | **២,០** | **១,១** | **១,២** | **៨,២** |
| សាច់ប្រាក់នៅធនាគារពាណិជ្ជ | -៧,១ | -២,៥ | ៣២,២ | -៨,៦ | ៨,៤ | ២៤,១ | -២១,៦ | ១៨,៩ |
| ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា | ០,៦ | -៤,៤ | ៨,៤ | ៤,៩ | ១,៨ | ០,៥ | ២,០ | ៧,៩ |
| **ប្រាក់បញ្ញើ (ទ្រព្យអកម្មក្នុងស្រុកសុទ្ធ)** | **២,៦** | **២,៨** | **២,៩** | **២,៨** | **០,២** | **២,៣** | **២,៣** | **៤,៤** |
| ប្រាក់បញ្ញើចរន្ត | ០,០ | ៣,៦ | ២៨,៦ | ០,៣ | -១៧,៩ | ៥៤,៤ | -៨,១ | -១០,៨ |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | ០,៥ | -០,៦ | ២៩,៣ | -២២,៨ | ៦១,២ | -៣,៣ | -១៥,៨ | -១៤,៣ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ២,៦ | ២,៩ | ១,៩ | ៣,៨ | -១,៣ | ២,២ | ៣,២ | ៥,២ |
| **ទ្រព្យសកម្មសរុប = ទ្រព្យអកម្មសរុប** | **២,៩** | **១,៩** | **៧,៥** | **៣,០** | **២,៩** | **២,៤** | **២,៥** | **៣,៦** |

# ឧបសម្ព័ន្ធ ៧

## តារាង០៧ - ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច

(ឯកតា : ពាន់លានរៀល)

| | ២០១១ | | ២០១២ | | | | | |
|---|---|---|---|---|---|---|---|---|
| | មិថុនា | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
| **១- គ្រឹះស្ថានហិរញ្ញវត្ថុ** | **២២៩** | **៣២៤** | **៣១៣** | **៣០៤** | **៣២៧** | **៣៦៣** | **៦១០** | **៣៤៦** |
| ធនាគារជាតិនៃកម្ពុជា | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| គ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | ៣៤ | ១០៥ | ១០៥ | ៩៩ | ១២០ | ១៦៤ | ៤២០ | ១៦២ |
| គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗទៀត | ១៩៤ | ២១៩ | ២០៧ | ២០៦ | ២០៧ | ១៩៩ | ១៩១ | ១៨៤ |
| **២- គ្រឹះស្ថានមិនបម្រើសេវាហិរញ្ញវត្ថុ** | **១៣.៤៦២** | **១៥.០៥៧** | **១៥.៥៦៧** | **១៥.៩០៩** | **១៦.២០៣** | **១៦.៦៦៧** | **១៧.១៦៧** | **១៧.៦៣៧** |
| កសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | ១.១៧៦ | ១.៥៦៩ | ១.៦៨៩ | ១.៧៧៤ | ១.៨១៩ | ១.៨៧៣ | ១.៩៦៥ | ២.០៤៤ |
| ឧស្សាហកម្មរ៉ែ | ៦៥ | ១៣ | ៧៤ | ៦៩ | ៧៦ | ៧៨ | ១៦១ | ៧៩ |
| កម្មន្តសាលកម្ម | ១.៥០៨ | ១.៦២២ | ១.៦៩៦ | ១.៧១៩ | ១.៧០៣ | ១.៧៣២ | ១.៧៥៩ | ១.៩១៨ |
| ការផ្គត់ផ្គង់សេវាសាធារណៈ | ១២៥ | ២០៩ | ២០៣ | ២១០ | ២១២ | ២១៣ | ២២០ | ២០៩ |
| សំណង់ | ១.១៣១ | ១.៣១៧ | ១.២០៧ | ១.២៨០ | ១.៤២៦ | ១.៣២៥ | ១.៤០១ | ១.៤២៥ |
| ការជួញដូរដុំ | ២.៧០៣ | ២.៥៤៥ | ២.៥៦២ | ២.៦៨១ | ២.៨៣៣ | ៣.១០២ | ៣.០១១ | ៣.២៨៧ |
| ការជួញដូររាយ | ២.៦២៤ | ៣១៨៧ | ៣.២៦៥ | ៣.១៩៩ | ៣.១១២ | ៣.២០៨ | ៣.២៦១ | ៣.៣២៩ |
| សណ្ឋាគារនិងភោជនីយដ្ឋាន | ១.៣៣៥ | ១.៣១២ | ១.៣៣៣ | ១.៣៩៥ | ១.៣៩៦ | ១.៤៥៧ | ១.៥៣៩ | ១.៥៣៣ |
| ដឹកជញ្ជូននិងស្តុកបណ្តោះអាសន្ន | ២៨៤ | ២៧២ | ២៨៥ | ២៨១ | ២៨៣ | ២៨៧ | ២៩៩ | ២៩៤ |
| បណ្តាញព័ត៌មាននិងទូរគមនាគមន៍ | ៣៩៩ | ៥២៨ | ៥៨០ | ៥៥៧ | ៥៥៨ | ៥៤៩ | ៥៣៥ | ៥១៣ |
| អាជីវកម្មជួលនិងភតិសន្យាប្រតិបត្តិការ មិនរាប់បញ្ចូលភតិសន្យា និងការជួលអចលនទ្រព្យ | ១៥៧ | ២៩៣ | ២៩២ | ២៨៦ | ២៨០ | ២៧៤ | ២៩២ | ២៦០ |
| ការជួញដូរអចលនទ្រព្យ | ៥៥១ | ៥៦៥ | ៥៦២ | ៥៥៥ | ៥៦៦ | ៥៧៣ | ៦៥៦ | ៦៣៥ |
| សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗទៀត | ១.៤០៣ | ១.៦២៤ | ១.៨១៨ | ១.៩០៣ | ១.៩៤១ | ១.៩៩៦ | ២.០៦៧ | ២.១១៣ |
| **៣- គម្រោងការផ្ទាល់ខ្លួនផ្សេងៗទៀត** | **១.៤២៨** | **២.០០២** | **២.០៥២** | **២.០១៤** | **២.០៣២** | **២.០៨៥** | **២.០១២** | **២.០៧៨** |
| ការឲ្យខ្ចីជាបុគ្គល | ៧៣៣ | ៨៧៤ | ៨៩៣ | ៨៥១ | ៨៦០ | ៨៨១ | ៧៦២ | ៧៩២ |
| ការឲ្យខ្ចីតាមប័ណ្ណឥណទាន | ៣០ | ៣៣ | ៣២ | ២៩ | ២៩ | ៣៥ | ៣៥ | ៣៣ |
| ការឲ្យខ្ចីទិញផ្ទះជាកម្មសិទ្ធផ្ទាល់ខ្លួន | ៦៦៥ | ១.០៩៦ | ១.១២៧ | ១.១៣៥ | ១.១៤៣ | ១.១៧០ | ១.២១៦ | ១.២៥៣ |
| **៤- ឥណទានផ្សេងៗ** | **២២២** | **២៩៧** | **២៨៣** | **២១៧** | **២១០** | **១៩៧** | **២១៥** | **៣១៣** |
| **សរុបឥណទានដុល** | **១៥,៣៤២** | **១៧.៦៨០** | **១៨.២១៤** | **១៨.៤៤៤** | **១៨.៧៧៣** | **១៩.៣១២** | **២០.០០៤** | **២០.៣៧៥** |

## តារាង០៨ - សរុបប្រតិបត្តិការប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ

(ឯកតា : ពាន់លានរៀល)

| | ២០១១ | | ២០១២ | | | | | |
|---|---|---|---|---|---|---|---|---|
| | មិថុនា | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
| **ប្រាក់បញ្ញើជារៀល** | | | | | | | | |
| ប្រាក់បញ្ញើជារៀល | ១៨៥ | ១៧៦ | ២៥១ | ២៥៧ | ២៩៥ | ៣៧២ | ៣០៤ | ៣២៣ |
| ប្រាក់បញ្ញើសន្សំ | ១៩៨ | ២៦៧ | ២៦៧ | ២៤៨ | ៣៣៨ | ៣៤៦ | ៣៨៧ | ៣៣៩ |
| ប្រាក់បញ្ញើមានកាលកំណត់ | ២១៨ | ២៨២ | ២៦៥ | ២៧៧ | ២៨២ | ២៦៧ | ២៧៨ | ២៩៣ |
| ប្រាក់បញ្ញើផ្សេងៗ | ០,៤ | ០,៣ | ៦ | ៦ | ៦ | ៧ | ៧ | ៧ |
| **សរុប** | **៦០១** | **៧២៥** | **៧៨៨** | **៧៨៩** | **៩២១** | **៩៩១** | **៩៧៦** | **៩៦២** |
| **ប្រាក់បញ្ញើជារូបិយប័ណ្ណ** | | | | | | | | |
| ប្រាក់បញ្ញើជារៀល | ៣.៤៨៣ | ៣.៨៣៥ | ៤.១៩៤ | ៤.៣៩៥ | ៤.១៦២ | ៤.៣៦៨ | ៤.៥០៥ | ៤.២៩៦ |
| ប្រាក់បញ្ញើសន្សំ | ៦.៦៦៩ | ៧.០១០ | ៧.២៩៩ | ៧.៤៩៦ | ៧.៥០៨ | ៧.៦០៤ | ៧.៥៨៥ | ៧.៧៦៤ |
| ប្រាក់បញ្ញើមានកាលកំណត់ | ៨.៩២8 | ៨.៨៩៨ | ៩.០៥៣ | ៩.១៩៤ | ៩.៤៦៤ | ៩.៦៤៩ | ១០.០៣៤ | ១០.២៦៤ |
| ប្រាក់បញ្ញើផ្សេងៗ | ១០៣ | ៤១២ | ៤៥០ | ៤៥៣ | ៤០៦ | ៣៥៤ | ៣៦៦ | ១.១៨៩ |
| **សរុប** | **១៩.១៨៣** | **២០.១៥៦** | **២០.៩៤៣** | **២១.៥៣៨** | **២១.៥៤០** | **២១.៩៧៥** | **២២.៤៨៩** | **២៣.៥១២** |
| **សរុបរួម** | **១៩.៧៨៤** | **២០.៨៨១** | **២១.៧៣១** | **២២.៣២៧** | **២២.៤៦១** | **២២.៩៦៦** | **២៣.៤៦៥** | **២៤.៤៧៤** |

# ឧបសម្ព័ន្ធ ៨

## ជញ្ជីងទូទាត់ប្រទេសកម្ពុជា

ឆ្នាំ២០០៩ ដល់ ឆមាសទី១ ឆ្នាំ២០១២

( គិតជាលានដុល្លារអាមេរិក )

| | ២០០៩ | ២០១០ | ២០១១ | | ២០១២[ព] |
|---|---|---|---|---|---|
| | | | ឆមាសទី១ | ឆមាសទី២ | ឆមាសទី១ |
| **ជញ្ជីងពាណិជ្ជកម្ម** | **-១.៤៩៤,២** | **-១.៥៨១,៦** | **-៨៦៨,៤** | **-៦២១,៧** | **-៨៥៧,៥** |
| នាំចេញ (FOB) | ២.៩៩៥,៧ | ៣.៨៨៤,៣ | ២.៤៤០,៨ | ២.៧៧៨,៧ | ២.៨៦៥,០ |
| នាំចេញផលិតផលក្នុងស្រុក | ២.៧៣៣,៧ | ៣.៦២០,២ | ២.២៩៣,៥ | ២.៦៣៣,៥ | ២.៧១១,៥ |
| នាំចេញតាមប្រព័ន្ធ GSP ( ភាគច្រើនសម្លៀកបំពាក់ ) | ២.៦២៦,៧ | ៣.៤៣៥,៧ | ២.១៥២,៦ | ២.៤៨៦,៦ | ២.៥៥១,៦ |
| នាំចេញផលិតផលក្នុងស្រុកផ្សេងៗ | ១០៧,០ | ១៨៤,៥ | ១៤០,៨ | ១៤៧,០ | ១៥៩,៩ |
| នាំចេញបន្ត ( រាប់បញ្ចូលចំណេញ និងចំណាយដឹកជញ្ជូន ) | ២៦២,០ | ២៦៤,១ | ១៤៧,៣ | ១៤៥,១ | ១៥៣,៥ |
| នាំចូល (FOB) | -៤.៤៨៩,៩ | -៥.៤៦៦,០ | -៣.៣០៩,២ | -៣.៤០០,៤ | -៣.៧២២,៥ |
| នាំចូលសម្រាប់ប្រើប្រាស់ក្នុងស្រុក | -៤.២៨៨,៨ | -៥.២៦២,២ | -៣.១៩៧,៨ | -៣.២៩១,៥ | -៣.៦០៦,៧ |
| សម្លៀកបំពាក់ | -១.០៤៩,៩ | -១.៣៥៨,៨ | -៨១០,៥ | -៩១៥,៣ | -៩៧០,៣ |
| ប្រេងឥន្ធនៈ | -៤១៣,៧ | -៤៦៥,៩ | -៤៦៧,០ | -៥០១,៧ | -៥៣៩,៥ |
| អគ្គិសនី | -៥៤,៥ | -១០៤,៩ | -៦១,០ | -៦៤,២ | -៦៥,៧ |
| នាំចូលសម្រាប់ប្រើប្រាស់ក្នុងស្រុកផ្សេងៗ | -២.៧៧០,៦ | -៣.៣៣២,៦ | -១.៨៥៩,៤ | -១.៨១០,៣ | -២.០៣១,១ |
| នាំចូលសម្រាប់នាំចេញបន្ត | -២០១,១ | -២០៣,៧ | -១១១,៤ | -១០៨,៩ | -១១៥,៨ |
| **សេវា (សុទ្ធ)** | **៦១៥,៣** | **៦៩៧,៣** | **៣៤២,១** | **៥៤៧,១** | **៥៦៩,៣** |
| ចំណូល | ១.៥២៤,៧ | ១.៦៦៩,០ | ៩៧៣,៣ | ១.២៣៩,៣ | ១.១៧៤,៦ |
| ក្នុងនោះ : សេវាធ្វើដំណើរ | ១.០៨១,៥ | ១.១៧៩,៦ | ៦៨៥,៣ | ៩៣១,១ | ៨៧០,៨ |
| ចំណាយ | -៩០៩,៤ | -៩៧១,៧ | -៦៣១,២ | -៦៩២,២ | -៦០៥,៤ |
| ក្នុងនោះ : សេវាធ្វើដំណើរ | -១០៣,៥ | -១៩៧,៨ | -១០០,០ | -១៥៣,៤ | -១៣៦,៨ |
| **ប្រាក់ចំណូល (សុទ្ធ)** | **-៤៧៧,២** | **-៥២៩,៨** | **-៣០៩,១** | **-៣៨៥,៧** | **-៣០០,៧** |
| ចំណូល | ៥៥,៦ | ៥៨,៧ | ៣០,៣ | ៣១,០ | ២៩,២ |
| ក្នុងនោះ : ការប្រាក់ | ២៦,២ | ២៨,៤ | ១៤,៥ | ១៤,៨ | ១៣,៩ |
| ចំណាយ | -៥៣២,៨ | -៥៨៨,៥ | -៣៣៩,៤ | -៤១៦,៨ | -៣២៩,៩ |
| ក្នុងនោះ : - ការបង់ការប្រាក់ | -៤៨,៨ | -៥២,០ | -២៨,២ | -២៦,០ | -២៩,០ |
| - ចំណូលពីហ៊ុន | -៣៤៤,២ | -៣៨៥,៦ | -២៤៦,៤ | -៣២៥,៩ | -២៣១,៨ |
| **បង្វែរឯកជន (សុទ្ធ)** | **២៩០,៤** | **២៤៣,០** | **៩៤,៦** | **៧៨,៩** | **៩០,៥** |
| ចំណូល | ៣៦៧,៦ | ៣៥១,៥ | ១៤៧,១ | ១៣១,៣ | ១៣៣,២ |
| ចំណាយ | ៧៧,២ | ១០៨,៥ | ៥២,៤ | ៥២,៤ | ៤២,៧ |
| **សមតុល្យគណនីចរន្ត** (មិនរាប់បញ្ចូលបង្វែរផ្លូវការ) | **-១.០៦៥,៧** | **-១.១៧១,២** | **-៧៤០,៨** | **-៣៨១,៤** | **-៤៩៨,៥** |
| **បង្វែរផ្លូវការ (សុទ្ធ)** | **៥៩២,៦** | **៧៣០,៥** | **៣៣១,៩** | **៣០០,៧** | **៣០០,៥** |
| ចំណូល | ៥៩២,៩ | ៧៣០,៨ | ៣៣២,០ | ៣០០,៨ | ៣០០,៦ |
| ចំណាយ | -០,៣ | -០,៣ | -០,១ | -០,១ | -០,១ |
| **សមតុល្យគណនីចរន្ត និងបង្វែរផ្លូវការ** | **-៤៧៣,០** | **-៤៤០,៧** | **-៤០៨,៩** | **-៨០,៧** | **-១៩៨,១** |
| **គណនីហិរញ្ញវត្ថុ** | **៤៧៦,៧** | **៦២០,៤** | **៥៦១,៦** | **២៦៣,២** | **៤៤៦,២** |
| **ឥណទេយ្យផ្លូវការ** (មិនរាប់បញ្ចូល IMF) **សុទ្ធ*** | ១៥៣,១ | ២៤៤,៩ | ១១៣,៣ | ១០៨,៥ | ១១៧,០ |
| ដកប្រាក់ | ១៦៤,១ | ២៥៧,១ | ១១៦,៥ | ១១៦,៨ | ១២១,០ |
| ទូទាត់ | -១១,០ | -១២,១ | -៣,២ | -៨,២ | -៤,០ |
| **វិនិយោគឯកជន** | **៣២៣,៦** | **៣៧៥,៤** | **៤៤៨,៣** | **១៥៤,៦** | **៣២៩,២** |
| វិនិយោគផ្ទាល់ (សុទ្ធ) * | ៥២០,២ | ៧៦២,០ | ៣៣៤,៥ | ៥៣៨,០ | ៤៤៤,២ |
| វិនិយោគលើផលប័ត្រ (សុទ្ធ) * | -៧,៦ | -៣៦,៧ | -២២,៥ | ១៦,៣ | -១៥,០ |
| វិនិយោគផ្សេងទៀត (សុទ្ធ) * | -១៨៩,០ | -៣៤៩,៩ | ១៣៦,២ | -៣៩៩,៧ | -១០០,០ |
| **កំហុស និងរំលង** | **-៨,៤** | **-២៩,៤** | **៥១,៧** | **-៧៨,១** | **-៤៦,៤** |
| **សមតុល្យរួម** | **-៤,៧** | **១៥០,៣** | **២០៤,៣** | **១០៤,៤** | **២០១,៧** |
| **ហិរញ្ញប្បទាន** | **៤,៧** | **-១៥០,៣** | **-២០៤,៣** | **-១០៤,៤** | **-២០១,៧** |
| ទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិ * | -៨,១ | -១៦៣,០ | -២០៧,៤ | -១១៤,១ | -២០៤,៧ |
| បម្រែបម្រួលទ្រព្យសកម្មជាទុនបម្រុងបរទេស | -១១៦,៦ | -១៦៣,០ | -២០៧,៤ | -១១៤,១ | -២០៤,៧ |
| ការប្រើប្រាស់ឥណទានរបស់ IMF | -- | -- | -- | -- | -- |
| ការបែងចែក SDR | ១០៨,៥ | -- | -- | -- | -- |
| ហិរញ្ញប្បទានពិសេស | ១២,៨ | ១២,៨ | ៣,១ | ៩,៧ | ៣,០ |

** តម្លៃវិជ្ជមានតំណាងឲ្យកំណើនទ្រព្យអកម្មបរទេស ឬថយចុះទ្រព្យសកម្មបរទេស និងតម្លៃអវិជ្ជមានតំណាងឲ្យកំណើនទ្រព្យសកម្មបរទេស ឬការថយចុះទ្រព្យអកម្មបរទេស*

***ប្រភព :*** ទិន្នន័យទទួលបានពីអាជ្ញាធរកម្ពុជានិងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

***កំណត់សំគាល់ :*** - ទិន្នន័យបណ្តោះអាសន្នសម្រាប់ឆ្នាំ *២០០៩-២០១១ (* ទិន្នន័យទាំងនេះអាចនឹងត្រូវបានកែប្រែឡើងវិញក្នុងពេលអនាគត *)*

- ព = ព្យាករណ៍ទិន្នន័យសម្រាប់ឆមាសទី១*-២០១២*

បោះពុម្ពដោយធនាគារជាតិ នៃកម្ពុជា